ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

# ទស្សនាវដ្តី គ្រូបង្រៀន

លេខ ៨



ខែ តុលា វិច្ឆិកា ធ្នូ ១៩៩៧

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៩ ៩ មហាវិថីព្រះនរោត្តម (តំបន់៣)




# សេចក្ដីជូនពត៌មានទៅគ្រប់បុគ្គលិកសិក្សាខ្មែរ

- គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ បានផ្ញើជូនទៅគ្រប់គណៈកម្មាធិការ ស.ប.ស.ខ. ខេត្ត - ក្រុង នូវលិខិតមួយច្បាប់លេខ ០៤ គ.ក ចុះថ្ងៃទី ៥-០២- ៩៨ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ :

**កម្មវត្ថុ :** ការផ្ដល់ប្រាក់គរុមរណបត្តម្ភដល់គ្រួសារសព

ខ្ញុំសូមជំរាបលោកប្រធានថា នៅក្នុងស្ថានភាពបច្ចុប្បន្នដែលបុគ្គលិកសិក្សាយើងទាំងអស់កំពុងជួបការលំបាកក្នុងជីវភាពរស់នៅ និងដើម្បីលើកកំពស់ស្មារតីរបស់សមាជិក - សមាជិកាអោយកាន់តែមានសុឆន្ទៈក្នុងការជួយគ្នាទៅវិញទៅមក ព្រមទាំងការលើកស្ទួយនូវកិត្យានុភាពរបស់សមាគមបុគ្គលិកសិក្សាខ្មែរយើងអោយកាន់តែល្អប្រសើរថែមទៀត ដើម្បីអោយចូលជ្រៅទៅគ្រប់ស្រទាប់សង្គមនោះ ខ្ញុំសូមលោកប្រធានមេត្តាផ្ដល់ប្រាក់គរុមរណបត្តម្ភដល់គ្រួសារសព ព្រមទាំងតូស្រករនៃសមាជិកអោយបានគ្រប់ចំនួន តាមសេចក្ដីសំរេចដែលអង្គមហាសន្និបាតឆ្នាំ ១៩៩៦ បានអនុម័តរួចហើយគឺ ១.៣០០.០០០៛ និង ៦៥០.០០០៛ ។

ក្នុងករណីនេះ គណៈកម្មាធិការ ស.ប.ស.ខ. ខេត្ត - ក្រុង ត្រូវចំនាយថវិកាដែលបានតំកល់ទុកនៅក្នុងបេឡារបស់សមាគមដែលមានស្រាប់ ។ ទង្វើនេះ គឺជៀសវាងការថ្នាំងថ្នាក់ចិត្តសមាជិកសមាជិកា ដែលនាំអោយខូចកិត្តិយសសមាគម ។

ដោយសង្ឃឹមយ៉ាងមុតមាំលើការយល់ច្បាស់ពីគោលបំណងសមាគម ខ្ញុំសូមលោកប្រធានផ្សព្វផ្សាយខ្លឹមសារនេះ ជូនដល់គ្រប់សមាជិក - សមាជិកាទាំងអស់អោយបានជ្រាបគ្រប់ៗគ្នា ។

សូមលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

ហត្ថលេខា

**យ៉ង់ ធី**

# បុណ្យឧទ្ទិសកុសល

កាលពីថ្ងៃទី ១០ មេសា ១៩៩៨ ម៉ោង ១៦ : ៣០ នាទី នៅទីស្នាក់ការសមាគមបុគ្គលិកសិក្សាខ្មែរ ១២៨ B មហាវិថីព្រះនរោត្តមភ្នំពេញ គណៈកម្មាធិការនាយក បាននិមន្តព្រះសង្ឃ ៤ អង្គចំរើនព្រះបរិត្ត ដើម្បីឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធនៃបុគ្គលិកសិក្សាខ្មែរ ដែលបានបាត់បង់ជីវិតក្នុងរយៈកាលកន្លងមក និងបុគ្គលិកសិក្សាមួយចំនួនដែលបានធ្វើមរណកាលដ៏អណោចអធមក្នុងសម័យរបបប្រល័យពូជសាសន៍ប៉ុល ពត ។

សូមវិញ្ញាណក្ខន្ធនៃបុគ្គលិកសិក្សាទាំងអស់នោះ បានសោយសុខក្នុងសុគតិភពកុំបីអាក់ខាន ។



# ការចូលគាន់មរណទុក្ខ

កាលពីថ្ងៃទី ២២ - ២៣ មេសា ១៩៩៨ គណៈប្រតិភូនៃគណៈគម្មាធិការនាយក ស.ប.ស.ខ ចំនួន ៤ រូប ដឹកនាំដោយលោកប្រធាន បានអញ្ជើញទៅកាន់ខេត្តកំពត ដើម្បីចូលគាន់មរណទុក្ខជាមួយគ្រួសារសពលោក ងួន ហៀង ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ដែលបានអនិច្ចកម្ម កាលពីថ្ងៃច័ន្ទទី ២០ ខែ មេសា ១៩៩៨ វេលាម៉ោង ៨:០០ យប់ដោយក្រុមជនកំណាចបានធ្វើឃាតនៅក្នុងចំការរបស់គាត់ ។

# វប្បធម៌ខ្មែរ & ការអប់រំ



## ក្រាំងប្រវត្តិសាស្ត្រ

គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ សូមថ្លែងអំណរគុណចំពោះលោក **ពេជ កែវ** អគ្គនាយករងនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងលោក **អ៊ុក ចន** អនុប្រធាននាយកដ្ឋានសារៈមន្ទីរដែលបានជួយសំរួលការងារតាក់តែងអត្ថបទ ដែលមានខ្លឹមសារទុកជាប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា

សូមលោកគ្រូ - អ្នកគ្រូ ពិនិត្យរូបសំណាកព្រះបាទស៊ីសុវត្ថិ ផ្ដិតនៅក្របទស្សនាវដ្ដីគ្រូបង្រៀនយើងនេះ ។

ហេតុអ្វី បានជាខ្ញុំយករូបសំណាកនេះមកផ្ដិត ? តើមានបំនងអ្វី ?

នេះជាសំនួរដែលខ្ញុំត្រូវឆ្លើយបំភ្លឺបុគ្គលិកសិក្សាយើងទូទាំងប្រទេសអោយបានជ្រាប ដើម្បីបំបាត់អវិជ្ជា និងបង្កើនចំនេះដឹងថ្មី ។

លោកគ្រូ - អ្នកគ្រូ ជ្រាបទេថា រូបសំណាកព្រះបាទស៊ីសុវត្ថិ តំកល់នៅចង្កេះភ្នំដូនពេញខាងត្បូង បាត់ទៅនៅឆ្នាំណា ? នរណាយកទៅឯណា ? លុះត្រាតែដល់ពាក់កណ្ដាលខែ មករា ១៩៩៨ ទើបរូបសំណាកនេះ ត្រូវបានយកមកតំកល់នៅកន្លែងដើមវិញ តែជារូបសំណាកចំលងសាងសង់ពីស៊ីម៉ង់ត៍ ។ រូបដើមត្រូវបានរក្សាទុកនៅក្នុងលេណាគ្រឹះនៃសារៈមន្ទីរជាតិ ។ លោក **អ៊ុក ចន** អនុប្រធាននាយកដ្ឋានសារៈមន្ទីរបានចំលងពីរូបដើមតាមសំនូមពររបស់រដ្ឋអំណាចក្រុងភ្នំពេញ ។

សូមជ្រាបថា ក្រោយព្រឹត្តិការណ៍ថ្ងៃ ១៨ មីនា ១៩៧០ រូបសំណាកព្រះបាទស៊ីសុវត្ថិ ត្រូវបានយកទៅថែរក្សាទុកនៅសារមន្ទីរជាតិដោយអ្នកគ្រប់គ្រងមន្ទីរអភិរក្សបុរាណវត្ថុនៅពេលនោះ ។ រូបសំណាកនោះ សាងសង់អំពីល្បាយលោហធាតុមានស្ពាន់ភាគច្រើន ក្នុងឆ្នាំ ១៩០៩ ។

ឥឡូវនេះ សូមលោកគ្រូ - អ្នកគ្រូពិនិត្យជាមួយខ្ញុំនូវរូបភាព ( image ) ដែលភ្ជាប់នៅលើផ្ទាំងសិលា ( ថ្មបាយក្រៀម ) ។ រូបភាពនេះ ធ្វើពីដីឥដ្ឋដុត លាបពណ៌ ( céramique peinte ) ។

ខ្ញុំសូមចែករូបភាពជាបីផ្នែកគឺ ៖

ទី ១ : រាជបល្ល័ង្កលំអដោយក្បាច់នាគក្បាលបី ។ ព្រះបាទស៊ីសុវត្ថិទ្រង់ប្រថាប់ក្រោមព្រះស្វេតច្ឆ័ត្រ និងទ្រង់គ្រឿងអម្ពរពស្រ្តាជាស្តេចកំពុងគ្រងរាជ្យ ។

ទី ២ : ខាងឆ្វេងបង្អស់ ( ឈរពីមុខ ) នៅខាងលើ យើងឃើញអក្សរបារាំងពីរតួ R.F. គឺជា République Française ប្រែថា **សាធារណរដ្ឋបារាំង** ។ នៅលើតួអក្សរ យើងឃើញចុងដងទង់ជាតិឆ្លាក់ជាផ្កាលីស ( lis រឺ Lys )(១) ព័ទ្ធដោយកំរងស្លឹកអូលីវីយេ ( olivier )(២) ពណ៌បៃតង ។ ភ្ជាប់នឹងដងនេះ គឺជាទង់ជាតិប្រទេសបារាំង មានពណ៌ខៀវ ស ក្រហម ។ ពលទ្មើរជើងម្នាក់ឈរធ្វើវន្ទនាការ ( ឈរទីមជើងត្រង់ខ្លួន ) ដៃស្តាំកាន់កាំភ្លើងបញ្ឈរនៅជើង ដៃឆ្វេងទាញទង់ជាតិបារាំងអោយលាតសន្ធឹងពីខាងលើ ។ នៅលើទង់មាននាគពណ៌បៃតង នៅខាងក្រោមទង់មានផ្ទាំងរាងបួនជ្រុងទ្រវែងបញ្ឈរលំអដោយក្របក្បាច់បុរាណ ។ នៅលើផ្ទាំងនេះ មានឆ្លាក់អក្សរបារាំង មានសេចក្តីថា << Traité franco-siamois du 15 Mars 1907 Battambang, Siemréap, Sisophon >> ប្រែថា សន្ធិសញ្ញាបារាំង សៀម ចុះថ្ងៃទី ១៥ មីនា ១៩០៧ (៣) ខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន ។ ខាងក្រោមអក្សរចារិកនេះ មានរូបសំណាកជនជាតិបារាំងឈ្មោះ(៤) ដែលជាកុងស៊ុលប្រចាំនៅខេត្តបាត់ដំបង នាឆ្នាំ ១៩០៣ ។ ខាងក្រោមបង្អស់ រូបក្បាលដំរីលេចចេញពីក្របសិលាចារិក ។

ទី ៣ : នារីបីនាក់មានសំលៀកបំពាក់ខុសៗគ្នា កាន់ពានមាសគ្រប់គ្នា ។ នារីទី ១ ស្លៀកពាក់របៀបរូបចំលាក់ទេពអប្សរនៅអង្គរវត្ត ហើយកាន់ពានមួយតំកល់រូបសំណាកប្រាសាទដែលខ្ញុំយល់ថា ជារូបប្រាសាទព្រះវិហារ ដោយកាលនោះព្រះវិហារស្ថិតក្នុងទឹកដីសៀមរាប ។ យើងអាចសន្និដ្ឋានថា រូបនារីទី១ នេះ ជាតំណាងខេត្តសៀមរាប រីឯនារីទាំងពីរខាងក្រោយជាតំណាងខេត្តបាត់ដំបង និងស៊ីសុផុន ព្រោះខេត្តទាំងពីរស្ថិតនៅជាប់នឹងប្រទេសថៃ ហើយសំលៀកបំពាក់ក៏ប្រហាក់ប្រហែលនឹងស្ត្រីបំរើក្នុងព្រះរាជវាំងទាំងពីរ ( កម្ពុជា ថៃ ) នាសម័យនោះ ។ នារីទី ២ កាន់ពានតំកល់ថង់ត្រាពណ៌បៃតង និងត្រាពណ៌លឿង ។ នារីទី ៣ កាន់ពានតំកល់ក្លង(៥) ពណ៌បៃតង សំរាប់ដាក់ឯកសារជាលាយលក្ខណ៍អក្សរ ។ នារីទាំងបីនាក់ធ្វើកាយវិការនាំដង្វាយទៅថ្វាយព្រះមហាក្សត្រខ្មែរ ព្រះបាទស៊ីសុវត្ថិ ។ នេះជានិមិត្តរូបនៃការថ្វាយបូរណភាពទឹកដីនៃខេត្តសៀមរាប បាត់ដំបង និងសិរីសោភ័ណ អោយមកក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រខ្មែរវិញ ។ ខាងលើផ្ទាំងសិលានេះ មានរូបនាគពណ៌បៃតង ។ ខាងក្រោមក្បាលនាគមានរូបក្បាលដំរីលេចចេញពីផ្ទាំងសិលា ។ នៅសងខាងរូបសំណាក ដែលបានពិពណ៌នារួចមកហើយនេះ មានផ្ទាំងសិលាពីរ : ផ្ទាំងខាងឆ្វេងដៃ ចារិកជាភាសាបារាំង ។ ផ្ទាំងខាងស្តាំដៃ ជាភាសាខ្មែរបកប្រែពីភាសាបារាំង ។

ដោយអក្សរថតបានមិនច្បាស់ ខ្ញុំចំលងតាមអក្សរចារិកដើម ។

---

(១)- Lis រឺ Lys ដើមរុក្ខជាតិតូចមានផ្កាពណ៌ ស និង ក្រអូប ។ ដើមវាជានិមិត្តរូបនៃភាពបរិសុទ្ធ ( pureté ) ។ ផ្កាវាជាបដិរូប ( emblème ) នៃរាជាធិបតេយ្យនៅប្រទេសបារាំង ។

(២)- ក្នុងសម័យបុរាណ ជាបដិរូបនៃពហុផលភាព ( fécondité ) និងជានិមិត្តរូបនៃសន្តិភាព និងភាពរុងរឿង ។

(៣)- កាលបរិច្ឆេទ ១៥ មិនា ១៩០៧ មិនស្របនឹងការបរិច្ឆេទចុះក្នុងសៀវភៅប្រវត្តិសាស្ត្រលោក ត្រឹង ងា និងលោក Adhemad Leclerc និងលោក តូច ឈួង

(៤)- លោក ដូរស្ទូ ដឺតុលសង់ ( តាមឯកសាររបស់លោក តូច ឈួង )

(៥)- បំពង់មានគ្របខ្ចីដាងក្អក់ ធ្វើដោយក្រឡឹង ដោយសិត ក្នុងស្ពាន់ ក្នុងភ្លុក ( វចនានុក្រមខ្មែរ )

# ១- សិលាចារឹកជាភាសាខ្មែរ



## គេជៈព្រះគុណ

ប្រតិកត្តរ៉ារបស់ក្រុងបារាំងសែស ដែលជួយទំនុកបំរុង

## ក្រុងកម្ពុជាធិប្ដី

ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិប្ដី ទ្រង់ព្រះសូត្រនៅថ្ងៃអង្គារ ១២រោជ ខែស្រាពន្ត ឆ្នាំជូត ទោស័ក្ស ចុលស័ករ៉ាជ១២០២ គឺខែអ៊ូតសិបតមគ្រិស័សរាជ ១៨៤០ ទ្រង់សោយ្យរាជសំម្បត្តនៅថ្ងៃអាទិត្យ ១០ កើត ខែពិសាក្ខ ឆ្នាំរោង ឆស័ក្ស ចុលស័ករាជ ១២៦៦. គឺ ២៤ ខែ អាវ៊ែល គ្រិសរាជ ១៩០៤ ។ ទ្រង់ទទួលខែត្រដែនបាត់ដំបង សៀមរាប និងស៊ីសោភ័ណជារបស់នគរខ្មែរពីដើម ហ្សៀក្រុងសៀមឃាត់យកនោះ ឱ្យមកជារបស់ព្រះរាជម្កុដក្រុងកម្ពុធិប្ដី ដោយ្យអំណាចសញ្ញាត្រតែរាជ្ជារបារាំងសែស់ និងរាជ្ជារសៀម ពីថ្ងៃ ២ កើត ខែផល្គុន ឆ្នាំមមី អដ្ឋស័ក្ស ចុលសករាជ ១២៦៨ គឺ ១៥ ខែ មារ្យ គ្រិសករាជ ១៩០៧

## ក្នុងរាជ្ជារ

លោក អារម៉ង់ហ្វាលីយ៉ែរ ជាប្រេស៊ីដង្គជីឡារេព្ញ៉ិក
បារាំងសែស ។

លោក ពីសុង ជាសែណាបុត្តិ ក្រសួងតាងប្រទេស
លោក មីយែសឡាក្រវ៉ា ជាសែណាបុត្តិ ក្រសួងកូឡូនី
លោក ប៉ុល បូ ជាគូវែរណើយេ៉ាល់ជីឡាំងដូស៊ីន
លោក ប៉ុល លុស ជារេស៊ីដង្គសូប៉េរីយ៉េរក្នុង
ក្រុងកម្ពុជាធិប្ដី ។

## បានធ្វើបុន្យឆ្លង

ក្នុងឆ្នាំរក សំរិទ្ធិស័ក្ស ចុលស័ករាជ ១២៧០ គ្រិស័ករាជ ១៩០៩

## ក្នុងរាជ្ជារ

លោក អងតូនីក្លូប៉ិតូវស្គី ជាគូវេរណ៍រយេណេរ៉ាល ជីឡាំងដូស៊ីន ។

## ២- សិលាចារិកតាសាឃរាំង



**GRACE**

AU PROTECTORAT de la FRANCE pour le Royaumme du Cambodge S.M. Préah Bat Samdach Préah SISOWATH.

**ROI DU CAMBODGE**

Né le Mardi 12$^{e}$ jour de la lune décroissance du mois de Srap, de l' année Chut Tossâk, de l' Ere Chollassakrach 1202 (Août-Septembre 1840), monta sur le trône le dimanche 10$^{e}$ jour de la lune croissante du mois de PISAK de l'année Rông Chhéssak de l' Ere chollassakrach 1266 (24 Avril 1904). Recevant les anciennes provinces de Battambang, Siém Réap et Sisophon détenues par le Siam et rétrocédées à la Couronne du Cambodge, en vertu du Traité Franco-siamois du 2$^{e}$ jour de la lune croissante du mois de Pholkun de l'année Momi Athassak de l'Ere Chollassakrach 1268 (15 Mars 1907)

**SOUS LE GOUVERNEMENT DE:**

M.M. Armand FALLIÈRES, Président de la République Française :
PICHON, Ministre des Affaires etrangères
MILLIÈS-LA CROIX, Ministre des Colonies;
PAUL BEAU, Gouverneur général de l'Indo-Chine,
PAUL LUCE, Résident Supérieur au Cambodge

...............

Inauguration en l'Année du Singe VOK SAMRETHISSAK de l'Ere Chollassakrach 1270 - 1909

**SOUS LE GOUVERNEMENT DE :**

M. ANTONI KLOBUKOWSKI, Gouverneur général de l'Indo-Chine.

ជារួម រូបសំណាកទាំងអស់នេះកសាងឡើងដើម្បីទុកជាអនុស្សាវរីយ៍រំលឹកពីការប្រគល់អោយមកខ្មែរវិញ នូវខេត្ត បាត់ដំបង សៀមរាប និង ស៊ីសុផុន តាមសន្ធិសញ្ញាថ្ងៃទី ២៣ ខែ មីនា ១៩០៧ ។

លោក ត្រឹង ងា[(១)] មានប្រសាសន៍ថា « គួរគប្បីជ្រាបថា ការវិលចូលមកក្នុងមាតុភូមិវិញនូវទឹកដីមួយភាគយ៉ាងសំខាន់ដែលត្រូវបាត់បង់ទៅតាំងពីសម័យ **ពញាអភ័យធិបែស បែន** ( ១៧៩៥ ) ជាជោគជ័យមួយនៃនយោបាយបារាំងនៅប្រទេសកម្ពុជា ដែលមានចារិកទុកជាអនុស្សាវរីយ៍នៅត្រង់ទិសខាងត្បូងវត្តភ្នំដូនពេញសព្វថ្ងៃ ។ ការទាមទារយកបានទឹកដីនេះមកវិញគឺធ្វើឡើងក្នុងពេលដែលលោក Armand Fallières កាន់តំណែងជាប្រធានាធិបតីនៃ

(១)-. លោក ត្រឹង ងា សាស្ត្រាចារ្យបរិញ្ញាផ្នែកវប្បធម៌ និង អរិយធម៌អាស៊ី នាយករងនៃវិជ្ជាស្ថានខ្មែរ - មន ( ១៩៧៤ )

សាធារណរដ្ឋបារាំងលោក Paul Beau ជាអគ្គទេសាភិបាលនៃឥណ្ឌូចិន និងលោក Paul Luce ជារេស៊ីដង់ស៊ុបេរីយ៍នៅប្រទេសកម្ពុជា[(១)] ។

**សំនូមពរ :** សូមលោកគ្រូ - អ្នកគ្រូ អានដោយផ្ចិតផ្ចង់នូវសិលាចារិកជាភាសាខ្មែរ និងបារាំង ។ ខ្ញុំជឿជាក់ថា ចំងល់នឹងកើតនៅលើពាក្យពេចន៍មួយចំនួន និងអក្ខរាវិរុទ្ធកាលជំនាន់នោះ ។ ដើម្បីដោះស្រាយចំងល់ ខ្ញុំសូមលោកគ្រូ - អ្នកគ្រូ សរសេរមកកាន់ទីស្នាក់ការ ស.ប.ស.ខ ។

ទង្វើខ្ញុំនេះ គឺដើម្បីអោយលោកគ្រូ - អ្នកគ្រូរៀនគិតពិចារណាជាមុនសិន ។

គណៈកម្មាធិការនាយកសប្បាយរីករាយនឹងចាំទទួលចំនាប់អារម្មណ៍ និងសំនួរផ្សេងៗពីលោកគ្រូ - អ្នកគ្រូ ។

ដោយ **យ៉ង់ ធី**

(១)- ប្រវត្តិសាស្ត្រភាគទី ២

# ការបណ្តុះបណ្តាលនៃអ្នកអប់រំ

បញ្ញត្តិមួយចំនួនដែលទាក់ទងនឹងការអប់រំសំរាប់ប្រើប្រាស់ក្នុងអគារសិក្សាគឺបុគ្គលិកសិក្សា ( les enseignants ) គ្រូបង្រៀន ( les maitres ) គ្រូបង្ហាត់ ( les instructeurs ) និងអ្នកអប់រំ ( les éducateurs ) ។ នៅទីនេះ យើងចង់សង្កត់ធ្ងន់ទៅលើ « ការអប់រំ » ( éducation ) ដែលអាចមានន័យក្តោប ទាំងការបង្ហាត់ ការបង្រៀន និងការតំរង់ទិស ដើម្បីបណ្តុះបណ្តាលអាកប្បកិរិយា និងមារយាទរបស់សិស្សានុសិស្ស អោយក្លាយទៅជាអនាគតពលរដ្ឋដែលមានសមត្ថភាពការពារ និងកសាងសង្គមជាតិ ។ ចង់សំរេចបំណងនេះ លុះត្រាតែលើកកំពស់ការបណ្តុះបណ្តាលអ្នកអប់រំ ។

ប្រទេសនីមួយៗបញ្ជាក់ច្បាស់ថា មិនមែនជាការងាយស្រួលទេក្នុងការជ្រើសរើស និងបណ្តុះបណ្តាលអ្នកអប់រំដែលមានសមត្ថភាពបច្ចេកទេស និងមានសីលធម៌វិជ្ជាជីវៈដែលគួរអោយជឿជាក់ ។ កត្តាកំណត់ក្នុងការទទួលជោគជ័យក្នុងកម្មវិធីសិក្សាគឺ ទំនួលខុសត្រូវរបស់អ្នកអប់រំ ។ ម្យ៉ាងទៀត អ្នកអប់រំត្រូវការជំនួយដ៏ខ្លាំងក្លាពីសំណាក់បុគ្គលិក កម្មករទាំងអស់នៅក្នុងអាគារសិក្សា ។ គឺអ្នកអប់រំបុគ្គលិក កម្មករទាំងអស់នោះហើយ ដែលបង្កើតបរិយាកាសសមស្រប ប្រកបដោយការយោគយល់ ការព្រមព្រៀង និងសហប្រតិបត្តិការដោយឥតប្រកាន់ពូជសាសន៍ សាសនា វប្បធម៌ ...ល... ដែលសិស្សម្នាក់ៗជាប់ជំពាក់នៅក្នុងអាគារសិក្សាទាំងឡាយ ។

គ្រូបង្រៀនណាដែលគ្រាន់តែផ្អែកលើចំណេះដឹងដ៏ទូលំទូលាយរបស់ខ្លួនទូវមុខវិជ្ជាឯកទេសណាមួយ គឺពិតជាពុំទាន់គ្រប់គ្រាន់ទេ ។ គ្រូបង្រៀនត្រូវធ្វើខ្លួនអោយទៅជាអ្នកអប់រំពិតប្រាកដ ពិសេសត្រូវមានសម្បទា និងសមត្ថភាពគ្រប់គ្រាន់ ស្តីពីចំណង់ និងសមត្ថភាពបញ្ចូលគរុកោសល្យថ្មី ការចូលចិត្តធ្វើការងារតាមក្រុម ការសិក្សា - អន្តរវិជ្ជា ចំណេះដឹងស្តីពីភាពស្វាហាប់របស់ក្រុម និងសម្បទាបង្កើតឱកាសសមស្រប ដើម្បីឆក់យកឱកាសនោះមកប្រើប្រាស់ ។ ក្រៅពីការរៀបរាប់ខាងលើនេះ អ្នកអប់រំត្រូវមានពុទ្ធិអន្តរវិជ្ជា ស្តីពីបញ្ហាពិភពលោកជាចាំបាច់ ។

ដើម្បីទទួលបានពុទ្ធអន្តរវិជ្ជា ស្តីពីបញ្ហាពិភពលោក ( Connaissances interdisciplinaires sur les problèmes mondiaux ) អ្នកអប់រំត្រូវមានពិសោធន៍ទូលំទូលាយក្នុងការអនុវត្តវិធីសកម្មនៃការអប់រំ ។ មេរៀនស្តីពីសន្តិភាព សិទ្ធិមនុស្ស ការអត់ឱន អហឹង្សា សេរីភាព ប្រជាធិបតេយ្យ... ពិតជាតំរង់ទិសដល់សិស្សានុសិស្សអោយមានសន្តិភាពពិតប្រាកដក្នុងស្មារតី ។ ហេតុនេះ មុខវិជ្ជាឯកទេសដែលខ្វះទស្សនវិជ្ជា សីលធម៌ លោកនិតិ ពិតជាមិនទាន់គ្រប់គ្រាន់ឡើយ ។ អ្នកអប់រំទាំងអស់ត្រូវផ្អែកលើកត្តាទាំងបីនេះជាមួយនឹងមុខវិជ្ជាឯកទេសរបស់ខ្លួន ដើម្បីអនុវត្តនៅក្នុងអាកប្បកិរិយាសង្គម និងអាកប្បកិរិយារបស់កុមារ យុវជន និង មនុស្សពេញវ័យ ។ ក្នុងករណីនេះ ទង្វើគេស្តាវស់បំលាស់ប្តូរអាកប្បកិរិយា និងមារយាទរបស់សិស្សានុសិស្សក្នុងដំណាក់កាលនីមួយៗជាបញ្ហាសំខាន់បំផុតនៅក្នុងវិស័យអប់រំ ។

ម្យ៉ាងទៀតអ្នកអប់រំត្រូវតែជាអ្នកច្នៃប្រឌិត និងជាអ្នកចេះបញ្ចូលរបៀបថ្មីៗនៅក្នុងការប្រើប្រាស់ឧបករណ៍អប់រំ ។ អ្នកអប់រំត្រូវចេះប្រើធនធានយ៉ាងច្រើនដែលមាននៅក្នុងសហគមន៍ដូចជា សារមន្ទីរ ពិព័រណ៍ប្រជុំសិល្បៈវត្ថុ បណ្ណាល័យ កន្លែងបង្ហាញព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងខ្សែភាពយន្តជាដើម ។

វិស្វករព្រលឹងជាតិ គឺជាអ្នកអប់រំដែលមានសីលធម៌វិជ្ជាជីវៈគ្រប់គ្រាន់ ។ ការយល់ដឹងមុខវិជ្ជាឯកទេសជ្រៅជ្រះតែរស់នៅខុសពីច្បាប់ និងទំនៀមទំលាប់សង្គម តែងស្តែងអោយឃើញបាតុភូតច្រឡើសបើសឥតវិន័យ ។

ដោយបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាន**

# មនសិការវិជ្ជាជីវៈ

មនុស្សអ្នករកស៊ីធ្វើការ ជាជំនួញជួញដូរក្ដី និងអ្នកមានមុខងារក្នុងរោងចក្រ សហគ្រាសក្ដី មន្ត្រីរាជការក្ដី ត្រូវតែមាន « ការកំនត់ទុកក្នុងចិត្ត » មួយអោយមាំ ពោលគឺ :

- បើជាអ្នករកស៊ី អ្នកធ្វើការក្នុងមុខរបរផ្ទាល់ខ្លួន ក្នុងផ្លូវជំនួញជួញដូរ ក្នុងគ្រឹះស្ថានឧស្សាហកម្ម ពាណិជ្ជកម្មក្ដី ម្នាក់ៗត្រូវតែកំណត់ទុកក្នុងចិត្តថា « អាត្មាអញរកស៊ីធ្វើការអ្វី ? » ហើយត្រូវ « តាំងចិត្ត » ជៀសិប់ក្នុងមុខការនោះអោយខ្ជាប់ខ្ជួន ដោយខិតខំតាំងស្មារតីអោយជាប់លាប់ក្នុងកិច្ចការនោះ កុំធ្វើលេងៗ រឺ « ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា » អោយសោះ ។

- បើជាអ្នកមានមុខងារ ជាមន្ត្រីរាជការ ម្នាក់ៗត្រូវតែកំណត់ទុកក្នុងចិត្តថា « អាត្មាអញមានមុខងារធ្វើការអ្វី ? មានភារកិច្ចអ្វីខ្លះដែលត្រូវធ្វើក្នុងថ្ងៃនេះ ថ្ងៃស្អែក ខានស្អែក ថ្ងៃតៗទៅមុខ ហើយត្រូវមានការចាំបាច់ដែលត្រូវធ្វើកិច្ចការណាមុន និងកិច្ចការណាក្រោយហើយជាបន្តបន្ទាប់ ដោយមិនត្រូវបណ្ដែតបណ្ដោយចាំថ្ងៃនេះ រឺចាំថ្ងៃនោះ ។ ត្រូវមានកាតព្វកិច្ចគិតគូររៀបចំអ្វីខ្លះទៀត ដទៃអំពីកិច្ចការដែលលោកប្រធាន រឺលោកនាយកដាក់អោយបំពេញ ។ មិនត្រូវមើលបំនាំចាំតែគេប្រើ គេតៀន គេបង្ខំ គេស្ដីប្រដៅ គេប្រមាន រឺ បន្ទោស ទើបស្ទុះស្ទាប្រឹងធ្វើ » នោះឡើយ ។ បានសេចក្ដីថាអ្នកមានមុខងារម្នាក់ៗតាំងពីថ្នាក់ធំ រហូតដល់ថ្នាក់តូច ត្រូវតែមាន « ចិត្ត » មាន « គំនិត » ឈ្លាសវៃ ស្រលាញ់ « ការងាររបស់ខ្លួន » ដោយខិតខំបំពេញអោយអស់សមត្ថភាព ដោយមិនចាំបាច់អោយគេប្រើ រឺ គេបង្ខំ រឺក៏ថា គេទៅត្រួតពិនិត្យ ទើបស្ទុះប្រវេប្រវាខិតខំធ្វើអោយរួចតែពីដៃ ដោយមិនគិតពីគុណភាពនោះឡើយ ។

មនុស្សមាន « **មនសិការ** » គឺជាមនុស្សអ្នកមាន « ចិត្ត » ដុះគំនិតគិតរំពៃទៅលើកិច្ចការគ្រប់បែបយ៉ាងរបស់ខ្លួន និងរបស់អ្នកដទៃជុំវិញខ្លួន ។ កន្លែងណាមិនចេះ មិនយល់ ត្រូវរៀនសូត្រស្រាវជ្រាវ រឺ សាកសួរលោកអ្នកដែលគេចេះ ។

បើម្នាក់ៗមាន « **មនសិការ** » ចំពោះការងារ តួនាទី ភារកិច្ចរបស់ខ្លួនផ្ទាល់ហើយ កិច្ចការរបស់ខ្លួននឹងចំរើនល្អគួរលាស់ដុះដាលជាលំដាប់ ។ បើគ្រប់ៗគ្នាសុទ្ធតែដុះចិត្ត លេចគំនិត ផ្ចិតផ្ចង់ ស្រលាញ់ការងាររបស់ខ្លួនដោយខិតខំបំពេញអោយពេញដៃ ពេញជើង គ្មានធ្វេសប្រហែស គ្មានប្រមាថមើលងាយការងារតាមមុខវិជ្ជាជីវៈរបស់ខ្លួន នោះការងាររបស់អង្គភាព ការងាររបស់ក្រសួង រឺ ការងាររបស់ប្រទេសជាតិ នឹងមានវឌ្ឍនភាពយ៉ាងប្រត្យក្ស ។

នៅក្នុងវិជ្ជាជីវៈ មនសិការ គឺជាថ្នាំទិព្វ រឺ ជាថាមពលសំខាន់របស់បុគ្គលម្នាក់ៗ ក្នុងការប្រកបមុខរបរអ្វីមួយ ។ ក្នុងករណីដែលគេមិនស្រលាញ់ពេញចិត្តនឹងមុខរបរ គេធ្វើការដោយញញៀតញញៀម ធ្វើលេងៗ នោះមុខរបរនោះនឹងត្រូវបរាជ័យ ខាតចុង ខាតដើមជាពុំខាន ។

រឿងមាន រឿងបាន បុណ្យសក្ដិ ឋានៈតួនាទី មុខមាត់ក្នុងសង្គមពុំមែនជា « ជោគវាសនា ព្រេងសំណាង រឺ ព្រហ្មលិខិត » សុទ្ធសាធនោះទេ ប៉ុន្តែវាជារឿង « មានចិត្ត » រឺ « គ្មានចិត្ត » ធ្វើការទាក់ទងត្រឹមត្រូវមានផែនការ រឺធ្វើការលេងៗអោយរួចតែពីដៃ ធ្វើការគស្ញូបួរផ្ដាច់ រឺធ្វើការអោយតែល្អមើល ! ធ្វើការដោយចិត្តខ្លួនឯងចង់ រឺ ធ្វើការដោយគេបង្ខំ ។ ក្នុងបច្ចុប្បន្នកាលនេះ ប្រជាជនកម្ពុជាទាំងអស់មានការចាំបាច់ត្រូវតែប្រមូល « មនសិការ » ក្នុងវិជ្ជាជីវៈ ក្នុង

មុខងាររៀងៗខ្លួន ហើយប្រឹងប្រែងគ្រប់ៗគ្នាឡើង ទើបយើងឆ្លងឧបសគ្គទាំងខាងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចបាន ។ បើពុំនោះសោតទេ យើងនឹងជួបប្រទះនូវទុក្ខវេទនាជាពុំខាន ។ វឌ្ឍនភាព សុភមង្គល សំបូរសប្បាយកើតមានទៅបាន អាស្រ័យលើកំលាំងកាយ ចិត្ត ស្មារតី និងបញ្ញាវាងវៃរបស់មនុស្សទាំងអស់ គឺជាកំលាំងនៃ « ធនធានមនុស្ស » នេះឯង ។

ព្រះរាជាណាចក្រកម្ពុជានឹងទទួលវឌ្ឍនភាព សុភមង្គល សំបូរសប្បាយរឹងប៉ឹងទៅបាន គឺពិតជាអាស្រ័យដោយ « មនសិការ » ភ្ញាក់រលឹករបស់ប្រជាជនកម្ពុជាម្នាក់ៗ និងប្រជាជនកម្ពុជាទាំងជាង ១០ លាននាក់នេះឯង ។

អ៊ុយ សុខ
នាយកសាលាបឋមសិក្សាព្រែកកំពឹស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

## សេចក្ដីកែតំរូវ

ក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ៧ ទំព័រ ២ កាលបរិច្ឆេទនៃការចុះហត្ថលេខា របស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ មានដូចតទៅ៖

- រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

**សូមមេត្តាកែតំរូវវិញថា ៖**

- រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៨

ភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៨

ប្រធាន ស.ប.ស.ខ

**យ៉ង់ ធី**

# សាវតារ អរិយក្សត្រ

បើលោកអ្នកឈរពីមុខព្រះបរមរាជវាំង ហើយមើលចំទៅទិសខាងកើត លោកអ្នកនឹងឃើញដើមតគិច្រេងច្រាង នោះហើយវត្ត **អរិយក្សត្រ** នៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល ។ **អរិយក្សត្រ** គឺនៅខាងកើតដងទន្លេមេគង្គ មានចំងាយប្រមាណ ៤ គីឡូម៉ែត ។

ចុះអរិយក្សត្រមានសាវតារដូចម្តេច ? មានឈ្មោះពីត្រឹមណាមក ក្នុងរាជ្យស្តេចអង្គណា ?

អរិយក្សត្រ នេះតាមព្រះរាជពង្សាវតារ មិនមែនឈ្មោះថា អរិយក្សត្រ ដូច្នេះទេ ពីដើមគេហៅតាមនាមនៃវត្តមួយដែលមានឈ្មោះថា « **វត្តស្រីក្សត្រ** » តែយូរក្រោយមក ក្លាយទៅជា « **វត្តអរិយក្សត្រ** » ។

កាលពីឆ្នាំរោង ទោស័ក ព.ស ២១៤៩ គ.ស ១៦០៤ នៅវេលាថ្ងៃរសៀល មានភ្លៀងព្រៃឆេះសន្ធោសន្ធៅ អ្នកស្រុកពន្លត់មិនឈ្នះ ។ ពេលនោះ មានផ្កាភ្លើងអណ្តែតតាមអាកាសមកធ្លាក់លើដំបូលព្រះបរមរាជវាំងដំណាក់នៃព្រះបាទ **ស្រីសុរិយោពណ៌** នៅកោះស្លាកែត បណ្តាលអោយឆេះព្រះរាជដំនាក់ ទាហានពន្លត់មិនឈ្នះសោះ លុះព្រះអគ្គិស្ងប់ហើយ ព្រះបាទ **ស្រីសុរិយោពណ៌** ទ្រង់ប្រជុំសេនាបតី មន្ត្រីទាំងពួងថា ទីកោះស្លាកែតនេះជិតមាត់ទន្លេល្អហើយ តែទីនេះគ្មានជ័យភូមិទេ បើខាងត្រើយល្វាឯមឯណោះ ទើបជាទីប្រកបដោយជ័យភូមិ យើងគួរតែទៅកសាងព្រះបរមរាជវាំង តាំងបន្ទាយនៅឯល្វាឯមវិញ ។

លុះព្រះរាជាទ្រង់ប្រជុំរួច នាម៉ឺនសព្វមុខមន្ត្រីយល់ស្របតាមព្រះរាជយោបល់ ហើយព្រះ **ស្រីសុរិយោពណ៌** ទ្រង់មានព្រះរាជបញ្ជាសេនាបតី អោយផ្ញើសំបុត្រទៅចៅហ្វាយស្រុកគ្រប់ខេត្ត អោយកេណ្ឌរាស្ត្រមកសាងព្រះបរមរាជវាំងនៅត្រើយខាងល្វាឯម ។ ការកសាងព្រះបរមរាជវាំងនៅក្រោមការត្រួតត្រារបស់ឧកញ៉ាក្រឡាហោម **កែវ** អស់ថេរវេលា ៨ ខែ ទើបហើយស្រេច ។

សាងព្រះរាជវាំងហើយស្រេច ឧកញ៉ាក្រឡាហោម **កែវ** ឡើងទៅក្រាបថ្វាយបង្គំទូលថ្វាយពតិមានអំពីការកសាងអោយព្រះអង្គជ្រាប ។ ទើបនៅថ្ងៃ ១០ ខែបុស្ស ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២១៤៩ គ.ស. ១៦០៥ វេលាម៉ោង ៩ ព្រឹក ជាថ្ងៃប្រកបដោយនក្ខត្តឫក្ស ព្រះបាទ **ស្រីសុរិយោពណ៌** ស្តេចទ្រង់ព្រះរាជដំណើរចេញពីព្រះបរមរាជវាំងកោះស្លាកែតមួយអន្លើ ដោយព្រះមហេសី ស្រីស្នំក្រមការ ព្រះរាជបុត្រ សេនាបតី មន្ត្រីគ្រប់ក្រុម គង់ជិះនាវាឆ្លងទៅត្រើយល្វាឯម ស្តេចឡើងគង់ក្នុងព្រះបរមរាជវាំងថ្មី ហើយទ្រង់បញ្ញតិនាមថា ព្រះបរមរាជវាំង « **ល្វាឯម** » ។

ព្រះបាទ **ស្រីសុរិយោពណ៌** ទ្រង់គង់នៅព្រះបរមរាជវាំងល្វាឯម បានប្រកបដោយសេចក្តីក្សេមក្សាន្តដល់ឆ្នាំ ជូត ទោស័ក ព.ស ២៤៥៦ គ.ស. ១៦១៣ សម្តេចព្រះ **ភគវតី** ជារាមថ្ងៃ ទ្រង់មានព្រះអាពាធជាទំងន់ ព្រះអង្គទ្រង់សោយទីវង្គតក្នុងព្រះជន្មាយុ ២៨ ព្រះវស្សា ព្រះរាជាគំកល់ព្រះសពតាមព្រះរាជប្រពៃណី ។ ក្រោយមកទៀត សម្តេច **ព្រះនេតិក្សត្រ** ទ្រង់សោយទីវង្គត ក្នុងព្រះជន្មាយុ ៦៣ ព្រះវស្សា ព្រះបាទ **សុរិយោពណ៌** ទ្រង់រៀបចំចាត់ចែងអោយធ្វើព្រះមេរុយ៉ាងមធ្យម ទុកសំរាប់ធ្វើបុណ្យថ្វាយព្រះភ្លើងនៃព្រះសពទាំងពីរព្រះអង្គ ។

លុះចប់កម្មវិធីបុណ្យថ្វាយព្រះភ្លើងរួចហើយ ព្រះបាទសម្តេចព្រះ **ស្រីសុរិយោពណ៌** ទ្រង់បញ្ជាអោយកសាងវត្តមួយនៅត្រង់ព្រះមេរុ ហើយទ្រង់ដាក់បញ្ញតិថា « វត្តស្រីក្សត្រ » ។

កាលបើមានវត្តអារាម មានព្រះសង្ឃមកគង់នៅចាំព្រះវស្សា ឧបាសក ឧបាសិកា ក៏មកតាំងលំនៅគេហដ្ឋានជាភូមិ ជាឃុំ រហូតមកដល់សព្វថ្ងៃ តែនាមដើម « **វត្តព្រះស្រីក្សេត្រ** » មិនទៅគង់វង្សតាមនាមដើមទេ អ្នកភូមិហៅក្លាយមកថា « **វត្តអរីយក្សេត្រ** » ឯភូមិ ឃុំ ក៏ហៅក្លាយមកថា « **អរីយក្សេត្រ** » រហូតមកដល់សព្វថ្ងៃនេះ ។

**ជុំ ការណាល់**

ដកស្រង់ចេញពីកាសែតរស្មីកម្ពុជា

# បរិស្ថានសង្គមវប្បធម៌កម្ពុជា

## ១- បរិស្ថានធម្មជាតិកម្ពុជា

ប្រជាជនខ្មែរយើង មានភ័ព្វសំណាងណាស់ដែលបានកកើតឡើងនៅលើភូមិសាស្ត្រមួយមានអំណោយផលពីធម្មជាតិនូវភោគទ្រព្យធម្មជាតិដ៏សំបូរបែបទាំងលើដី ក្នុងដី លើទឹក និងក្នុងទឹក...។ លើសពីនេះទៀត ក្រៅពីធនធានទឹកសាប ខ្មែរយើងមានដែនសមុទ្រដែលជាច្រកទ្វារសេដ្ឋកិច្ចមួយយ៉ាងសំខាន់ ផ្សារភ្ជាប់ខ្សែគមនាគមន៍តាមនាវាក្នុងក្របខ័ណ្ឌសកលលោកទាំងមូល ។

ដោយទីតាំងភូមិសាស្ត្រ និងធាតុអាកាសអំណោយផលនេះផងដែរ ខ្មែរយើងបានចៀសផុតបាតុភូតធម្មជាតិនានាដូចជាការរញ្ជួយដី ខ្យល់ព្យុះសង្ឃរា ភ្នំភ្លើងជាដើម ។ ទោះបីប៉ុន្មានឆ្នាំចុងក្រោយនេះ យើងជួបប្រទះទឹកជំនន់ គ្រោះរាំងស្ងួតខ្លះៗក៏ដោយ តែបើប្រៀបប្រទេសមួយចំនួនលើសកលលោក ជាគ្រោះធម្មជាតិតូចតាចប៉ុណ្ណោះដែលបណ្ដាលមកពីការខូចខាតបរិស្ថានធម្មជាតិ ។ ការបញ្ចៀសបានរាល់បាតុភូតធំៗ វាបានអំណោយផលយ៉ាងខ្លាំងដល់ការធានាសុវត្ថិភាព និងជីវភាពសង្គម ។

សម្បត្តិធម្មជាតិយ៉ាងសំបូរបែបនេះគួរណាស់តែប្រជាជនយើងគ្រប់រូបមានជីវភាពធូរធារ ដូចប្រជាជននានានៅអារ្យប្រទេសទើបត្រឹមត្រូវ ។ តែគួរអោយស្ដាយ ដោយសារសង្គ្រាមបង្ហូរឈាមជាង ២ ទសវត្សរ៍ចុងក្រោយនេះខ្មែរយើងគ្រប់រូបមិនបានទទួលនូវភោគផលសមស្របពីសម្បត្តិធម្មជាតិយ៉ាងសំបូរបែបទាំងនោះឡើយ ព្រោះជីវភាពប្រជាជនយើងចំនួនច្រើនតែក្រីក្រ ជួបគ្រោះទុរ្ភិក្ស អសន្តិសុខ និងមានរោគា... ។

## ២- បរិស្ថានវប្បធម៌កម្ពុជាពីអតីតកាល

ប្រវត្តិសាស្ត្របានចារបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនខ្មែរយើងជាជាតិសាសន៍មួយដែលមានវប្បធម៌ អារ្យធម៌របស់ខ្លួនយ៉ាងពិតប្រាកដ ។ ទោះបីសព្វថ្ងៃ ទឹកដីយើងបានរួមតូច តែវាជាមោទនភាពមួយរបស់ជាតិយើង ដែលនៅមានឈ្មោះពេញលក្ខណៈជាប្រជាជាតិមួយក្នុងផែនទីសកលលោក ហើយយើងមានរចនាសម្ព័ន្ធគ្រប់គ្រាន់ ដឹកនាំពេញលក្ខណៈច្បាប់ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ។

បុព្វបុរសយើង ទោះបីតាមប្រវត្តិសាស្ត្រនៅសម័យកាលខ្លះបានឈ្មោះដណ្ដើមអំណាចគ្នា តែក៏មានសម័យតស៊ូយ៉ាងប្អូរផ្ដាច់ក្នុងការធ្វើសង្គ្រាមប្រឆាំងសត្រូវឈ្លានពានគ្រប់ទិសទី ។

ក្នុងដំណើរប្រវត្តិសាស្ត្រដ៏យូរលង់នេះ មនុស្សខ្មែរយើងបានកសាងឡើងនូវកេរដំណែលប្រវត្តិសាស្ត្រ ដែលជាតំលៃវប្បធម៌ និងអារ្យធម៌លើគ្រប់ផ្នែក គ្រប់វិស័យ ជាអត្តសញ្ញាណជាតិ មិនអាចមានខ្មាំងសត្រូវណាបដិសេធបានឡើយ ។ ក្នុងនោះយើងមានភាសាសំរាប់ទំនាក់ទំនងប្រជាជាតិ យើងមានអក្សរសាស្ត្រ និងស្នាដៃអក្សរសិល្ប៍ជាច្រើនដែលឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រជាតិ ពីចរិតខ្មែរ ពីសង្គមខ្មែរ ពីវប្បធម៌ ចរិយាធម៌ និងសីលធម៌ខ្មែរ ។ ប្រវត្តិសាស្ត្រជាក់ស្ដែងនីមួយៗ គឺសំរាប់អ្នកជំនាន់ក្រោយសិក្សាបង្រៀនបន្ថែម ។

និយាយអំពីទំនៀមទំលាប់ ប្រពៃណីខ្មែរយើងក៏មានពហុសណ្ឋានដោយសរបញ្ចាក់ថា យើងមានវប្បធម៌មួយដ៏រុងរឿងពីអតីតកាល ។ ប្រាង្គប្រាសាទនានា សំណង់វប្បធម៌ដែលមាននៅទូទាំងប្រទេស បានឆ្លុះបញ្ចាំងនូវទេពកោសល្យភាពប៉ិនប្រសប់ ការឧស្សាហ៍ព្យាយាម សេចក្តីអំណត់យ៉ាងខ្ពស់ឥតពីរ ដែលវីរបុរសយើងស្ថាបនាឡើងជាមូលដ្ឋានប្រវត្តិសាស្ត្រដល់ខ្មែរជំនាន់ក្រោយ ។

សាសនា ទោះបីមានការផ្លាស់ប្តូរនៅសម័យកាលមុន និងក្រោយអង្គរ ពីព្រាហ្មណ៍សាសនា មកព្រះពុទ្ធសាសនា តែវាបានសំដែងអោយអ្នកសិក្សាប្រវត្តិសាស្ត្រយល់ថា ខ្មែរយើងមានសាសនាជាគោលសំរាប់រៀបចំផ្សេងៗ ជាលក្ខណៈជាតិគ្រប់សម័យកាល ។

ក្រៅពីនោះយើងមានរចនាសម្ព័ន្ធសង្គមសំរាប់គ្រប់គ្រងតាមលំដាប់ថ្នាក់ មានគោរម្យងារយ៉ាងច្បាស់លាស់ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស ។ តាមរយៈនៃរចនាសម្ព័ន្ធនេះ យើងបានដឹងថា អាណាចក្រខ្មែរយើងនាសម័យកាលមុនមានភូមិសាស្ត្រយ៉ាងធំទូលាយ ហើយអាណាខេត្តរបស់យើងមួយចំនួនបានត្រូវក្លាយជាទឹកដីបរទេសក្បែរខាង ។

សរុបខ្លីមក បរិស្ថានសង្គមវប្បធម៌ខ្មែរពីអតីតកាលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ខ្មែរយើងជាប្រជាជាតិមួយដែលមានប្រវត្តិសាស្ត្ររបស់ខ្លួនយ៉ាងពិតប្រាកដហើយ ដោយសារកំលាំងនៃវប្បធម៌ទាំងនោះ ត្រូវបានមគ្គុទ្ទេសក៍នយោបាយយកធ្វើជាសក្ខីកម្ម និងជាមូលដ្ឋានគ្រឹះសំរាប់ការពារថែរក្សាបូរណភាពដែនដីនៅពេលជាលំដាប់ក្រោយមករហូតដល់សព្វថ្ងៃនេះ ។

ដោយសារបរិស្ថានសង្គមវប្បធម៌ពីអតីតកាលដែរនោះ អ្នកជំនាន់ក្រោយបានទទួលបន្ត និងពង្រីងបន្ថែម ញ៉ាំងអោយបរិស្ថានសង្គមវប្បធម៌កាន់តែល្អផូរផង់ឡើង ។

## ៣- បរិស្ថានវប្បធម៌កម្ពុជាក្នុងសភាពការណ៍បច្ចុប្បន្ន

ជាងពីរទសវត្សរ៍ចុងក្រោយនេះ ដោយរាប់ពីក្រោយរដ្ឋប្រហារ ឆ្នាំ ១៩៧០ សង្គ្រាមបានឆាបឆេះនៅលើទឹកដីដ៏បវររបស់យើង ហើយផ្សែងនៃភ្លើងសង្គ្រាមវិនាសកម្មនេះ មិនទាន់បានរលត់ទាំងស្រុងនៅឡើយទេ ។ ដូច្នេះ សន្តិភាពពិតប្រាកដមិនទាន់ធានាទាំងស្រុងនៅលើទឹកដីដ៏ពិសិដ្ឋរបស់យើងនៅឡើយ ។

ដោយសារផលវិបាកនៃសង្គ្រាមនេះ ទោះបីរាជរដ្ឋាភិបាលសព្វថ្ងៃខិតខំស្តារគ្រប់វិស័យយ៉ាងណាក៏ដោយ ក៏កំរិតនៃស្ថិរភាពទាំងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសតិអារម្មណ៍ មិនទាន់មានដំណើរវិវត្តខ្ពស់ល្អទៅតាមសំណូមពរនៅឡើយ ។

ទន្ទឹមនឹងការថយចុះនោះ ជាទិដ្ឋភាពរួមបរិស្ថានសង្គមវប្បធម៌សព្វថ្ងៃ ត្រូវបានវប្បធម៌បរទេសបន្ទំខ្លួនជ្រៀតចូលមកជំនួស ដែលជាគ្រោះថ្នាក់មួយដល់អត្តសញ្ញាណវប្បធម៌ជាតិ បើយើងសម័យនេះមិនមានវិធានការរាំងខ្ទប់អោយបានខ្ជាំងក្លា និងប្រកបដោយសុវត្ថិភាពទេនោះ ។

ជាក់ស្តែងខ្មែរយើងមានសិល្បៈប្រជាជនយ៉ាងច្រើនដូចជា អាយ៉ៃ យីកេ ល្ខោនបាសាក់ ល្ខោននិយាយ ចាប៉ីដងវែង ភាពយន្ត វីដេអូ ... ។ ក្រៅពីនេះ ខ្មែរយើងមានសិល្បៈចំរៀង របាំ តន្ត្រី ល្បែងប្រជាប្រិយពិសេសរបស់ខ្លួនដ៏សំបូរបែប តាំងពីបុរមបុរាណមកផងដែរ ។

តែជាអកុសលសព្វថ្ងៃនេះ សិល្បៈប្រជាជនមួយចំនួនដូចជា អាយ៉ៃ យីកេ ល្ខោនបាសាក់ ល្ខោនខោលល្ខោននិយាយ ចាប៉ីដងវែង ភាពយន្ត វីដេអូ និងល្បែងប្រជាប្រិយមួយចំនួន ត្រូវបានឈានទៅរកការសាបសូន្យជាបណ្តើរៗ

ទាំងមូលដ្ឋានសំភារៈ និងធនធានមនុស្ស ។ ទន្ទឹមនោះដែរ បេតិកភ័ណ្ឌវប្បធម៌ជាតិ រួមមានវត្ថុបុរាណ និងរូបសំណាក នៃសំណង់វប្បធម៌ខ្លះ ត្រូវបានពួកជនទុច្ចរិតលួចគាស់ កកាយយកទៅលក់អោយឈ្មួញបរទេសដោយខ្វះមនសិការជាតិ ។

ប្រាកដណាស់ វិទ្យាសាស្ត្របានជំរុញអោយសង្គមជឿនលឿនទៅមុខ តែផ្នែកខ្លះនៃវិទ្យាសាស្ត្រ វាក៏ជាជាតិពិសពុលនៃសភាពការណ៍សង្គមកម្ពុជា នាពេលបច្ចុប្បន្ននេះដែរ នេះមកពីចំណេះដឹងសតិអារម្មណ៍ខ្មែរយើងខ្លះ វិវត្តទៅការរីកចំរើននៃវិទ្យាសាស្ត្រទាំងនោះ ។

ជាក់ស្តែង ភាពយន្តវីដេអូខ្មែរត្រូវសាបសូន្យ ហើយបានជំនួសវិញដោយភាពយន្តបរទេស មានភាពយន្តថៃ ហុងកុង អាមេរិកជាដើម ។ ជាការពិត ភាពយន្តមានចរិតអប់រំដើម្បីឆ្លុះបញ្ចាំងអំពីជីវភាពសង្គម ។ តែដល់កំរិតយល់ដឹងទាបមានយុវជនខ្មែរយើងខ្លះ បានចំលងយកល្បិចខិលខូចនៃខ្សែរឿងនោះមកប្រព្រឹត្តអំពើអបាយមុខក្នុងសង្គមទៅវិញ ហើយគ្រោះថ្នាក់បំផុតគឺ វីដេអូប្រភេទអាសអាភាស ។

អំពើចោរកម្ម ពេស្យាចារ អំពើពុករលួយ ល្បែងស៊ីសង ភាពអានាធិបតេយ្យ ការបំផ្លាញធនធានធម្មជាតិ ការឃុបឃិតគ្នាលួចសម្បត្តិរដ្ឋ និងភេរវកម្មកាប់សំលាប់មនុស្ស ... សុទ្ធតែជាភាសាអសកម្ម ដែលមានឥទ្ធិពលអាក្រក់ដល់បរិស្ថានសង្គមវប្បធម៌នាពេលបច្ចុប្បន្ន ។

## សន្និដ្ឋាន

ភារកិច្ចនៃកិច្ចការពារ និងការលើកស្ទួយបរិស្ថានសង្គមវប្បធម៌កម្ពុជា ជាភារកិច្ចរួមរបស់មនុស្សខ្មែរគ្រប់រូប វាមិនមែនជាភារកិច្ចដោយឡែកតែស្ថាប័នជំនាញណាមួយឡើយ ។ ជាសញ្ញាគ្រោះថ្នាក់មួយសំរាប់សង្គមកម្ពុជានាពេលអនាគត បើសង្គ្រាមនៅតែបន្ត និងប្រសិនបើបរិស្ថានសង្គមវប្បធម៌ជាតិនៅតែត្រូវបានញាំញីដោយភាពអសកម្ម រីការទទួលយកវប្បធម៌បរទេសមកជំនួសវិញនោះ ។

វប្បធម៌ជាផ្នែកមួយនៃបរិស្ថានសង្គមវប្បធម៌ ។ បើវប្បធម៌រលាយ ជាតិនឹងរលត់ ។ កិច្ចការពារបរិស្ថានវប្បធម៌គឺជាភារកិច្ចរបស់យើងទាំងអស់គ្នា ដើម្បីរួមចំណែកការពារជាតិមាតុភូមិអោយស្ថិតស្ថេរគង់វង្សជាអមតៈ ។

ដកស្រង់ចេញពីកាសែតរស្មីកម្ពុជា

> គប្បីអោយសិស្សធ្វើសកម្មភាពច្រើន ជួបប្រាស្រ័យច្រើន
> ជាមួយវត្ថុ ទើបឆាប់មានប្រត្យក្សារម្មណ៍គ្រប់គ្រាន់

# តើត្រូវអប់រំពលរដ្ឋវិជ្ជាដល់សិស្សានុសិស្ស នៅមធ្យមសិក្សាដោយរបៀបណា ?

## I- ការអប់រំជាអ្វី ?

ការអប់រំមានន័យថា ការធ្វើអោយរីកចំរើនបុគ្គលិកលក្ខណៈរបស់សិស្ស ។ បុគ្គលិកលក្ខណៈផ្សំឡើងដោយពុទ្ធិ (Cognitive) គំនិត យល់ដឹង បទពិសោធន៍ បំនិន ... ទឹកចិត្ត សញ្ចេតនា Feeling or emotion ( ស្រលាញ់ ចូលចិត្ត ស្អប់ ឈឺចាប់ ទុក្ខព្រួយ សប្បាយរីករាយ ... ) និងអាកប្បកិរិយា Behaviour ( ទឹកមុខ កាយវិការ ... ) ដែលធ្វើអោយបុគ្គលម្នាក់ប្លែកពីបុគ្គលម្នាក់ទៀតនៅពេលដែលគេសំរបសំរួល រឺឆ្លើយតបទៅនឹងបរិស្ថាន ( មជ្ឈដ្ឋានជុំវិញ ស្ថានការណ៍ក្នុងជីវិតប្រចាំថ្ងៃរបស់គេ ... ) ។




មានផ្នែកខ្លះនៃបុគ្គលិកលក្ខណៈមិនអាចប្រែប្រួលទេ (កត្តាជីវៈ រឺ កត្តាសេនេទិច ឧទាហរណ៍ ក្រូម៉ូសូម ...) ។ ប៉ុន្តែ មានផ្នែកខ្លះអាចប្រែប្រួលបាន ជាពិសេស តាមរយៈបទពិសោធន៍ និងការប៉ះទង្គិចផ្លូវចិត្តដែលបណ្ដាលមកពីការប្រាស្រ័យទាក់ទងជាមួយបរិស្ថាន ( បានឃើញ បានលឺ បានស្ដាប់ បានធ្វើ បានទទួលផលល្អ រឺ ទទួលផលជាការឈឺចាប់ ... ) ។ ឧទាហរណ៍ : ពីមុនស្រលាញ់ចូលចិត្តរាប់រកគ្នា ប៉ុន្តែបន្ទាប់ពីបានរស់នៅជាមួយគ្នា មានការប្រាស្រ័យទាក់ទងគ្នាមិនល្អ ដែលប៉ះពាល់ដល់ផ្លូវចិត្តមក ក៏បែរជាស្អប់គ្នាទៅវិញ ។

លោកគ្រូ អ្នកគ្រូ ត្រូវអប់រំពុទ្ធិ និងការគិតអោយសិស្សយល់ដឹង រួចជ្រួតជ្រាបទៅក្នុងចិត្ត ហើយអោយសិស្សធ្វើអំពើជាក់ស្ដែងដែលអាចមើលឃើញបានតាមរយៈកាយវិការ ទឹកមុខ និយាយអោយចំគឺអាកប្បកិរិយា ។ ដូច្នេះ លោកគ្រូ អ្នកគ្រូត្រូវអប់រំសិស្សលើចំនុចបីយ៉ាងគឺ ពុទ្ធិ ចិត្ត អាកប្បកិរិយា ។ ការអប់រំអាចបានលទ្ធផលល្អ លុះត្រាតែសិស្សធ្វើសកម្មភាពជាមួយសិស្សដទៃ ទៅតាមផែនការរបស់លោកគ្រូ អ្នកគ្រូ ។ លោកគ្រូ អ្នកគ្រូ ត្រូវមានបំនិនជាអ្នកជួយសំរួល និងធ្វើផែនការ ។

## II- លោកគ្រូ អ្នកគ្រូ ត្រូវមានតួនាទីអ្វីខ្លះក្នុងពេលបង្រៀនពលរដ្ឋវិជ្ជា ?

### ១- សកម្មភាព

**ក - មុនដំបូង :** លោកគ្រូ អ្នកគ្រូជាអ្នកនាំសិស្សអោយមានទឹកចិត្តចង់រៀន ចង់ដឹងខ្លឹមសារមេរៀនតាមរយៈចោទជាសំនួរងាយៗ ដែលទាក់ទងនឹងឧទាហរណ៍ជាក់ស្តែង ដែលសិស្សធ្លាប់ស្គាល់ជាស្រេចនៅក្នុងសហគមន៍របស់គេ ។ ឧទាហរណ៍ : ប្អូនទាយមើលថ្ងៃនេះយើងរៀនអំពីអ្វី ? រី រូបភាពនេះស្តីអំពីអ្វី តើវាមានន័យយ៉ាងណាចំពោះប្អូន ? តើវាមានទ្រង់ទ្រាយដូចអ្វីខ្លះ ? ។ ល ។

**ខ - ពិភាក្សា :** លោកគ្រូ អ្នកគ្រូ ណែនាំសិស្សអោយបញ្ចេញមតិរបស់ខ្លួន ស្តាប់មតិរបស់អ្នកដទៃ ធ្វើទំនាក់ទំនងជាមួយអ្នកដទៃ ប្តូរយោបល់ជាមួយអ្នកដទៃ ។ លោកគ្រូ អ្នកគ្រូមានតួនាទីជាអ្នកផ្តួចផ្តើម គឺធ្វើយ៉ាងណាអោយសកម្មភាពសិស្សកើតមានឡើង ។ លោកគ្រូ អ្នកគ្រូជាអ្នកលើកទឹកចិត្តសិស្ស មិនវាយតំលៃសិស្សថា មានយោបល់ខុសទេ ព្រោះនេះជាការអប់រំសិស្សអោយក្លាហានក្នុងការបញ្ចេញមតិដើម្បីអោយដឹងថាអ្វីខ្លះដែលសិស្សចេះហើយ អ្វីខ្លះដែលសិស្សមិនទាន់ចេះ ។

លោកគ្រូ អ្នកគ្រូជាអ្នកកំនត់ពេល បានន័យថា ប្រាប់ដល់សិស្សអំពីរយៈពេលត្រូវពិភាក្សា និងបញ្ឈប់សកម្មភាពនៅពេលត្រូវចប់ ។ ឧទាហរណ៍ : បន្ទាប់ពីផ្តល់សំនួរដល់សិស្ស លោកគ្រូ អ្នកគ្រូប្រាប់អោយសិស្សធ្វើការជាមួយដៃគូ ដើម្បីប្តូរយោបល់គ្នាក្នុងរយៈប្រាំនាទី ។

**ហេតុអ្វីក៏សិស្សត្រូវធ្វើសកម្មភាពជាមុន បើលោកគ្រូ អ្នកគ្រូមិនទាន់ធ្វើបទឧទ្ទេសអោយសិស្សស្តាប់ផង ?**

ដូចលោកគ្រូ អ្នកគ្រូដឹងស្រាប់ហើយថា ការអប់រំទាមទារអោយសិស្សបញ្ចេញចំនេះដឹងរបស់ខ្លួន ដែលបានយល់ដឹងពីក្នុងសហគមន៍ បញ្ចេញមតិរបស់ខ្លួន តើមតិនោះដូចគ្នា រឺខុសគ្នាពីអ្នកដទៃ តើជាក់ស្តែងរឺយ៉ាងណា ? ដូច្នេះតាមរយៈសកម្មភាពរបស់សិស្សនេះ លោកគ្រូ អ្នកគ្រូអាចប្រើវិធីបង្រៀនអនុមានរួម ដើម្បីនាំសិស្សទៅដល់បញ្ញត្តិអរូបិយបាន ( ពីព្រោះសិស្សរៀនចេះ លុះត្រាតែសិស្សនោះមានបទពិសោធន៍ រឺទទួលបានបទពិសោធន៍ពីសកម្មភាពរបស់ខ្លួន )។ ឧទាហរណ៍ : ស្នេហាមាតុភូមិជាអ្វី ? សន្តិភាពជាអ្វី ?

1 - លោកគ្រូ អ្នកគ្រូត្រូវផ្តល់ចំនេះដឹងដល់សិស្ស តាមរយៈការផ្តល់ឱកាសអោយសិស្សធ្វើសកម្មភាពដូចជា ស្តាប់សិស្សដទៃទៀត បញ្ចេញមតិរបស់ខ្លួន ប្រៀបធៀបចំនេះដឹងរបស់ខ្លួនជាមួយនឹងមិត្តរួមថ្នាក់ ។

2 - បន្ទាប់មកសិស្សនឹងត្រូវបានអប់រំផ្លូវចិត្ត ។

ឧទាហរណ៍ : សន្តិភាពនេះមានន័យយ៉ាងណាសំរាប់ខ្លួនអ្នក ? អ្នកទទួលបានផលអ្វីខ្លះ ប្រសិនបើភូមិ ស្រុក ប្រទេស រឺ ពិភពលោកយើងនេះមានសន្តិភាព ? អ្នកចូលចិត្តសន្តិភាពដែររឺទេ ? ពីព្រោះអ្វី ?

៣ - បន្ទាប់មកសិស្សត្រូវបានអប់រំផ្នែកអាកប្បកិរិយា ។

ឧទាហរណ៍ : តើប្អូនត្រូវធ្វើអ្វីខ្លះក្នុងនាមជាសិស្ស ជាពលរដ្ឋល្អ ជាមនុស្សស្រលាញ់សន្តិភាព? តាមរយៈសំនួរទាំងនេះ សិស្សអាចស្គាល់អំពីមតិរបស់ខ្លួន មតិរបស់អ្នកដទៃ និងអ្វីៗដែលជាសភាពពិតជាក់ស្តែង ។ សូមបញ្ជាក់ថា នៅដំនាក់កាលនេះ ពុំមានការវាយតំលៃថា ប្អូននេះខុស ប្អូននេះឆ្លើយត្រូវជាងគេទេ ព្រោះនេះជាការអប់រំអោយសិស្សក្លាហានក្នុងការបញ្ចេញមតិ និងអោយសិស្សវាយ

តំលៃលើខ្លួនឯង ហើយការអប់រំតែងតែចាប់ផ្ដើមពីត្រូវខ្លះ ខុសខ្លះបែបនេះជាធម្មតា ។ ពេលខ្លះការខុសអាចចាត់ទុកជាបទពិសោធន៍សំរាប់អោយសិស្សប្រឹងប្រែងទៅរកចំនុចដែលត្រូវ ពីព្រោះការអប់រំតិធ្វើយ៉ាងណាអោយសិស្សបំពេញសកម្មភាពទទួលបានបទពិសោធន៍ដោយខ្លួនឯង ។ អប់រំមិនមែនទៅស្ទៀមអង្គុយចាំស្តាប់តាមតែមតិរបស់លោកគ្រូ អ្នកគ្រូនោះទេ ។

នៅក្នុងដំណាក់កាលនេះ លោកគ្រូ អ្នកគ្រូត្រូវប្រើសំនួរសមស្របទៅតាមសិស្សរបស់ខ្លួន ដើម្បីដឹកនាំសិស្សអោយធ្វើសកម្មភាព ។ សំនួរសមស្របជាមធ្យោបាយដ៏សំខាន់បំផុត ព្រោះថា បើសំនួរខ្ពស់ពេក រឺ ទាបពេក នោះសិស្សមិនរើសយកមកគិតឡើយ ដូច្នេះ ពុំមានអត្ថន័យធ្វើអោយសិស្សរីកចំរើនឡើយ ។ លោកគ្រូ អ្នកគ្រូអាចបង្កើតសំនួរថ្មីទៅតាមសភាពជាក់ស្តែងរបស់សិស្សខ្លួន ។ ក្រុមអ្នកនិពន្ធដែលជូនសំនួរនេះ គ្រាន់តែជាឧទាហរណ៍ទូទៅសំរាប់សិស្សទូទាំងប្រទេសតែប៉ុណ្ណោះ ។ តាមរយៈសកម្មភាពពិភាក្សាលើសំនួរ លោកគ្រូ អ្នកគ្រូទទួលចំលើយ រួចប្រើវិធីអនុមានរួមមកចូលបញ្ញត្តិតំលៃ ។

**២- បញ្ញត្តិតំលៃ :** នៅតំណាក់កាលនេះ តួនាទីលោកគ្រូ អ្នកគ្រូជាអ្នកសំរបសំរួល ( ការទូត ) ពោលគឺធ្វើយ៉ាងណាដើម្បីយកខ្លឹមសារត្រឹមត្រូវមួយមកធ្វើឧទ្ទេសយ៉ាងខ្លីជូនដល់សិស្ស ដោយពុំត្រូវធ្វើយ៉ាងណាដែលបង្ហាញថាមតិរបស់សិស្សវាអន់នោះទេ ។ បញ្ញត្តិតំលៃដែលជូនពេលនេះមានលក្ខណៈត្រឹមត្រូវ ដែលលោកគ្រូ អ្នកគ្រូត្រូវសរសេរលើក្ដារខៀន រួចចោទជាសំនួរ រឺ ណែនាំសិស្សអោយវិភាគទៅលើខ្លឹមសារនោះទាំងផ្នែកចំនេះដឹងទឹកចិត្ត និងអាកប្បកិរិយារបស់ខ្លួន ។ តួនាទីរបស់លោកគ្រូ អ្នកគ្រូជាអ្នកបំភ្លឺអោយឃើញច្បាស់ថា នេះជាខ្លឹមសារដែលមានលក្ខណៈត្រឹមត្រូវ ។

**៣- ការអនុវត្ត :** នៅដំណាក់កាលនេះ លោកគ្រូ អ្នកគ្រូប្រើវិធីបង្រៀនអនុមានញែកចេញពីសញ្ញាណអរូបី រឺ បញ្ញត្តិអរូបីទៅរកការអនុវត្តជាក់ស្តែង ដែលទាមទារអោយសិស្សប្រឹងប្រែងរិះគិតធ្វើយ៉ាងណាអោយសញ្ញាណអរូបីយនោះកាន់តែយល់ច្បាស់តាមរយៈការផ្សារភ្ជាប់ជាមួយនឹងការពិតប្រចាំថ្ងៃរបស់សិស្ស ។ នេះជាដំណាក់កាលរៀន ( សិស្សធ្វើសកម្មភាព ) មួយទៀតដែលពេលនេះលោកគ្រូ អ្នកគ្រូជាអ្នកធ្វើផែនការ ព្រមទាំងជំរុញអោយសិស្សប្រឹងប្រែងផ្សារភ្ជាប់ពីអរូបី មករូបី ។

ឧទាហរណ៍ : ផ្អែកលើបញ្ញត្តិខាងលើ ចូរប្អូនវិភាគមើលថា តើសព្វថ្ងៃនេះ ខ្លួនរបស់ប្អូនបានប្រព្រឹត្តអំពើអ្វីខ្លះដែលទាក់ទងនឹងសកម្មភាពរបស់ជនស្នេហាជាតិ ? តើប្អូនប្តេជ្ញាចិត្តនឹងធ្វើអ្វីខ្លះសំរាប់ថ្ងៃមុខ ដើម្បីក្លាយខ្លួនទៅជាជនស្នេហាជាតិ ? ប្រសិនបើមានជនណាម្នាក់កសាងសាលារៀន តើអាចចាត់ទុកថា ជននោះជាជនស្នេហាជាតិបានដែររឺទេ ? ហេតុអ្វី ? ពេលគឺនាំសិស្សអោយយកចំនេះដឹង រឺ ទ្រឹស្តីនៅក្នុងតំលៃបញ្ញត្តិយកមកប្រើប្រាស់ដើម្បីវិនិច្ឆ័យអំពីខ្លួនឯង អំពីអ្នកដទៃ និងធ្វើការសំរេចចិត្តចំពោះអាកប្បកិរិយារបស់ខ្លួនសំរាប់អនាគត និងរួមចំណែកសង់នៅសុខដុមរមនាជាមួយគ្នា ដើម្បីកសាងមាតុភូមិខ្លួន ក៏ដូចជាពិភពលោកយើងនេះ ប្រកបដោយសុខសន្តិភាព និងវឌ្ឍនភាព ។

**៤- វាយតំលៃ :** នេះជាផ្នែកសំខាន់បំផុតសំរាប់ពតិមានត្រលប់ដល់សិស្ស ដល់លោកគ្រូ អ្នកគ្រូ ដល់មាតាបិតាសិស្ស អំពីលទ្ធផលការងាររបស់ខ្លួន ក៏ដូចជាសមត្ថភាពរបស់ខ្លួន ។ រង្វាយតំលៃយ៉ាងទៀតទាត់ នឹងញឹកញាប់មានឥទ្ធិពលបង្កើនសមិទ្ធផលសិក្សារបស់សិស្ស ( អត្រាប្រលងជាប់នឹងកើនឡើង ) ។ តាមការពិត រង្វាយតំលៃត្រូវតែធ្វើទៅលើពុទ្ធិ - ទឹកចិត្ត ( សញ្ចេតនា ) អាកប្បកិរិយា ដោយរាប់បញ្ចូលទាំងបំនិនផង តាមរយៈសំនួរខុស រឺ សំនួរត្រូវសំនួរពហុជ្រើសរើស សំនួរផ្គូផ្គង សំនួរ បញ្ហា រឺ លំហាត់អនុវត្តដោះស្រាយបញ្ហា រឺ បញ្ចេញមតិ រឺ ការនិពន្ធអត្ថបទ រឺ ការសង្កេតឃើញអាកប្បកិរិយាផ្ទាល់របស់សិស្ស ។

ឧទាហរណ៍ : បើប្អូនជិះម៉ូតូ ហើយប្អូនចង់ប្រជែងគេ តើប្អូនត្រូវធ្វើដូចម្ដេចខ្លះ ? ( សំនួរដោះស្រាយបញ្ហា ) ។

**៥ · គំនិតគួរពិចារណា និង ការណែនាំ :** គំនិតគួរពិចារណាសំរាប់សិស្សយកទៅគិតនៅពេលត្រលប់ទៅផ្ទះវិញ ។ សូមលោកគ្រូ អ្នកគ្រូធ្វើការណែនាំអោយសិស្សអានមេរៀនទៅផ្ទះជាមុន កត់មេរៀនទៅផ្ទះជាមុន រិស្រាវជ្រាវដោយខ្លួនឯង តាមរយៈការអានបណ្ដាឯកសារនានាដែលទាក់ទងនឹងមេរៀន ។ សិស្សត្រូវតែសាកសួរបំភ្លឺចំងល់របស់ខ្លួនដល់មាតា បិតា តាអាចារ្យ លោកសង្ឃ មេឃុំ ។ ល ។ ដើម្បីអោយមានមតិទូលំទូលាយយកមកពិភាក្សាគ្នាជាមួយមិត្តរួមថ្នាក់ ។

**ដោយបណ្ឌិត អ៊ឹម កុច**

> « **អ្នកអប់រំត្រូវប្រយ័ត្នប្រយែងឫកពា សំដីសំដៅអោយណាស់ ព្រោះតែពាក្យសំដី និង ឫកពារបស់គ្រូ នឹងជ្រាបចូលទៅដក់ក្នុងក្បាលសិស្សដោយមិនដឹងខ្លួន** »

# ក្រូចពោធិសាត់

ក្នុងចំណោមផ្លែឈើទាំងអស់ដែលយើងធ្លាប់ទទួលទាន ក្រូចពោធិសាត់ជាផ្លែឈើម្យ៉ាងសំបូរដោយជីវជាតិសេ (C) និងជីវជាតិឯទៀត ដែលរាងកាយយើងត្រូវការជាចាំបាច់ ដូចជាជីវជាតិអា (A) បេអង (B$_1$) បេឌឺ (B$_2$) និងប៉េប៉េ (PP) ។

ជីវជាតិ (C) នៅក្នុងក្រូចពោធិសាត់ មានគុណភាពល្អជាងជីវជាតិសេ (C) ដែលបានធ្វើជាឱសថរួចស្រេច ។ កាលណាចូលដល់ក្នុងខ្លួនយើងជីវជាតិសេ (C) រលាយជាមួយឈាមជ្រាបចូលកោសិកា ហើយផ្តល់ថាមពលដល់កោសិកាទាំងនោះអោយរីកចំរើនល្អ និងមានកំលាំងគ្រប់គ្រាន់សំរាប់ទប់ទល់នឹងការឈ្លានពាននៃមេរោគផង ។ ពេលមានគ្រុនក្តៅ រាងកាយយើងត្រូវចំណាយជីវជាតិសេ (C) ច្រើនជាងពេលធម្មតា ។

ការខ្វះខាតជីវជាតិសេ (C) អាចធ្វើជំងឺអោយគ្រលប់ជាធ្ងន់ និងធ្វើអោយយើងអស់កំលាំងហេវ ហើយជាពិសេស ធ្វើអោយខ្លួនយើងពុំអាចទប់ទល់បាននឹងការរុករាននៃមេរោគ ។

ជីវជាតិសេ (C) ជួយអោយយើងជៀសវាងជំងឺធ្លាក់ឈាមបាន អាចជួយអោយដំបៅឆាប់សះ ព្រមទាំងធ្វើអោយយើងរួចផុតពីជំងឺគ្រុនផ្តាសាយធ្ងន់ៗផង ។

ខ្លួនយើងត្រូវការជីវជាតិសេ (C) ច្រើនជាងគេនៅរដូវក្តៅ គឺពីខែ មេសា ដល់ខែ មិថុនា រឺ កក្កដា ។ អ្នកដែលត្រូវការជីវជាតិសេ (C) ជាងគេគឺអ្នកលេងកីឡា និងអ្នកធ្វើការធ្ងន់ៗ ។ ដូច្នេះ ក្រូចពោធិសាត់ជាចំណីអាហារដ៏ប្រសើរ និងជាឱសថមួយដ៏ល្អចំពោះខ្លួនយើងក្នុងរដូវក្តៅនោះ ។ ក្រូចពោធិសាត់មានប្រសិទ្ធិភាពក្នុងការព្យាបាលរោគស្បែក និងប្រព័ន្ធប្រសាទ ព្រមទាំងជំងឺខ្លះទៀតដូចជា បាយមិនឆ្ងាញ់ គ្រុនក្តៅ ធាត់ ដំណេកមិនបាន ជំងឺបេះដូង ។ ល ។ អ្នកដើបពីឈឺ បើទទួលទានក្រូចរាល់ថ្ងៃ មុខជាឆាប់មានកំលាំងឡើងវិញពុំខាន ។

តទៅនេះ គឺតារាងបង្ហាញចំនួនជីវជាតិសេ (C) ដែលខ្លួនយើងត្រូវការតាមអាយុ និងក្នុងករណីផ្សេងៗគ្នា ៖

| អាយុ | ជីវជាតិសេ (C) ត្រូវការជាមីល្លីក្រាម | ចំនួនថ្ងៃ |
|---|---|---|
| ក្មេង ៥ ឆ្នាំ | ៥០ មីល្លីក្រាម | ១ ថ្ងៃ |
| ក្មេង ១០ ឆ្នាំ | ៦០ មីល្លីក្រាម | ១ ថ្ងៃ |
| យុវជន ១៥ ដល់ ២០ ឆ្នាំ | ១០០ ដល់ ១៥០ មីល្លីក្រាម | ១ ថ្ងៃ |
| ស្រីមានផ្ទៃពោះ | ១៤០ ដល់ ១៥០ មីល្លីក្រាម | ១ ថ្ងៃ |
| មនុស្សចាស់ | ៧០មីល្លីក្រាម | ១ ថ្ងៃ |

ក្រូចពោធិសាត់មួយអាចផ្តល់ជីវជាតិសេ (C) បានប្រហែល ៥០ មីលីក្រាម ។ ដូច្នេះ ក្មេងអាយុប្រាំឆ្នាំទទួលទានបានតែក្រូចមួយក្នុង ១ថ្ងៃជាការគ្រប់គ្រាន់ហើយ ។

ក្រៅពីផ្តល់នូវជីវជាតិសេ (C) ក្រូចពោធិសាត់អាចផ្តល់អោយយើងនូវជាតិផ្សេងៗទៀត ដូចតទៅនេះ ៖

១- ទឹក. ក្រូចនីមួយៗមានទឹកពី ៨៥ ដល់ ៩០ ភាគរយ ។ ទឹកនេះជាទឹកធម្មជាតិសុទ្ធល្អ មានជាតិទ្រទ្រង់ជីវិត និងមានសារៈសំខាន់ក្នុងការរំលាយអាហារផង ។

២- ស្ករ. ក្រូចនីមួយៗអាចផ្តល់ស្ករពី ៨ ដល់ ១២ ភាគរយ ។ ស្ករនេះមានគុណភាពល្អប្រពៃណាស់ចំពោះសរីរាង្គនៃអ្នកមានជំងឺដូចអ្នកជា ។

៣- ក្រូចពោធិសាត់ផ្តល់ជីវជាតិដែក ទង់ដែង ស្ពាន់ធ័រ ប៉ូតាស្យូម ម៉ាញ៉េស្យូម និងកាល់ស្យូមដល់ខ្លួនយើងដែរ។ ទោះជាជាតិទាំងនេះមានតិចតួចស្តួចស្តើងនៅក្នុងខ្លួនយើងក៏ដោយ តែវាជាជាតិដែលមានសារៈសំខាន់ជាទីបំផុតចំពោះសុខភាព ។

បើទទួលទានក្រូចពោធិសាត់ រឺ ទឹកក្រូចពោធិសាត់ យើងគួរតែទទួលទាននៅពេលព្រឹក ដូចជាជនជាតិអារ៉ាប់បាននិយាយសំណេះសំណាលថា ៖

« ពេលព្រឹក ក្រូចមានតំលៃប្រៀបបាននឹងមាស ពេលថ្ងៃត្រង់ ក្រូចមានតំលៃប្រៀបបាននឹងប្រាក់ ពេលល្ងាចក្រូចមានតំលៃប្រៀបបាននឹងសំណ » ។ ដូច្នេះ ទោះបីយើងអាចទទួលទានក្រូចពោធិសាត់ពេលណាក៏បានដែរនោះក៏ដោយ តែគួរយើងទទួលទានពេលព្រឹក ព្រោះពេលនេះ ក្រូចមានគុណភាពជាងពេលថ្ងៃត្រង់និងល្ងាច ។

អត្តពលករ ម៉ារសែល ហាន់សែន (Marcel Hansenne) ដែលជាអ្នករត់ប្រណាំងលេខមួយ ចូលចិត្តទទួលទានក្រូចនៅពេលព្រឹកណាស់ ។ តាមយោបល់លោក កីឡាករណាក៏ត្រូវទទួលទានក្រូចទាំងអស់ទើបមានកំលាំង និងសុខភាពល្អ ។

នីណុង ដឺឡង់ក្លូ (Ninon de Lenclos) ដែលជាស្ត្រីម្នាក់មានសោភ័ណភាពឥតខ្ចោះ ល្បីល្បាញទាំងអឺរ៉ុបអាចរក្សាស្បែកមុខអោយបានស្រស់ល្អរហូតដល់អាយុ ៨៥ ឆ្នាំ ក៏ដោយសារតែបានទទួលទានក្រូចមួយថ្ងៃៗជាងដប់ផ្លែ ។

សិល្បៈការិនី សារ៉ា ប៊ែរណារ (Sarah Bernhardt) ជាអ្នកធ្លាប់ទទួលទានក្រូចពោធិសាត់ និងក្រូចឆ្មារាល់ថ្ងៃដែរ ហេតុនោះហើយបានជាសិល្បការិនីរូបនេះ មានសោភ័ណភាពស្រស់ប្រិមប្រិយល្អបិតថេរជាយូរអង្វែង ។

និយាយដោយសង្ខេប អ្នកណាដែលចង់អោយសុខភាពបានល្អ និងមានកំលាំង គួរតែទទួលទានក្រូចពោធិសាត់រាល់ថ្ងៃ ជាពិសេសទទួលទាននៅពេលព្រឹក ។ ប្រទេសយើងមានក័ក្ខព្រេងសំណាងដ៏ប្រពៃ ដោយធម្មជាតិផ្តល់អោយមានក្រូចពោធិសាត់បរិបូរណ៍ ហេតុអ្វីក៏យើងមិនទទួលទាន ?

ដោយឯកឧត្តម ទ្រៀង ចាណី

ដកស្រង់ចេញពីទស្សនាវដ្តីខេមរយានកម្ម ឆ្នាំទី ២ ភាគ៧

**« ចំណីអាហារ និង ទឹក ចាំបាច់ដល់ក្មេងយ៉ាងណា បរិយាកាសសប្បាយរីករាយ និង វិស្សមកាលនៅពេលរៀនក៏ចាំបាច់ដល់សិស្សយ៉ាងនោះដែរ »**

# ការស្គាល់ខ្លួនឯង
# La connaissance de soi

នៅទំព័រទី ១ ជំពូកទី ១ សៀវភៅគ្រូសិក្សាសង្គមថ្នាក់ទី ៧ បានចាប់ផ្តើមមេរៀននេះជាដើមអាទិ ។

យើងគួរនាំគ្នាសួរថា ហេតុអ្វីបានជាគណៈកម្មការនិពន្ធចាប់ផ្តើមមេរៀននេះមុនគេ ? តើមានគោលបំណងអ្វី ?

ក្នុងឋានៈជារៀមច្បង ខ្ញុំសូមជួយបង្កើនការយល់ដឹងពីមេរៀននេះបន្ថែមទៀត តាមការយល់ដឹងរបស់ខ្ញុំ ។

ទស្សនវិទូក្រិចសូក្រាត ( ៤៧០ - ៣៩៩ មុន គ.ស. ) បានអប់រំសិស្សគាត់ រឺ អ្នកចូលចិត្តស្តាប់គាត់នូវពាក្យទូន្មានមួយឃ្លាថា ៖ « Connais-toi, toi-même » ប្រែថា « **ចូរឯងស្គាល់ខ្លួនឯងដោយខ្លួនឯងផ្ទាល់** » ។ បានសេចក្តីថា មានគំនិតត្រឹមត្រូវច្បាស់ពីខ្លួនឯងផ្ទាល់ និងពីលទ្ធភាពរបស់ខ្លួន ។

យើងនាំគ្នាសិក្សាពីពាក្យដ៏មានតំលៃមួយឃ្លានេះ ។ ពាក្យ « **ស្គាល់ខ្លួនឯង** » តើស្គាល់ទៅលើអ្វី ? មនុស្សគ្រប់រូបកើតមានភេទប្រុស ភេទស្រី ខុសៗគ្នា ។ ប៉ុន្តែ គ្រប់គ្នាមិនបានរៀនសូត្រអោយបានស៊ីជំរៅនូវអ្វីដែលហៅថា ការស្គាល់ខ្លួនឯងអោយបានច្បាស់លាស់ឡើយ ។

## * ភាពចាំបាច់នៃការស្គាល់ខ្លួនឯង

១- **ស្គាល់សរីរៈរបស់ខ្លួន** : ឧទាហរណ៍ : អ្នកជាសិស្ស និស្សិត ជាគ្រូ នៅពេលអ្នកទៅអោយលោកគ្រូពេទ្យពិនិត្យរោគ គាត់តែងតែអោយគិលានុបដ្ឋាក-ដ្ឋាយិកាវាស់សីតុណ្ហភាព ។ លោកគ្រូពេទ្យតែងតែសួរនាំចង់ដឹង តើអ្វីដែលនាំអោយអ្នកមិនស្រួលខ្លួន រឺ ឈឺនេះ ។ តើមកពីអ្វី ? តើគាត់ត្រូវធ្វើដូចម្តេចដើម្បីព្យាបាល ? ដោយឃើញអ្នកស្លមពេក រឺ ធាត់ពេក រឺ កូនស្រីពាក់អាវរឹតខ្លួនពេក ? ជារួម ការពិនិត្យយ៉ាងយកចិត្តទុកដាក់នេះ មានគោលបំណងអោយអ្នកជៀសវាងបានជំងឺផ្សេងៗ ។ គាត់បញ្ជាកុំអោយញ៉ាំស្ករ រឺ ខ្លាញ់ច្រើនពេក អោយសំរាកអោយបានគ្រប់គ្រាន់ អោយលេងកីឡា ។ល។ បើអ្នកជាអ្នកស្គាល់ខ្លួនពិតដោយខ្លួនឯងផ្ទាល់ អ្នកនឹងធ្វើតាមលោកគ្រូពេទ្យ ដើម្បីជៀសវាងជំងឺផ្សេងៗ ។ បើអ្នកធ្វើជាមិនដឹង មិនលឺ អ្នកនឹងវិនាសខ្លួនដោយការធ្វេសប្រហែស ព្រងើយកន្តើយនឹងវេជ្ជបញ្ជា ។ នេះជាកិច្ចការពារសុខភាពសរីរៈ រឺ រូបវន្ត ( Santé physique ) ។ ស្គាល់ខ្លួនឯងផ្ទាល់ បានសេចក្តីថា ខ្លួនអញឈឺអ្វី គមអ្វី ។ លោកគ្រូពេទ្យហាមមិនអោយផឹកស្រា ម្តេចក៏ខ្លួនអញភ្លេចខ្លួនទៅផឹកស្រា ហូបម្ទេសទៀត ដែលនាំអោយក្រពះរឹតតែឈឺ រឺ រលាកខូចអស់ប្រមាត់ ថ្លើម ។

មនុស្សគ្រប់រូបត្រូវថែរក្សាសុខភាពរូបវន្តជាភាតព្វកិច្ចទី ១ ។ ប៉ុន្តែ មានភាតព្វកិច្ចមួយទៀតរឹតតែសំខាន់ គឺការពារសុខភាពខួរក្បាល រឺ ផ្លូវចិត្តគំនិត ( santé mentale ) ព្រោះវាមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍ញាណសក្តិ (facultés) នៃព្រលឹង ( âme ) របស់មនុស្ស ។

ដូចនេះ ជារួមការស្គាល់ខ្លួនឯងដោយខ្លួនឯងផ្ទាល់ នាំអោយយើងប្រព្រឹត្តនូវចរិយាធម៌បានល្អប្រពៃ មិនហ៊ានរំលងបទដ្ឋានសីលធម៌ មានឆន្ទៈមោះមុត ខិតខំជំនះខ្លួនដោយខ្លួនឯង ។

កាលយើងនៅពីតូច យើងមិនស្គាល់ខ្លួនឯងដោយខ្លួនឯងបានទេ ។ គឺម្តាយយើងនេះហើយ ជាអ្នកនាំផ្លូវអោយស្គាល់អំពើល្អ-អាក្រក់ ។ យើងធ្វើអ្វីខុសឆ្គង ម្តាយយើងប្រដៅប្រដៅដោយខិតខំពង្រីកគុណសម្បត្តិយើងទៀត ។ រាល់ថ្ងៃម្តាយដឹងចិត្តយើង គាត់ខិតខំកែសំរួលទំនោរមួយមិនល្អ (Tendance) ដូចជាភាពរឹងរូស ខ្ជិល អំនួតជាដើម ។

ប៉ុន្តែ លុះខ្លួនយើងធំឡើង ហើយទៅរស់នៅឆ្ងាយពីម្តាយ ឪពុក រឺ អនិច្ចកម្មចោលទៅ តើបានរណាប្រដៅប្រដៅបន្តទៀត ។ យើងត្រូវតែរៀនលត់ដំពីក្មេង ដើម្បីប្រព្រឹត្តបានត្រឹមត្រូវតាមគន្លងធម៌ ត្រូវស្គាល់ខ្លួនឯងអោយពិតប្រាកដ ។

ខ្ញុំសូមដកស្រង់ទាំងស្រុងនូវសាសនសុភាសិតមួយឃ្លាខាងក្រោមនេះ ទុកជូនជាពាក្យប្រដៅ ៖

## អត្តា សុទន្តោ បុរិសស្ស ជោតិ (១)

## ខ្លួនដែលទូន្មានល្អហើយ ជាពន្លឺរបស់បុរស

សាសនសុភាសិតនេះ មានសេចក្តីអធិប្បាយដូចតទៅនេះ ៖

ពាក្យថាខ្លួនដែលទូន្មានល្អហើយនោះ គឺខ្លួនដែលប្រព្រឹត្តល្អជាប្រយោជន៍ចំពោះខ្លួនឯងផង ជាប្រយោជន៍ដល់អ្នកដទៃផង ។

ពាក្យថាពន្លឺរបស់បុរស សំដៅយកផលល្អរបស់សាធុជនដែលបានទូន្មានប្រៀនប្រដៅខ្លួនអោយតាំងនៅក្នុងគន្លងនៃសុចរិតធម៌អោយបានត្រឹមត្រូវទៅតាមគោលបំណងរបស់ពុទ្ធសាសនា គឺអោយមានចរិយាសម្បត្តិល្អ ស្គាល់អាក្រក់ស្គាល់ល្អ លះបង់អំពើអាក្រក់ ប្រព្រឹត្តអំពើល្អ កសាងខ្លួនអោយតាំងនៅក្នុងឧត្តមគតិ ដែលអ្នកប្រាជ្ញលោកសរសើរ ផ្សាយកេរ្តិ៍ឈ្មោះល្អអោយល្បីល្បាញក្នុងលោក មានការធ្វើប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃអោយកើតឡើងបានជាដើម ។ យ៉ាងនេះហៅថាពន្លឺ រឺ រស្មីរបស់បុរសក៏បាន ។

មួយទៀត បុរសស្ត្រីណាបានកសាងខ្លួនដោយការទូន្មានភ្នែក ច្រមុះ អណ្តាត កាយ ចិត្ត ល្មមរក្សាខ្លួនបានល្មមយោងប្រាណអោយអណ្តែតផុតចាកឋានៈដ៏ថោកទាបក្នុងលោកិយបានពិតប្រាកដហើយ បុរសស្ត្រីនោះឈ្មោះថា មានពន្លឺភ្លឺក្នុងលោកនេះនិងលោកខាងមុខ សមដូចបុរាណភាសិតថា ‹‹ **ភ្លឺពីមនុស្សលោក យោគយល់សួគ៌ាល័យ** ›› ព្រោះហេតុនោះ បានជាគោលនៃសាសនសុភាសិត ដែលបានតំកល់ទុកខាងដើមថា ៖ ‹‹ **អត្តា សុទន្តោ បុរិសស្ស ជោតិ** ›› ខ្លួនដែលទូន្មានល្អហើយ ជាពន្លឺរបស់បុរស ។

**ជារួម** : សូក្រាតទូន្មានមនុស្សអោយស្គាល់ចិត្តគំនិតខ្លួនឯងជាមុន ស្គាល់សមត្ថភាពអាចធ្វើបានរឺមិនបាន ។ កាលណាយើងស្គាល់ច្បាស់ក្នុងការប្រព្រឹត្តបាននូវអំពើល្អ (កុសល) តាមផ្លូវកាយ វាចា ចិត្ត នោះយើងមុខជានឹងមិនប្រព្រឹត្តអ្វីខុសឡើយ សមស្របទៅតាមទិសនៃជីវិត និងមានទស្សនៈមនុស្សជាតិ ។ ខ្ញុំសូមលើករឿងមួយមកនិទានដូចតទៅ ៖

អាល់ស៊ីប៊ីយ៉ាត (Alcibiade) ជាសិស្សរបស់សូក្រាត ។ គាត់មិនបានយកចិត្តទុកដាក់នឹងដំបូន្មានរបស់សូក្រាតឡើយ ។ គាត់មានឋានៈជាមេទ័ពនៃប្រទេសអាថែន (Athènes) ។ គាត់ចង់ធ្វើសង្គ្រាមយកប្រទេសស៊ីស៊ីល (Sicile)

(១) – សាសនសុភាសិត ភាគទី១ ទំព័រទី ៥ ផ្សាយចេញពីពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥៣៩

មកធ្វើជាចំណុះប្រទេសអាថែន ។ គាត់ទៅពិគ្រោះជាមួយលោកគ្រូគាត់ គឺ សូក្រាត ។ សូក្រាតឆ្លើយភ្លាមថា ចូរឯងស្គាល់ ( ដឹង ) ខ្លួនឯងអោយច្បាស់ថា តើឯងមានសមត្ថភាពគ្រប់គ្រាន់ឬទេ ? ។

ដោយមហិច្ឆតាខ្លាំងពេក អាល់ស៊ីប៊ីយ៉ាត ( Alcibiade ) ចាប់ផ្ដើមធ្វើសង្គ្រាមទាំងផ្សងព្រេង ដោយធ្វើអោយប្រទេសអាថែនចាញ់សង្គ្រាមនៅឆ្នាំ ៤១៥ មុន គ.ស. ។ ម្យ៉ាងទៀត អាល់ស៊ីប៊ីយ៉ាត ត្រូវជាប់ចោទពីបទពិសិដ្ឋបមាថ ( Sacrilège ) បដិមាករនៃទេវ Hermès ផងទៀត ។ គាត់រត់ទៅនៅក្នុងប្រទេស Sparte មួយរយៈ ។ នៅទីបញ្ចប់នៃជីវិតគាត់ គាត់មកសុំជ្រកកោនទៅប្រទេសខ្លួនវិញ គឺអាថែន ប៉ុន្តែត្រូវគេនិរទេស ។ គាត់ស្លាប់ដោយគេធ្វើឃាត (១) ។

ខ្ញុំមានជំនឿជាក់ថា សំនេររបស់ខ្ញុំប៉ុននេះ ត្បិតផ្សំនឹងសំនេរក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី ៧ សមល្មមគ្រប់គ្រាន់ បំពេញចំណេះដឹងរបស់លោកគ្រូ - អ្នកគ្រូ ដែលជាអ្នកអប់រំបានខ្លះហើយ ។ ប៉ុន្តែ ការដឹកនាំមេរៀនអោយដល់ទិសដៅ ខ្ញុំទុកអោយលោកគ្រូ អ្នកគ្រូជាអ្នកផ្ដើមគំនិតតាមការណែនាំពីស្ថាប័នអប់រំថ្នាក់លើ ។

**យ៉ង់ ធី**

(១) – សូមអានសៀវភៅ Alcibiade របស់លោកស្រី Jacqueline de Romilly de l’Académie française ។




# វិធីបង្រៀនសិស្សមជ្ឈមណ្ឌល

## ១- សញ្ញាណទូទៅ

ដូចយើងបានដឹងរួចមកហើយ គោលដៅនៃការអប់រំបច្ចុប្បន្ន គឺអភិវឌ្ឍន៍បុគ្គលម្នាក់ៗ ដើម្បីអោយគេមានលទ្ធភាពចូលរួមកសាងសង្គម ។ នេះមានន័យថា ការអប់រំត្រូវផ្តល់ឱកាសអោយបុគ្គលគ្រប់រូបកសាងលទ្ធភាពរបស់គេ ទាំងរូបរាងកាយ បញ្ញាស្មារតី សតិអារម្មណ៍ សីលធម៌ និងសោភ័ណ... ។ ទាំងអស់នេះ គឺជាបរិបទដែលសង្គមទាំងមូលទាមទារអោយបុគ្គលគ្រប់រូបត្រូវមាន ហើយដែលអ្នកអប់រំពិសេស គ្រូបង្រៀនត្រូវសំរេចអោយបានដើម្បីត្រៀមរៀបចំយុវជនជំនាន់ក្រោយអោយបន្តវេនកសាង និងបំរើអត្ថិភាពសង្គមតាមរយៈការផ្តល់ចំនេះដឹង ( Le savoir ) ចំនេះធ្វើ ( Le savoir faire ) ការអប់រំផ្លូវចិត្ត ( le savoir être ) និងការចេះរស់នៅជាមួយគ្នាក្នុងសង្គម ( savoir vivre ensemble dans la société ) ។

ផ្តើមចេញពីនេះ គ្រូបង្រៀនម្នាក់ៗត្រូវចាប់អារម្មណ៍ជានិច្ចថា ខ្លួនជាអ្នកសំរបសំរួលការរៀនសូត្ររបស់សិស្ស មិនមែនជាអ្នកបង្ខំសិស្សអោយធ្វើតាមឡើយ ។ ឯសិស្សម្នាក់ៗមានលក្ខណៈដោយឡែកៗពីគ្នា ទាំងចំនង់ចំនូលចិត្ត ទាំងតំរូវការ ទាំងកំរិតយល់ដឹង... ។ ដូចនេះ គ្រូត្រូវព្យាយាមរិះរកគ្រប់វិធី ដើម្បីស្វែងយល់ពីសិស្សអោយបានច្បាស់ និងជំរុញ ( motiver ) អោយសិស្សម្នាក់ៗប្រើអស់លទ្ធភាពដែលគេមាន តាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនប្លែកៗ និងសំភារៈឧបទេសសំបូរបែបសំដៅទាក់ទាញចំនង់ចំនូលចិត្ត និងជំនក់ចិត្តសិស្សអោយចាប់អារម្មណ៍ចូលរួមលើមេរៀន ។

ពាក់ព័ន្ធលើវិធីសាស្ត្របង្រៀន គ្រូបង្រៀនម្នាក់ៗគួរចាប់អារម្មណ៍អោយបានច្បាស់លាស់ថា គ្មានវិធីសាស្ត្របង្រៀនណាមួយល្អប្រសើរបំផុតឡើយ ។ គ្រូបង្រៀនម្នាក់ៗតែងមានវិធី និងល្បិចបង្រៀនរៀងៗខ្លួន ។ តែទោះបែបនេះក្តី ក៏ការស្រាវជ្រាវជាច្រើនបានបង្ហាញអោយឃើញថា សិស្សរៀនបានល្អប្រសើរនៅពេលដែលគេបានចូលរួមយ៉ាងសកម្មក្នុងលំនាំនៃការបង្រៀន - រៀន ។

ទន្ទឹមនេះ ការរៀនក៏គ្មានរបៀបណាមួយល្អបំផុតសំរាប់សិស្សដែរ ។ តែទោះយ៉ាងណា ក៏គ្រូត្រូវជៀសវាងដាក់សិស្សអោយស្ថិតក្នុងភាពអកម្ម ហើយបង្ខំអោយសិស្សទន្ទេញចាំមាត់ដូចសត្វសេកដែរ ។ ក្នុងគ្រប់ករណីទាំងអស់ គេត្រូវបំផុសចំនូលចិត្ត និងជំរុញសិស្សអោយធ្វើសកម្មភាពរៀនសូត្រអោយបានច្រើនជាអតិបរមា ទៅតាមលទ្ធភាពដែលគេមាន ។ ចង់សំរេចបានសំនូមពរនេះ គ្រូត្រូវចេះប្រើប្រាស់ « គោលវិធីសិស្សជាមជ្ឈមណ្ឌល » ។

## ២- គោលបំណង

ជាការពិត គោលវិធីសិស្សជាមជ្ឈមណ្ឌល ផ្ទុយស្រឡះពីគោលវិធីគ្រូជាមជ្ឈមណ្ឌលដែលក្នុងនោះ ការបង្រៀនសំរេចលើសកម្មភាពគ្រូ ឯសិស្សចាំតែទទួល ។

គោលបំណងសំខាន់នៃវិធីនេះគឺផ្តល់អោយ ៖

- ជីវិតកុមារមានការអភិវឌ្ឍពីមួយថ្ងៃទៅមួយថ្ងៃឈានទៅរកការរីកចំរើនពេញលេញលើគ្រប់ផ្នែកដើម្បីប្រែក្លាយជាមនុស្សដែលសង្គមចង់បាន ។
- ថ្នាក់មានភាពរស់រវើកពោរពេញដោយបរិយាកាសរីករាយក្នុងការស្រាវជ្រាវស្វែងយល់ ។
- សិស្សបំពេញការងារយ៉ាងសកម្មក្នុងការសិក្សា ។ គេប្រើអស់លទ្ធភាពដែលគេមាន គេមានគំនិតច្នៃប្រឌិតតាមលទ្ធភាពរបស់គេ ។
- សិស្សស្គាល់តំលៃរបស់ខ្លួនដែលជាសមាជិកម្នាក់របស់ក្រុម និងសង្គមទៅអនាគត ។
- សិស្សយល់ដឹងពីសិទ្ធិទទួលខុសត្រូវរបស់ខ្លួន និងចេះគោរពសិទ្ធិអ្នកឯទៀត ( ការអប់រំសិទ្ធិមនុស្ស ) ។
- សិស្សយល់ដឹងពីអត្ថន័យនៃតំលៃសោភ័ណ សិល្បៈ តន្ត្រី អក្សរសិល្ប៍ ... ។
- សិស្សចេះរស់នៅ និងសហការជាមួយអ្នកឯទៀតប្រកបដោយការយោគយល់គ្នា និងគ្មានហឹង្សា ( បណ្តុះគំនិត សាមគ្គីភាព ភាតរភាព សន្តិភាព ចេះរស់នៅរួមគ្នា ... ) ។
- សិស្សរៀនប្រើប្រាស់ពេលទំនេររបស់គេអោយមានប្រយោជន៍ ។
- សិស្សយល់ដឹងច្បាស់ពីបរិស្ថាន ( បរិស្ថានសាលារៀន សង្គម និង ធម្មជាតិ ) ។

## ៣- លក្ខណៈគួរអោយកត់សំគាល់នៃវិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌល

ការបង្រៀនសិស្សមជ្ឈមណ្ឌលមានលក្ខណៈដូចខាងក្រោម ៖

១- ថ្នាក់រៀនរស់រវើកពោរពេញដោយបរិយាកាសរីករាយក្នុងការផ្លាស់ប្តូរយោបល់គ្នាលើប្រធានបទដែលត្រូវសិក្សា ។

២- ថ្នាក់រៀនត្រូវមានពន្លឺគ្រប់គ្រាន់ មានអនាម័យ និងរៀបចំបានល្អ ដើម្បីអោយសិស្សរៀនសូត្របានល្អ ។

៣- ថ្នាក់រៀនត្រូវមានឈុតសំភារៈឧបទេសសំបូរបែបសំរាប់បំរើការបង្រៀន - រៀន ហើយត្រូវរៀបចំទុកដាក់និងដាក់តាំងអោយមានរបៀបរៀបរយដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ដូចជាតំរោងកម្មវិធី តារាងផ្សេងៗ ទូភណ្ឌនិកេតន៍ដែលក្នុងនោះត្រូវមានសំភារៈសំរាប់បង្រៀនមុខវិជ្ជាផ្សេងៗ ដូចជាវិទ្យាសាស្ត្រ ភូមិវិទ្យា ប្រវត្តិវិទ្យា ... ទូដាក់សៀវភៅ រឺឯកសារស្នាដៃច្នៃប្រឌិតរបស់សិស្ស ។

៤- កិច្ចតែងការបង្រៀនត្រូវឆ្លើយតបទៅនឹងវិសេសភាពសិស្សម្នាក់ៗទៅតាមតំរូវការផ្ទាល់ និងសមត្ថភាពរបស់គេម្នាក់ៗ ។

៥- សកម្មភាពសិស្សច្រើនជាងសកម្មភាពគ្រូ ។ សិស្សពង្រីកបានភាពម្ចាស់ការច្នៃប្រឌិត និងស្គាល់តំលៃរបស់ខ្លួនប្រកបដោយឆន្ទៈមោះមុតក្នុងការសិក្សា ។

៦- ជាធម្មតាសិស្សត្រូវបានបែងចែកជាក្រុមការងារទៅតាមលទ្ធភាពជាក់ស្តែងដូចបានរៀបរាប់ខាងលើ ។

៧- សិស្សត្រូវប្រើប្រាស់អស់លទ្ធភាព ដើម្បីបង្ហាញអោយឃើញនូវសមត្ថភាពក្នុងការទទួលខុសត្រូវលើគ្រប់

ផ្នែក ពិសេសផ្នែកសណ្តាប់ធ្នាប់ និងការដឹកនាំការពិភាក្សា និងឡើងឆ្លើយសំនួរ ។

៨- សិស្សត្រូវជៀសវាងដាច់ខាត ការសូត្រតាមគេ និងទន្ទេញចាំមាត់ដូចសត្វសេក ។

៩- គ្រូត្រូវស្គាល់សិស្សម្នាក់ៗ ហើយចាត់ទុកសិស្សជាបុគ្គលដែលមានគ្រប់ការលំបាកដែលត្រូវការអោយគ្រូជួយដោះស្រាយ ។

១០- រាល់ទណ្ឌកម្មរាងកាយ ការគំរាមកំហែង ត្រូវបានចៀសវាងដាច់ខាតដើម្បីបង្កបរិយាកាសទុកចិត្តគ្នា យោគយល់ និងមានអធ្យាស្រ័យល្អរវាងគ្នានិងគ្នាប្រកបដោយប្រជាធិបតេយ្យ ។

## ៤- ការដឹកនាំសកម្មភាពបង្រៀន

៤.១- **ការរៀបចំក្រុមការងារ :** វិធីបង្រៀនសិស្សមជ្ឈមណ្ឌលអាចអនុវត្តបានតាមច្រើនរូបភាពដូចជា ៖

- បង្រៀនជាក្រុមធំ ( សិស្សមួយថ្នាក់ធម្មតា )
- បង្រៀនជាក្រុមមធ្យម ( សិស្សពី ៥ ទៅ ១០ នាក់ )
- បង្រៀនជាក្រុមតូច ( សិស្សពី ៣ ទៅ ៥ នាក់ )
- បង្រៀនជាដៃគូ ( សិស្សពីរនាក់ )
- បង្រៀនសិស្សម្នាក់ ( គ្រូម្នាក់ សិស្សម្នាក់ )

៤.២- **ការអនុវត្តសកម្មភាពបង្រៀន :** ជាទូទៅការបង្រៀនសិស្សមជ្ឈមណ្ឌល ទោះស្ថិតក្នុងរូបភាពបែបណាក្តី ( ក្រុមធំ ក្រុមមធ្យម ក្រុមតូច... ) រាល់សកម្មភាពបង្រៀនត្រូវប្រមូលផ្តុំលើសិស្ស ។ សិស្សត្រូវប្រើប្រាស់គ្រប់លទ្ធភាព ដើម្បីស្វែងយល់មេរៀន ឯគ្រូមានតួនាទីត្រឹមជាអ្នកសំរបសំរួលប៉ុណ្ណោះ ។

៤.២.១. **ការបង្រៀនតាមក្រុមធំ ( សិស្សមួយថ្នាក់ )**

មតិមួយចំនួនតែងយល់ថា ការបង្រៀនជាក្រុមធំ ជារបៀបបង្រៀនបែបបុរាណ និងអន់ថយបំផុត ព្រោះសិស្សត្រូវរៀនរួមគ្នាដោយគ្មានបែងចែកជាក្រុមតូចៗ តាមមតិនេះគេយល់ថា វិធីបង្រៀនសិស្សមជ្ឈមណ្ឌលត្រូវតែបង្រៀនជាក្រុមតូចៗ រៀបចំអោយសិស្សអង្គុយទល់មុខគ្នា ... ។ តាមពិតយើងគួរចាប់អារម្មណ៍អោយច្បាស់ថា សិស្សមជ្ឈមណ្ឌល សិស្សជាមជ្ឈមណ្ឌលនៃសកម្មភាព មានន័យថា រាល់សកម្មភាពបង្រៀន - រៀនត្រូវប្រមូលផ្តុំលើសិស្ស រឺនិយាយអោយងាយស្តាប់គឺ ‹‹ **សិស្សត្រូវធ្វើសកម្មភាពច្រើនជាងគ្រូ ដោយប្រើគ្រប់លទ្ធភាពដែលគេមានដើម្បីស្វែងយល់ចំណេះដឹង និងបង្រៀនគ្នាទៅវិញទៅមក** ›› ។ ក្នុងន័យនេះគឺ សិស្សមជ្ឈមណ្ឌលសំដៅលើខ្លឹមសារសកម្មភាពរបស់សិស្ស មិនមែនសំដៅលើរូបភាពចាត់តាំងជាក្រុមឡើយ ។ ដូចនេះ ទោះបង្រៀនសិស្សមួយថ្នាក់ ក៏គ្រូអាចអនុវត្តវិធីបង្រៀនសិស្សមជ្ឈមណ្ឌលបានដែរ ។ ឯរបៀបអនុវត្តមានដូចខាងក្រោម ៖

- រក្សាសិស្សអោយស្ថិតក្នុងស្ថានភាពធម្មតា ( គ្មានផ្លាស់ប្តូរទីកន្លែងអង្គុយ )
- គ្រូផ្តល់ការងារ ( សំនួរ ) អោយសិស្សអនុវត្ត ( ផ្តល់សំនួរ ផ្តល់សំភារៈឧបទេសអោយសិស្សប្រើប្រាស់ ... )

ឧទាហរណ៍ : អោយសិស្សម្នាក់ៗផ្តល់មតិលើខ្លឹមសារមួយតាមការយល់ឃើញរបស់គេ ផ្តល់សំនួរទូទៅមួយអោយសិស្សម្នាក់ៗគិត ដើម្បីរកចំលើយ ... ។

- គ្រូកំណត់ពេលវេលាសំរាប់សិស្សពិចារណាលើប្រធានបទដែលដាក់អោយអនុវត្ត ។
- សិស្សម្នាក់ៗម្ចាស់ការដោះស្រាយបញ្ហាតាមលទ្ធភាពផ្ទាល់របស់ខ្លួន ( សិស្សប្រើបំណិនរបស់គេដើម្បីពិនិត្យសំភារៈឧបទេស ឯកសារ ឆ្លើយសំនួរ ) ។
- សិស្សសរសេរការយល់ដឹងរបស់ខ្លួនដាក់ក្រដាសព្រាង ដើម្បីត្រៀមឡើងបំភ្លឺសិស្សឯទៀតក្នុងថ្នាក់ទាំងមូល ។
- គ្រូរង់ចាំជួយបំភ្លឺសិស្សក្នុងករណីចាំបាច់ ( គ្រូអាចពន្យល់ចំណុចរមខ្លះមុនក៏បាន រង់ចាំជួយបំភ្លឺពេលសិស្សកំពុងធ្វើការក៏បាន ) ។
- គ្រូហៅសិស្សឡើងរាយការណ៍ពីចំលើយរបស់ខ្លួន ចំពោះមុខសិស្សឯទៀត ។
- សិស្សឯទៀតជួយកែលំអ ( ពិភាក្សារួម ) ដើម្បីផ្តល់ចំលើយល្អៗ ។
- គ្រូជួយកែតំរូវចុងក្រោយ ( បើសិនចាំបាច់ ) ដើម្បីរកខ្លឹមសារឯកភាពមួយ ។
- គ្រូវាយតំលៃការយល់ដឹងរបស់សិស្សតាមរយៈ ៖
  . សំនួរផ្ទាល់មាត់
  . សំនួរតេស្តខ្លីៗដោយសរសេរ ...

៤.២.២. ការដឹកនាំសកម្មភាពបង្រៀនតាមក្រុម ( ក្រុមមធ្យម ក្រុមតូច ក្រុមដៃគូ )

ក - **សមាសភាពក្រុមការងារ** : ការចាត់តាំងជាក្រុមការងារ អាស្រ័យទៅតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់រៀននីមួយៗ ។ តែជាទូទៅគេអាចរៀបចំដោយពិចារណាលើចំណុច ៖

. ផ្អែកបរិមាណ ( ចំនួនសមាជិកក្នុងក្រុមនីមួយៗបានរៀបរាប់ខាងលើ )
. ផ្អែកគុណភាព ( ក្នុងក្រុមនីមួយៗមានសមត្ថភាពចំរុះ ខ្លាំង មធ្យម ខ្សោយ រឺ ក្រុមពូកែ ក្រុមមធ្យម ក្រុមខ្សោយ ) ។
. ប្រធានក្រុមការងារ ( សិស្សពូកែធ្វើប្រធាន រឺ ប្រធានក្រុមប្តូរវេន ... )

ខ - **អត្ថន័យនៃការសិក្សាតាមក្រុម** : ការសិក្សាតាមក្រុមអាច ៖

- បង្កើតស្នាដៃរបស់សិស្ស និងលើកទឹកចិត្តអោយមានសញ្ចេតនាវិជ្ជមានក្នុងការរៀនសូត្រដោយជោគជ័យ ។
- បង្កើតទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធរវាងគ្នានិងគ្នា មានគំនិតយោគយល់ និងអធ្យាស្រ័យលួគោរពគ្នាទៅវិញទៅមក ។ទីបំផុតប្រការនេះបង្កើតបានជាធុងសាមគ្គីភាពមួយយ៉ាងរឹងមាំ ។
- បង្កើនសមត្ថភាពគិត សមត្ថភាពហ៊ានទិតៀនកែលំអគ្នាទៅវិញទៅមក ដើម្បីជួយគ្នាក្នុងការរៀនសូត្រ បំបាត់ភាពស្ទឹកស្រពន់ ។
- រកឃើញសិស្សពូកែសំរាប់ដើរតួជំនួសក្រុមឯកល ។
- បង្កឱកាសអោយសិស្សប្រើប្រាស់លទ្ធភាពផ្ទាល់ខ្លួនក្នុងការដណ្តើមយកចំណេះដឹងចេះប្រើប្រាស់សិទ្ធិផ្ទាល់ខ្លួន ចេះគោរពសិទ្ធិអ្នកដទៃ ... ។
- ពង្រីកការអប់របរិស្ថាន ( បរិស្ថានថ្នាក់រៀន បរិស្ថានសង្គម បរិស្ថានធម្មជាតិ ... ) ។
- ជំរុញការប្រលងប្រណាំងរៀនសូត្រ និងបញ្ចេញស្នាដៃរវាងក្រុមនីមួយៗ ។

គ - សកម្មភាពតាមក្រុមនីមួយៗ : ពេលអនុវត្តការងារក្រុមនីមួយៗត្រូវ ៖

- ជ្រើសរើសប្រធានក្រុម ( ជាការល្អគួរប្តូរវេន ) សំរាប់ដឹកនាំការពិភាក្សា រឺ ការស្រាវជ្រាវ ។
- ពិនិត្យសំនួរ ឯកសារ សំភារៈឧបទេស ... ដើម្បីស្វែងយល់ ។
- ពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាលើសំណួរ រឺ ប្រធានបទដែលគ្រូដាក់អោយ ។
- ជួយកែលំអគ្នាទៅវិញទៅមក ដើម្បីយល់ច្បាស់ប្រធានបទ ។
- កត់ត្រាចំលើយរួម ដើម្បីឡើងរាយការណ៍ ។

ឃ - ទំនួលខុសត្រូវរបស់គ្រូបង្រៀនក្នុងការដឹកនាំក្រុមការងារ ៖

- រៀបចំក្រុមការងារ ដូចមានរៀបរាប់ខាងលើដោយកំណត់ទីកន្លែងធ្វើការរបស់ក្រុមនីមួយៗ ច្បាស់លាស់ និងសមរម្យ ។
- ណែនាំច្បាស់លាស់ពីភារកិច្ច និងគោលការណ៍អនុវត្តការងាររបស់ក្រុមនីមួយៗ ។
- កំណត់ពេលវេលាធ្វើការរបស់ក្រុមនីមួយៗច្បាស់លាស់ និងសមស្របតាមទំហំការងារ ( គ្រប់គ្រងពេលវេលា ) ។
- ផ្តល់ឱកាសភាពផ្នែកសំភារៈ និងស្មារតីដល់ក្រុមនីមួយៗ ។
- ជួយធ្វើអន្តរាគមន៍តាមក្រុមនីមួយៗទាន់ពេលវេលា ទទឹមនឹងការជំរុញលើកទឹកចិត្តសិស្សអោយសកម្មចូលរួម ។
- បង្កបរិយាកាសរីករាយស្និទ្ធស្នាល យុត្តិធម៌ និងសមធម៌ក្នុងថ្នាក់រៀន ប្រកបដោយសណ្តាប់ធ្នាប់ល្អ ។
- ខិតខំធ្វើកំណែសំរួលកិច្ចការរបស់ក្រុម និងផ្តល់យោបល់បន្ថែមខ្លះក្នុងករណីចាំបាច់ ។

## វាយតំលៃលទ្ធផល

មុននឹងបញ្ចប់មេរៀន ចាំបាច់គ្រូត្រូវធ្វើការវាយតំលៃទូទៅមួយ ដើម្បីរកអោយឃើញលទ្ធផលចុងក្រោយថាតើមេរៀននេះសំរេចដល់គោលដៅដែលបានកំណត់រឺទេ ?

របៀបវាយតំលៃមានច្រើនរូបភាពដូចជា ៖

១- ប្រើប្រាស់សំនួរផ្ទាល់មាត់ ដើម្បីត្រួតពិនិត្យការយល់ដឹង

២- ប្រើសំនួរតែសខ្មៅ ដោយសរសេរ ៖

- សំនួរពហុជ្រើសរើស
- សំនួរផ្គូផ្គង
- សំនួរបំពេញល្បះ
- សំនួរអោយឆ្លើយខុស រឺ ត្រូវ
- សំនួរប្រើបញ្ញា ... ។

ពិនិត្យកែសំរួល លោក **ណាត ប៊ុនរឿន** ដោយលោក **លឹម ម៉េង**

# វិធីសាស្ត្របង្រៀនជាអ្វី ?

**( What is methodology ? )**

ដើម្បីយល់ដឹងអំពីបញ្ហានេះ យើងត្រូវយល់ពីនិយមន័យរបស់ពាក្យវិធី ( Approach ) វិធីបង្រៀន ( Method ) ខ្លឹមសារ ( Content ) លំនាំ ( Process ) បច្ចេកទេស ( Technique ) បង្រៀនសិន ។

## ១. វិធីសិស្សជាមជ្ឈមណ្ឌល :

ជាពាក្យត្រូវបានយកមកប្រើដើម្បីសំគាល់គំរិយាបថទូទៅ ដែលប្រាប់អោយយើងដឹងអំពីផ្លូវដែលត្រូវបង្រៀន ។

*ឧទាហរណ៍* : វិធីយកសិស្សជាមជ្ឈមណ្ឌល ជាវិធីដែលមានលក្ខណៈពិសេស ដែលប្រាប់អោយដឹងអំពីរបៀបបង្រៀនរបស់គ្រូ ដោយយកសកម្មភាពសិស្សជាធំ ។ គ្រូមិនមែនជាស្នូលសំខាន់ ទេ ។ បានន័យថា ក្រោមការដឹកនាំរបស់គ្រូ សិស្សជាអ្នកគំនត់អ្វីៗ ដែលកើតមានក្នុងថ្នាក់រៀន ។ គ្រូមិនអានរៀនជំនួសសិស្សទេ ក៏ប៉ុន្តែគ្រូអាចជួយដល់សិស្សដែលប្រឹងប្រែងធ្វើសកម្មភាព និងដែលត្រូវការអោយគ្រូជួយ ។ នៅក្នុងវិធីនេះ សិស្សត្រូវបានបែងចែកជាក្រុមពីរនាក់ រឺលើសពីនេះ ដើម្បីប្តូរយោបល់ ដោះស្រាយបញ្ហានៅក្នុងក្រុមតូច រួចមកជាមួយក្រុមធំ ( Group Work ) ។ សិស្សត្រូវតែមានការប្រាស្រ័យទាក់ទងជាមួយសិស្ស ក្រោមការដឹកនាំប្រគល់ភារកិច្ចដ៏ច្បាស់លាស់អំពីគ្រូថា តើសិស្សម្នាក់ៗ រឺក្រុមនីមួយៗ ត្រូវបំពេញភារកិច្ចអ្វីខ្លះ ? ។ គំនិតទាំងឡាយចេញមកពីសិស្ស តាមរយៈការផ្តល់ឱកាសច្រើនដល់សិស្ស រីឯគ្រូនិយាយតិចបំផុត ( Less Teacher Talking Time ) ។ បើនិយាយអោយចំវិធីនេះគ្រាន់តែជាគោលការណ៍ទូទៅសំរាប់បញ្ជាក់អំពីការងាររបស់គ្រូ និងការងាររបស់សិស្ស ។ វាពុំមែនជាវិធីជាក់ស្តែងនៃការបង្រៀនទេ ។ គ្រូយកគោលការណ៍នេះសំរាប់អនុវត្តប្រើប្រាស់វិធីបង្រៀនណាមួយក៏បានដែរ ។ ឧទាហរណ៍ : ក្នុងគណិតវិទ្យាមានវិធីបង្រៀនទាំងនានាដូចជា អនុមានរួម ( inductive ) អនុមានញែក ( deductive ), (inquiry ), (heuristic ) ... etc. ។ បើគ្រូផ្តល់ឱកាសអោយសិស្សធ្វើសកម្មភាពដោះស្រាយតាមក្រុមទៅតាមភារកិច្ចដែលគ្រូប្រគល់អោយ រួចហើយគ្រូជួយសិស្សទៅដល់លទ្ធផលតាមរយៈការប្រឹងប្រែងរបស់សិស្ស នោះគេនិយាយថា គ្រូប្រើគោលការណ៍ រឺប្រើវិធីសិស្សជាមជ្ឈមណ្ឌល ពោលគឺ ទាមទារសកម្មភាពសិស្សជាមួយនឹងសិស្សក្នុងក្រុម រួចហើយសកម្មភាពគ្រូជាមួយនឹងសិស្ស រឺសកម្មភាពគ្រូជាមួយនឹងក្រុមទើបត្រឹមត្រូវ ។ ប្រសិនបើគ្រូធ្វើសកម្មភាពជាមួយនឹងសិស្សតែប៉ុណ្ណោះ ហើយសិស្សពុំមានធ្វើសកម្មភាពជាមួយសិស្សទេនោះ ពុំអាចចាត់ទុកថាគ្រូប្រើវិធីសិស្សជាមជ្ឈមណ្ឌលឡើយ ។ ម្យ៉ាងវិញទៀត បើគ្រូកាយវិកា រឺធ្វើសកាយបញ្ជាក់ រឺធ្វើពិសោធន៍តាមរយៈចំនេះដឹង បំនិនដ៏ស្ទាត់ជំនាញរបស់ខ្លួនបង្ហាញអោយសិស្សពិនិត្យរួចហើយ គ្រូពន្យល់អោយសិស្សបានយល់ដើម្បីចងចាំកត់ត្រាទុក យកទៅទន្លេញចាំមាត់សំរាប់ប្រលង បែបនេះពុំមែនជាវិធីសិស្សជាមជ្ឈមណ្ឌលឡើយ ។ ប៉ុន្តែ គ្រូនៅតែអាចប្រើវិធីបង្រៀន អនុមានរួម អនុមានញែកក៏បានដែរ ។ ប៉ុន្តែគេនិយាយថា គាត់ពុំបានអនុវត្តវិធីសិស្សជាមជ្ឈមណ្ឌលទេ ។

## ២. វិធីបង្រៀន ( Method )

ជាពាក្យពិពណ៌នាទិដ្ឋភាពជាក់លាក់នៃការបង្រៀន ។ វាជាក់ស្តែងជាងពាក្យ Approach បើយើងនិយាយអំពីទិដ្ឋភាពដែលមើលឃើញ ។

*ឧទាហរណ៍ :* វិធីបង្រៀនផ្ទាល់ ( Dirct Method ) ជាវិធីមួយដែលមិនយកសំដីមកប្រើជំនួសវត្ថុផ្ទាល់ជាក់ស្ដែង រឺភាសាជាតិសំរាប់បកប្រែពន្យល់ទេ ។ គ្រូត្រូវតែរកវត្ថុជាក់ស្ដែង កាយវិការ រឺទូរទស្សន៍ រឺជេអូ ដើម្បីអោយសិស្សយល់ខ្លឹមសារមេរៀន រឺ ពិសោធន៍ជាក់ស្ដែងតែម្ដង ។ ប៉ុន្ដែ នៅក្នុងវិធីបង្រៀនផ្ទាល់ គ្រូអាចប្រើវិធីសិស្សជាមជ្ឈមណ្ឌល រឺ វិធិគ្រូជាមជ្ឈមណ្ឌល បានន័យថាពុំប្រកាន់វិធី ( Approach ) ណាមួយទេ ។

## ៣. បច្ចេកទេសបង្រៀន ( Technique )

ជាពាក្យសំដៅទៅលើជំហានដែលគ្រូប្រើនៅពេលបង្រៀន ។

*ឧទាហរណ៍ :* ស្ដាប់ ហាត់ ពិសោធ វាស់វែង ថ្លឹង រាប់ចំនួនជាក់ស្ដែង ធ្វើកាយវិការ ចែកជាគូ រឺជាក្រុម សុទ្ធតែជាបច្ចេកទេស ។

## ៤. ខ្លឹមសារ ( Content )

សំដៅអ្វីដែលត្រូវយកមកបង្រៀន ។

*ឧទាហរណ៍ :* វេយ្យាករណ៍ តំលៃនៃវប្បធម៌ជាតិ សេរីភាព ។ល ។

## ៥. លំនាំ ( Process )

សំដៅទៅន័យ តើបង្រៀនយ៉ាងដូចម្ដេច « How to teach » ? វាបញ្ជាក់អំពីជំហានដែលគ្រូរៀបចំឡើង ដើម្បីផ្ដល់ឱកាសអោយសិស្សបញ្ចេញយោបល់ អោយសិស្សអាចធ្វើការដោះស្រាយតាមរយៈលំនាំនេះ ។ គ្រូបានបង្កអោយមេរៀនក្លាយទៅជាងាយរៀន ងាយយល់ជាងមុន ។

## ៦. វិធីសាស្ត្របង្រៀន ( Methodogy )

ជាពាក្យសំរាប់សំគាល់វិទ្យាសាស្ដ្រដែលសិក្សាអំពីវិធី ( Approaches ) និង បច្ចេកទេស ( Techniques ) បានន័យថា វិធីសាស្ត្រមានមុខងាររកអោយឃើញវិធី ( Approach ) វិធីបង្រៀន ( Method ) និងបច្ចេកទេស អោយមានភាពកាន់តែងាយស្រួលបង្រៀនជាងមុន ។ គួរបញ្ជាក់ថា វិធីសាស្ត្របង្រៀនត្រូវបានតែប្រែដូរជានិច្ចឥតឈប់ឈរទេ ។ ហើយសព្វថ្ងៃនេះ (១៩៩៧) វិធីសិស្សជាមជ្ឈមណ្ឌល ជាវិធីមួយដែលកំពុងនិយមបំផុត ហើយបានលទ្ធផលល្អបំផុតក្នុងការធ្វើអោយសិស្សសកម្មអាចរៀនសូត្រឆាប់ចេះដឹងច្បាស់លាស់ល្អ ។

ឧទាហរណ៍ : Communicative Approach ជាវិធីដែលបង្រៀនភាសាតាមរយៈយកសកម្មភាពសិស្សជាធំដោយចាត់ទុកថា កូនសិស្សត្រូវតែផ្ដល់ឱកាសអោយបានច្រើនបំផុតទទួលបានបំនិន ៤យ៉ាង ៖ និយាយ ស្ដាប់ អាន និងសរសេរ ។ ដូច្នេះនៅក្នុងវិធីនេះ សកម្មភាពរៀនរបស់សិស្ស សំខាន់ជាងសកម្មភាពបង្រៀនរបស់គ្រូ ។ ដើម្បីធ្វើអោយបានសំរេចបំនិនទាំង ៤ ព្រមទាំងសិស្សទទួលបានខ្លឹមសាររបស់មេរៀន គ្រូយកបច្ចេកមកប្រើដូចជា ការងារក្នុងក្រុមពីរនាក់ ( pair wok ) រឺការងារតាមក្រុម ( Group Work ) ល្បែង សកម្មភាពដែលផ្ដល់ពត៌មានមិនអោយគ្រប់ ( ទុកអោយសិស្សឆ្លើយ ) សំដែងតួ ។ ល ។ ដូច្នេះ **វិធីសាស្ត្រជាស្ពានមួយ** ។

បណ្ឌិត **អ៊ុម កុច**

# ដើមឈើ និងទឹក
## ( L'arbre et l'eau )

1. គោលបំណង

. ពន្យល់សិស្សអោយយល់ថា រុក្ខជាតិមានជីវិតរស់នៅដូចមនុស្ស ហើយវារួមចំណែកធ្វើអោយមនុស្ស សត្វ លើភពផែនដីមានសមតាធម្មជាតិ ( équilibre naturel ) ។

. ចេះដឹងពីភាពចំណុះគ្នាទៅវិញទៅមក ( interdépendance ) ដែលវិលចុះឡើងនៃដើមឈើ និង ទឹក ( cycle de l'arbre et du cycle de l'eau ) ។

2. សមត្ថភាព មានសញ្ញាណពីចក្រនៃទឹក ( ការវិលវល់របស់ទឹក )

* មេរៀន

១. ដើមឈើដកដង្ហើម ហើយធ្វើអោយយើងដកដង្ហើម

. វិលកឡើងវិញ មុខងារជាសារវន្តនៃដើមឈើ : តាមរយៈថាមពលព្រះអាទិត្យ ដើមឈើស្រូបយកឧស្ម័នកាបូនិច ( Gaz carbonique ) និងអ៊ីដ្រូសែន ( Hydrogène ) ( បានមកពីជាតុទឹក ) ។ រួចហើយដើមឈើបញ្ចេញអុកស៊ីហ្សែន ( Oxygène ) ដែលជាខ្យល់បរិសុទ្ធសំរាប់ជីវិតសត្វលោក ។ ដូចនេះ យើងអាចសន្និដ្ឋានថា ដើមឈើមានប្រយោជន៍ផ្លាស់ខ្យល់អាក្រក់ឧស្ម័នកាបូនិច ( Gaz carbonique ) អោយទៅខ្យល់ល្អសំរាប់ជីវិត ។

២. ដើមឈើជាអេប៉ុង ( éponge ) មួយដ៏ពិតប្រាកដ

. ដើមឈើជារោងចក្របង្កើតភ្លៀង ( usine à pluie ) ដើមឈើស្រូបទឹកតាមរឹស ។ ទឹកនេះឡើងតាមដើមទៅរហូតដល់ស្លឹក ហើយស្លឹកមានមុខងាររក្សាទុកទឹកនេះសំរាប់ចិញ្ចឹមដើមវា ។ បីភាគបួននៃទឹកនេះបានត្រូវប្លែងភាពជាចំហាយទឹក ដែលនឹងទៅជាទឹកភ្លៀង ទឹកសន្សើម ។ ចំណែកមួយភាគបួននៅសល់ ព្រោះយ៉ាងស្អាតជ្រាបចូលមកនៅក្នុងដី ដើម្បីបំពេញ nappes phréatiques souterraines ( ទឹកដក់ក្នុងស្រទាប់ដី ហើយចេញជាប្រភព ) ( source ) ។

. ដើមឈើជាជលដ្ឋាន ( réserve d'eau ) ម្យ៉ាងទៀត រឹសឈើធ្វើអោយដីធូរ (ខ្យល់ចេញចូលបាន) អោយដីជ្រាបទឹកបាន ។ ដូចនេះ ទឹកភ្លៀងចូលជ្រាបទៅក្នុងដីបានយ៉ាងឆាប់ តែហូរចេញមកវិញយឺតណាស់ ។ ដើមឈើដោយសារម្ទប់និងរឹសវា បានរក្សាទឹកទុកជាជលដ្ឋាននៅក្នុងដី ដែលអាចជៀសវាងបានភាពរាំងស្ងួត និងទឹកជំនន់ ។ ជារួមដើមឈើអាចអោយទឹកចរាចរ ( circuler ) រវាងដី និងអាកាស ។

. ពិសោធន៍លើស្លឹកឈើ និងជលដ្ឋាន ( réserve d'eau )

តើធ្វើដូចម្តេចដើម្បីបញ្ជាក់ថា ស្លឹកឈើមានទឹក ?

\+ យកស្លឹកឈើស្រស់មកថ្លឹងនឹងជញ្ជីងតូចមួយ ហើយកត់ទំងន់វា ។

\+ យកស្លឹកទៅហាលអោយស្ងួតក្នុងរវាងពីរ រឺបីថ្ងៃ ។

+ យកស្លឹកស្ងួតនេះមកថ្លឹងម្ដងទៀតជាថ្មី ហើយកត់ទំងន់ តើទំងន់ខុសគ្នានេះមកពីអ្វី ?

ព្រៃឈើជាធាតុសំខាន់បំផុតនៃសមតាធម្មជាតិ ( La forêt, élément essentiel des équilibres naturels )
នៅក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ២ ទំព័រ ១៩ យើងបានរៀនម្ដងហើយ ពីសារៈសំខាន់នៃព្រៃឈើលើបរិយាកាស ។ សូមអានឡើងវិញ ។

ព្រៃឈើមានតួនាទីសំខាន់ណាស់ ក្នុងការរក្សាទឹកទុក ការសំអាតខ្យល់អាកាសសំរាប់ដកដង្ហើម ការពារកុំអោយមានការហូរច្រោះដី ការអោយមានភ្លៀង និងធាតុអាកាសល្អ ។

## លំហាត់

ទី ១ : ដើមឈើ និង ឧស្ម័ន ( មើលរូបផ្ដិតជាប់ )

- រោងចក្រ រោងអគ្គិសនី រថយន្តបញ្ចេញឧស្ម័នអ្វី ?
- ដើមឈើស្រូបឧស្ម័នអ្វីខ្លះ ? វាបញ្ចេញឧស្ម័នអ្វី ?
- ផលអាក្រក់នៃឧស្ម័នកាបូនិច ចំពោះជីវិតសត្វលោក ?

ទី ២ : ដើមឈើ និង ទឹក

- ដើមឈើស្រូបទឹកតាមអ្វី ? ទឹកនោះប្ដូរភាពជាអ្វីខ្លះ ?
- ការបំផ្លិចបំផ្លាញព្រៃឈើនាំមកនូវផលវិបាកអ្វីខ្លះ ?

ទី ៣ : សូមសរសេរពាក្យបីម៉ាត់នេះ ដាក់ក្នុងផ្ទៃបួនជ្រុងទ្រវែង អោយស្របតាមការវិលវល់របស់ទឹក ។

ការស្រូប ការហូត ជលដ្ឋាន



លោក យ៉ង់ ធី





# វិធីរកចំលើយដោយត្រលប់ក្រោយ
## ( Back Tracking )

វិធីរកចំលើយបែបនេះ ជាទូទៅ យើងបានជួបប្រទះជាញឹកញាប់ តែយើងគិតមិនបានដល់ថា ជាវិធីដែលយើងធ្លាប់យកមកដោះស្រាយឡើយ ។

ឧទាហរណ៍ ១ : $\frac{3n-2}{2}+3 = 11$

ក្រឡេកមើលមួយភ្លែតចំពោះឧទាហរណ៍នេះ លោកគ្រូ - អ្នកគ្រូ ច្បាស់ជាយល់ថា ដើម្បីរកចំលើយចំនួន n ច្បាស់ជាគេរកតាមរបៀបដោះស្រាយតាមសមីការ ១ អញ្ញាត នៅថ្នាក់ទី ៨ រឺ ទី ៩ គំរូវអោយមានការគំរូវភាគបែងនៅអង្គទី ១ និងអង្គទី ២ ជាពុំខាន ។

ខ្ញុំសូមបង្ហើបដោះស្រាយតាមបែបនៅបឋមសិក្សាវិញម្តង ដើម្បីអោយលោកគ្រូ - អ្នកគ្រូយល់ថា អ្វីៗ មិនមែនដោះស្រាយតាមបែបតែម្យ៉ាងនោះទេ ។

ខ្ញុំអាចលើកជាសំនួរថា «... ? ... + 3 = 11» ( នេះជាវិធីដែលលោកគ្រូ - អ្នកគ្រូទាំងអស់ធ្លាប់បានប្រើជាទូទៅ នៅថ្នាក់ទី ១ ដើម្បីរកចំនួនមួយទៀតមកបន្ថែម និង 3 អោយបានស្មើនឹង 11 )

ដូចនេះ ខ្ញុំអាចសរសេរថា $\frac{3n-2}{2}$ នេះ គឺវាស្មើនឹង 8 ទើបយកទៅបូកនឹង 3 បានផលបូកស្មើ 11 ។

រឺ $8+3 = 11$ គឺ $\left(\frac{3n-2}{2} = 8\right)$

អាចបន្តសំនួរថា តើគេយកតំនាងចែកប៉ុន្មាន ចែកនឹង ២ ទើបបានផលចែកស្មើ ៨ ?

អាចសរសេរ $\frac{?}{2} = 8$ ( ចំលើយនៅបឋមសិក្សាគឺ 16 )

ខ្ញុំអាចបន្តសួរថា : « តើយកចំនួនប៉ុន្មានទៅដក 2 ទើបបាន 16 ? )

**ចំលើយគឺ : << 18 >>**

<< តើ 3 × ? = 18 >> ? គឺ 6

ដូចនេះ ខ្ញុំអាចឆ្លើយថា n គឺ 6

ខ្ញុំអាចសរសេរឡើងវិញថា $\frac{(3\times 6)-2}{2}+3 = 11$

ឧទាហរណ៍ ២ : $2(2n+3)-1 = 25$

ខ្ញុំអាចគូរជាការេ 5 បន្តគ្នា រួចសាកល្បងរកចំលើយណាមួយមកជំនួស n




ខ្ញុំអាចសួរបញ្ច្រាសពីលទ្ធផលចុងក្រោយថា « តើប៉ុន្មាន -1 ទើបស្មើ 25 ? ( ចំលើយគឺ 26 )

ខ្ញុំអាចសរសេរ 26 ក្នុងការេបន្ទាប់




ខ្ញុំអាចរកឃើញ n = 5

**សាកល្បងដោះស្រាយខ្លួនឯង :**

1/- $\dfrac{20n-10}{3}+2 = 12$

2/- $\dfrac{2(n-1)}{3}+5 = 16$

3/- $5\left[\dfrac{3n-2}{2}\right]+3-4 = 51$

រៀបរៀងដោយលោក **សៀង អុន**

សមាជិកក្រុមអ្នកនិពន្ធឯកសារបណ្តុះបណ្តាលពីចំងាយ

# វិធីតែងកាព្យ

មិត្ត ! ប្រិយមិត្តរួមមុខវិជ្ជាជីវៈគ្រូបង្រៀនទាំងអស់ជាទីមេត្រី ! ក្នុងរយៈកាលកន្លងមកនេះ គណៈកម្មការតំរង់ទិស អំនាន និង តាមដានរបស់ទស្សនាវដ្ដីគ្រូបង្រៀន បានទទួលអត្ថបទជាច្រើន ខ្លះសរសេរជាពាក្យរាយ ខ្លះសរសេរជាពាក្យកាព្យពីសំនាក់សមាជិក - សមាជិកា សមាគមបុគ្គលិកសិក្សាខ្មែរក្នុងទូទាំងប្រទេស ដើម្បីចុះក្នុងទស្សនាវដ្ដីគ្រូបង្រៀននៃលេខនីមួយៗ ។ នេះជាវិភាគទានដ៏ថ្លៃថ្លាបំផុត ហើយក៏បញ្ជាក់នូវស្មារតីស្រលាញ់មុខវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងការលើកកំពស់គុណភាពអប់រំ និងស្មារតីសាមគ្គីភាពរវាងគ្នា និងគ្នា នៃមហាគ្រួសារគ្រូបង្រៀនយើង ។

តែមានបញ្ហាមួយដែលគណៈកម្មការយើងមានគារកត់សំគាល់ នោះគឺអត្ថបទកំនាព្យមួយចំនួន ដែលអស់លោកគ្រូ - អ្នកគ្រូ បានផ្ញើមកអោយមានលក្ខណៈខ្វះខាតទាំងអត្ថន័យ និងទាំងអត្ថរូប ដែលតំរូវអោយមានការជួសជុលយ៉ាងច្រើនទើបអាចចុះក្នុងទស្សនាវដ្ដីបាន ។ មូលហេតុនៃកង្វះខាតនោះគឺ បណ្ដាលមកពីកង្វះខាតផ្នែកវិធីសាស្ត្រនៃការតែងកំនាព្យនេះឯង ។

ដោយមូលហេតុខាងលើនេះ យើងសូមលើកមកបង្ហាញអំពីក្បួនតែងកាព្យនៃបទផ្សេងៗ ដែលដកស្រង់ចេញពីសៀវភៅតែងកាព្យនានារបស់បណ្ឌិតរៀមច្បងទាំងឡាយ ដើម្បីទុកជាគុណប្រយោជន៍សំរាប់តែងកំនាព្យ រីមេស្ត្រូវរបស់លោកគ្រូ - អ្នកគ្រូ មិត្ត ! ប្រិយមិត្តទាំងអស់ !

## I. ដំបូងយើងត្រូវយល់ដូចម្ដេចហៅថា កំនាព្យ ?

កំនាព្យគឺជាកំរងពាក្យសំដី ដែលមានចំនាប់ចុងចួន ពិរោះរណ្ដំ ណែងណងក្នុងឃ្លា និងក្នុងល្បះទៅតាមក្បួនកំនត់ . . . ដែលចេញពីចិត្តរំភើប និងធ្វើអោយអ្នកផងរំភើបជាមួយផងដែរ ។ ការតែងកំនាព្យពុំមែនជាការងាយស្រួលប៉ុន្មានទេ ។ អ្នកតែងកាព្យត្រូវធ្វើយ៉ាងណាអោយគេពិរោះ អោយគេសប្បាយជាមួយ រឺអោយគេកើតទុក្ខជាមួយ . . . ។ គេត្រូវគោរពតាមជើងគាព្យ រឺ មេកាព្យអោយបានត្រឹមត្រូវបំផុត គួបផ្សំនឹងសិល្បវិធីផ្សេងៗ ទៀតរបស់កវី ។

តាមការស្រាវជ្រាវមេកាព្យទាំងអស់មានចំនួន ៤៦ មេ ក្នុងនោះមាន ៣២ មេ ដែលមានលក្ខណៈប្លែកគ្នាស្រឡះពោលគឺមិនច្រលំគ្នា ។

គេបង្កើតឃើញមាន ៖

១. បទ កាកគតិ

២. បទ ព្រហ្មគិតិ

១៧. បទ គ្រីពិធព័ន្ធ

១៨. បទ នាគរាជប្លែងរិទ្ធិពាក្យ ៨

| | |
|---|---|
| ៣. បទ ពំនោល | ១៩. បទ ពាក្យ ៩ សាមញ្ញ |
| ៤. បទ បន្ទោលកាក | ២០. បទ ផ្កាឈូករីក |
| ៥. បទ ភុជង្គលីលា | ២១. បទ ក្របចក្កវាឡ |
| ៦. បទ ពាក្យ ៧ សាមញ្ញ | ២២. បទ រលកខ្ទប់ច្រាំង |
| ៧. បទ ទមោ | ២៣. បទ កង្កែបលោតស្ទាក់ពេជ្រ |
| ៨. បទ ក ខ | ២៤. បទ សារថីទាញរថ |
| ៩. បទ គោព័ន្ធស្ទឹងពាក្យ ៧ | ២៥. បទ សីហ្គតោលេងកន្ទុយ |
| ១០. បទ នាគគៀវក្រវាត់ | ២៦. បទ ពាក្យ ១០ សាមញ្ញ |
| ១១. បទ អក្សរសង្វាស | ២៧. បទ ក្រឡាចឡើងទ្រើង |
| ១២. បទ កង្កែបលោតកណ្ដាលស្រះ | ២៨. បទ ពាក្យ ១១ សាមញ្ញ |
| ១៣. បទ អក្សរល្ងូន | ២៩. បទ ឆ័ត្របិដាន |
| ១៤. បទ ចយក្រោយ | ៣០. បទ ពាក្យជាបទង |
| ១៥. បទ ពាក្យ ៨ សាមញ្ញ | ៣១. បទ មករខ្ទាក់កែវ |
| ១៦. បទ នាគបរិព័ន្ធ | ៣២. បទ កង្កែបលោតលើគោក |

នៅមានមេកាព្យចំនួន ១៤ មេទៀត ដែលគ្មានលក្ខណៈចំឡែកពីគ្នាប៉ុន្មាន ច្រើនច្រលំគ្នា ពិបាកនឹងយកមកធ្វើជាក្បួនច្បាប់មិនបាន ដោយមូលហេតុគេបានបោះបង់ចោលយូរផង និងគេមិនសូវនិយមនាពេលសព្វថ្ងៃនេះផង ។

មេកាព្យទាំង ១៤នេះ គេសង្កេតឃើញមាន ៖

| | |
|---|---|
| ១. បទ សបាត់ សប៉ឹង | ៨. បទ យតិភង្គ |
| ២. បទ ពស់លេបកន្ទុយ | ៩. បទ រមាំងដើរព្រៃ |
| ៣. បទ សឡាបល្ងូន | ១០. បទ សហាក |
| ៤. បទ ព្រះច័ន្ទបាំងឆ័ត្រ | ១១. បទ សត្វកាងស្ទាប |
| ៥. បទ វង្សវិចិត្រ | ១២. បទ វិវិធមាលី |
| ៦. បទ កង្កែបលោតផ្ទាត់ខ្មៅ | ១៣. បទ សោរទិនវិសាល |
| ៧. បទ រលកឃោលឃាវ | ១៤. បទ សុក្រទិនវិសាល |

បទកំនាព្យនីមួយៗ នៃ ៣២ បទខាងលើ សុទ្ធតែមានរបៀបតែងរបស់ខ្លួនច្បាស់លាស់ តាមគំនិតបង្កើតឡើងដោយបុព្វបុរសយើង ។ មុននឹងសិក្សាពីរបៀបតែងកាព្យតាមមេកាព្យនីមួយៗ យើងគួរយល់ពីធាតុសំខាន់ៗ របស់កំនាព្យ និងចំនាប់ចុងចួននៃសូរស័ព្ទ រីសូរសៀង រីសំនៀងរបស់កាព្យជាមុនសិន ។ កំនាព្យដែលមានច្រើនបទខុសៗគ្នា អាស្រ័យដោយធាតុសំខាន់ៗ និងចំនាប់ចុងចួនរបស់វានេះឯង ។

## II. ធាតុសំខាន់ៗ របស់កំនាព្យ

គ្រប់បទកំនាព្យទាំងអស់ មានលក្ខណៈរួមគ្នានៅត្រង់មាន ព្យាង្គ ឃ្លា និង ល្បះ ដែលមានតិច រឺ ច្រើនទៅតាមជើងកាព្យ ។

- ព្យាង្គនៅក្នុងកំនាព្យ គឺជាពាក្យមួយម៉ាត់ៗ រឺសូរសំលេង ១
- ឃ្លា គឺព្យាង្គរួមគ្នាច្រើន
- ល្បះ គឺឃ្លាច្រើនរួមគ្នា ដោយមានខ័ណ្ឌ ( ។ ) នៅទីបញ្ចប់ ។

*ឧទាហរណ៍ :*

- ទឹកសាបមួយតក់ ស្រក់ក្នុងសមុទ្រ ពិបាកបំផុត នឹងបន្សាបបាន ។
- ផ្ការុះរោយហើយ មិនដែលប្រែប្រាណ ក្រពុំទៀតបាន ដូចដើមវិញទេ ។




មួយល្បះកំនាព្យខាងលើនេះ មានបួនឃ្លា និងក្នុងមួយឃ្លាមានបួនព្យាង្គ ។

**កំនត់សំគាល់**

ក្នុងការតែងកាព្យ ចូរកុំច្រលំព្យាង្គ និងពាក្យអោយសោះ ។

- ព្យាង្គ : គឺជាសំលេងពម្លូង ទោះបីមានន័យក្ដី រឺអត់ន័យក្ដី ហៅថាព្យាង្គ ។

*ឧទាហរណ៍* : ព្យាង្គគ្មានន័យ : ម . គ . សំ . ប្រ . . .

ព្យាង្គមានន័យ : ទៅ . ដើរ . ចង់ . . .

- ពាក្យ : គឺជាសំលេងពម្លូងក្ដី រឺច្រើនដងក្ដី មានន័យគ្រប់គ្រាន់សំគាល់របស់ រឺន័យសេចក្ដីអ្វីមួយ ។

*ឧទាហរណ៍* : ដើរ . ឈប់ . ឆាន់ . សំរស់ . សាលា . សៀវភៅ . . .

- ពាក្យ ១ ព្យាង្គ : ក្រូច . ល្ហុត . ស៊ុ . ដឹក
- ពាក្យ ២ ព្យាង្គ : ប្រណម្យ . ជញ្ជាំង . បន្ទែ . ចំនង់
- ពាក្យ ៣ ព្យាង្គ : អញ្ជលី . វិនិច្ឆ័យ . នរបតី . ចំនាប់ចូន

## III. ចំនាប់ចុងចួន

ចំនាប់ចុងចួន គឺជាពាក្យគន្លឹះចួន ផ្គួនរណ្តំណែងណងគ្នា រឺ គេហៅថាពាក្យសម្ពស្ស ។ ពាក្យចួនគ្នានៅឃ្លា ដែលគេហៅថាពាក្យសម្ពស្សក្នុង រឺចួនគ្នាឆ្លងពីឃ្លាមួយទៅឃ្លាមួយ រឺចួនគ្នាពីល្បះមុនទៅល្បះបន្ទាប់ បន្តបន្ទាប់គ្នារហូតដល់ចប់អត្ថបទកំនាព្យ គេហៅថា ពាក្យសម្ពស្សក្រៅ ។

ពាក្យដែលអាចចួនគ្នាបាន ទាល់តែព្យាង្គនេះមានព្យញ្ជនៈស្ថិតនៅក្នុងក្រុមអឃោសៈ ខ្យល់ ( អ ) រឺ ឃោសៈខ្យល់ ( អ៊ ) ដូចគ្នា និងដែលមានស្រះប្រកបដូចគ្នាទៀត ។

ឧទាហរណ៍ : - ព្យាង្គ : ដឹក ចួននឹង ដឹក . . .

- ព្យាង្គ : ជិត ចួននឹង គិត .

- ព្យាង្គ : គង់ ចួននឹង រង់ .

ក្នុងករណីដែលព្យាង្គចួនគ្នាពុំបានគោរពតាមគោលការណ៍ខាងលើនេះ បទកំនាព្យនោះពុំពិរោះ និងរណ្តំគ្នាទេ ។ ប៉ុន្តែ ក្នុងករណីខ្លះ គេអាចអនុគ្រោះបានខ្លះចំពោះចំនួនព្យាង្គ ឧទាហរណ៍ដូចជា ក្នុងល្បះកំនាព្យ :

នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។

ក្នុងឃ្លាចុងក្រោយនៃល្បះកំនាព្យខាងលើនេះ « កើត / ដោយ / ប្រ / ណិ / ប័តន៍ » បើយើងគិតចំនួនព្យាង្គមាន ៥ ព្យាង្គគឺ : កើន . ដោយ . ប្រ . ណិ . ប័តន៍ ។

តែក្នុងពេលគេសូត្រកំនាព្យ ដើម្បីអោយត្រូវជើងកាព្យ គេសូត្រកញ្ឆក់ទៅសល់តែបួន ដោយអោយសូរ «ណិ» ឮសូរយ៉ាងតិចបំផុត ។ ក្នុងកំនាព្យខ្មែរ ទោះបីបទណាក៏ដោយ គេជៀសពុំផុតពីការកាត់សូរព្យាង្គរបៀបនេះឡើយ ។ តែយើងគួរកត់សំគាល់ថា គេអាចកាត់ព្យាង្គដោយអោយឮសូរតិចបាន ទាល់តែព្យាង្គនោះស្ថិតនៅក្នុងពាក្យតែមួយ ឧទាហរណ៍ដូចជាក្នុងល្បះកំនាព្យ :

« ទៅដល់មហាក្សត្រិយ៍ » ឃ្លានេះមានប្រាំព្យាង្គ តែគេអោយព្យាង្គ « ហា » ឮសូរតិចដើម្បីអោយនៅតែបួនព្យាង្គ ។

« ឱយសាមណេរត្រាប់ » ឧ. : ព្យាង្គ (ម:) ត្រូវអោយឮសូរតិច ទើបត្រូវជើងកាព្យ ។

ម្យ៉ាងទៀត នៅក្នុងតែងកាព្យ រឺបទចំរៀងផ្សេងៗ អ្នកកវី រឺ អ្នកចំរៀង ក៏មានការលំបាកក្នុងការរៀបពាក្យអោយបានត្រឹមត្រូវទៅតាមចំនាប់ចុងចួននៃបទកំនាព្យនីមួយៗ ។ អាស្រ័យហេតុនេះ ទើបមានការអនុគ្រោះខ្លះអំពីចំនាប់ចុងចួនរវាងព្យាង្គ និងព្យាង្គ ដែលមានសូរសំលេងជាអឃោសៈ និងជាឃោសៈ ។ តែសូរសំលេងមិនត្រូវខុសគ្នាប៉ុន្មាន និងកុំអោយមានច្រើនពេក ដែលមានគ្រប់តែឃ្លា និងគ្រប់តែល្បះនោះឡើយ ។ បើជៀសវាងបានជាការល្អបំផុត សំរាប់កវី និងអ្នកតែងបទកំនាព្យទាំងឡាយ ។

ខាងក្រោមនេះ យើងសូមលើកយកវិធីតែងបទកំនាព្យនីមួយៗ មកបង្ហាញ ដោយផ្តើមចេញពីបទងាយៗ និងបទនិយមប្រើ ដើម្បីទុកជាក្បួនដល់លោកគ្រូ - អ្នកគ្រូ និង មិត្ត ប្រិយមិត្តទាំងអស់ ក្នុងពេលមានបំនងតែងបទកំនាព្យផ្សេងៗ ចុះក្នុងទស្សនាវដ្តី រឺ តែងមេសូត្របំរើដល់ការរៀនសូត្ររបស់សិស្ស ។

## បទមេប្អូន

តាមការស្រាវជ្រាវ បទមេប្អូនជាបទបុរាណមួយកើតមុនគេបង្អស់ ។ បទនេះ ក្នុងមួយល្បះមានបួនឃ្លា ហើយក្នុងមួយឃ្លាមានមួយព្យាង្គស្មើគ្នា ដែលគេអាចសរសេរជារូបមន្ត : ៤.៤.៤.៤ ។

*ឧទាហរណ៍ :*

« ... ទេវីអូនអើយ អូនបានទៅគេ អាចជួបវិញទេ រឺក៏យ៉ាងណា ? » ។
បងតែងសង្ឃឹម ក្នុងភាពសង្ហា ថាជួបជីវា ទាំងឥតសង្ឃឹម ។

ល្បះទី ១ : 0 0 0 0 0 0 0 0 0 0 0 0 0 0 0 0 ។
ល្បះទី ២ : 0 0 0 0 0 0 0 0 0 0 0 0 0 0 0 0 ។
0 0 0 0 0 0 0 0 0 0 0 0 0 0 0 0 ។

- ព្យាង្គទី ៤ នៃឃ្លាទី ៣ ត្រូវអោយចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ ។
- ព្យាង្គទី ៤ នៃឃ្លាទី ២ ត្រូវចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៤ នៃល្បះទី ១ ។
- ចំនែកព្យាង្គទី ៤ នៃឃ្លាទី ៣ ត្រូវចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ និងព្យាង្គទី ៤ នៃឃ្លាទី ៤ នៃល្បះទី ១ ដែរ ។

**កំនត់សំគាល់** ក្នុងការសូត្រកំនាព្យនេះ គេត្រូវសង្កត់ព្យាង្គទី ២ នៃគ្រប់ឃ្លាទាំងអស់ ។

## បទកាកគតិ មេភាព្យប្អូន

*ឧទាហរណ៍ :* នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទុន្មានអ្នកផង
ប្រែឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។

ទូរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធវត្ថ
ចូរធ្វើអោយត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន ។

ល្បះទី ១ :
0 0 0 0 0 0 0 0 0 0 0 0
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
0 0 0 0 0 0 0 0 0 0 0 0
១ ២ ៣ ៤ ១ ២ ៣ ៤ ១ ២ ៣ ៤
0 0 0 0 ។
១ ២ ៣ ៤

ល្បះទី ២ :
0 0 0 0 0 0 0 0 0 0 0 0
0 0 0 0 0 0 0 0 0 0 0 0
0 0 0 0 ។

រីគេអាចចំនាប់ចុងចួន :

ល្បះទី ១ : 0000 0000 0000 0000 0000 0000 0000 ។

ល្បះទី២ : 0000 0000 0000 0000 0000 0000 0000 ។

.... .... 0000 .... .... .... .... ។

បទកាកគតិ គេសរសេរក្នុងមួយបទ រីមួយល្បះមាន ៧ ឃ្លា ហើយក្នុងមួយឃ្លាមាន ៤ ព្យាង្គ ។ ដើម្បីអោយងាយចាំ គេអាចសរសេររូបមន្តបទកាកគតិ : **៤.៤.៤.៤.៤.៤.៤** ។

- ព្យាង្គទី ៤ ចុងឃ្លាទី ២ ត្រូវអោយចួននឹងព្យាង្គទី ៤ នៃឃ្លាទី ១ ។
- ព្យាង្គទី ៤ ចុងឃ្លាទី ៥ ត្រូវអោយចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៣ ។
- ព្យាង្គទី ៤ ចុងឃ្លាទី ៦ ត្រូវអោយចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៥ ។
- បើព្យាង្គទី ២ នៃឃ្លាទី ៥ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៤ នោះល្អណាស់ តែបើមិនចួនគ្នា ក៏មិនជាបញ្ហាអ្វីដែរ ។ ដោយឡែកព្យាង្គទី ៤ នៃឃ្លាទី ៤ និងព្យាង្គទី ៤ នៃឃ្លាទី ៧ បើមិនជាប់ចួននឹងព្យាង្គណាមួយក្នុងល្បះក៏ឥតទាស់ដែរ តែព្យាង្គទី ៤ នៃឃ្លាទី ៧ ត្រូវអោយចំនាប់ចួនទៅល្បះក្រោមទៅព្យាង្គទី ៤ នៃឃ្លាទី ៣ បន្តៗ គ្នាពីល្បះមួយទៅល្បះមួយ ។

## កំនត់សំគាល់

ក្នុងការសូត្របទកាកគតិ សំលេងពុំស្មើទេ ត្រូវលោតចុះលោតឡើង ទៅតាមចង្វាក់ ប្រៀបបាននឹងដំនើរជើងក្អែក ។

( នៅមានត )

**បណ្ឌិត ឆ សោ**

# លិខិតអំនរគុណចំពោះឯកឧត្តម មីសែល ត្រាណេ

- ក្នុងនាមគណៈកម្មាធិការនាយក នៃសមាគមបុគ្គលិកសិក្សាខ្មែរ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំនរគុណដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះឯកឧត្តម **មីសែល ត្រាណេ** បណ្ឌិតផ្នែកបុរាណវត្ថុវិទ្យា និង ជាអនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលបានអនុញ្ញាតអោយយើងខ្ញុំ ដកស្រង់អត្ថបទចេញពីសៀវភៅ « **បុរេប្រវត្តិនៃកម្ពុជា** » ដែលឯកឧត្តមបានចងក្រង និង រៀបរៀង ។

- លោកគ្រូ - អ្នកគ្រូ មុខជាសប្បាយរីករាយនឹងបានក្រេបជញ្ជក់នូវចំនេះដឹងថ្មីៗ បន្ថែមលើចំនេះដឹងដែលក្រសួងអប់រំបានផ្សព្វផ្សាយរួចហើយ ក្នុងសៀវភៅសិក្សាសង្គម ។

## បុរេប្រវត្តិនៃកម្ពុជា



ម.ត្រាណេ

# ឫសគល់នៃជនជាតិខ្មែរ

## សិក្សាស្រាវជ្រាវ

ចំពោះបញ្ហាកំណើតនៃជនជាតិខ្មែរ មានទ្រឹស្តីជាច្រើន ដែលមិនចុះសំរុងគ្នា អ្នកនិពន្ធខ្លះសរសេរថា « ខ្មែរជាឥណ្ឌាទី ២ » ដោយឃើញខ្មែរកាន់សាសនា និង ទំនៀមទំលាប់ឥណ្ឌា ដូចជាពិធីកោរជុក និងបុណ្យច្រត់ព្រះនង្គ័លជាដើម ។ អ្នកនិពន្ធខ្លះទៀតហ៊ានអះអាងទៀតថា ខ្មែរបានធ្វើដំណើរនៅសម័យបុរេប្រវត្តិពីទិសខាងជើង គឺប្រទេសទីបេ ចុះមកតាំងទីលំនៅ នៅតំបន់អាស៊ីអាគ្នេយ៍នេះ ។ មានអ្នកស្រាវជ្រាវខ្លះទៀតសន្និដ្ឋានថា ខ្មែរជាអ្នកកើតនៅលើទឹកដីឥណ្ឌូចិននេះ តែគ្រាន់តែបានទទួលឥទ្ធិពលពីឥណ្ឌានៅសតវត្សទី ១ ។



រូបទី ១ : **មនុស្សប្រុសដីដុត** ស.វ.ទី ៦ នៃគ.ស

ចំពោះបញ្ហាដ៏សំខាន់នេះ តើការពិតស្ថិតនៅត្រង់ណា ? តើយើងមានភស្តុតាងអ្វីសំរាប់គាំទ្រ រឺ បដិសេធមតិខាងលើនេះដែររឺទេ ?

### មតិទី ១

អ្នកនិពន្ធបរទេសសង្កេតឃើញខ្មែរ កាន់សាសនាឥណ្ឌា « ព្រាហ្មណ៍សាសនា និង ព្រះពុទ្ធសាសនា » ប្រើអក្សរសំស្ក្រឹតទំនៀមទំលាប់ក្បួនខ្លះ រឺ មានរបៀបគ្រប់គ្រងតាមឥណ្ឌា « របបរាជានិយម » គេក៏បានសរសេរថា « ខ្មែរជាជនជាតិឥណ្ឌា » ដែលបានរត់ចេញពីប្រទេសកំណើតរបស់ខ្លួន ចូលមកនៅក្នុងទឹកដីខ្មែរ ។ នេះជាមតិរបស់លោកអែមោនីយេ និងលោកឡឺក្លែរ ។ អ្នកនិពន្ធខ្លះទៀតថែមទាំងហ៊ានអះអាងថា ខ្មែរមានទីតាំងដើមនៅជើងភ្នំទីបេ ចុះមកភូមិភាគអាស៊ីអាគ្នេយ៍នាដើមសតវត្សទី ១ ។ នេះជាទស្សនៈរបស់លោកគើន និងលោកប្រេម រឺឌី ។

### មតិទី ២

មតិទី ២ មានការយល់ឃើញខុសប្លែកពីមតិទី ១ ។ តាមទ្រឹស្តីរបស់លោក ប្រ៉ាលីយេ ខ្មែរជាជនជាតិពិសេសមួយស្ថិតក្នុងអំបូរមន - ខ្មែរ ហើយជនជាតិនេះ បានកើតឡើងនៅលើជ្រោយឥណ្ឌូចិនតែម្តង ខុសពីចិន យួន និង ភូមា ដែលមានទីលំនៅៗ ស្រុកចិន ។ ម្យ៉ាងទៀត អ្នកស្រាវជ្រាវនេះ បានបន្ថែមទៀតថា អំបូរមន - ខ្មែរ កើតមកពីការជ្រុំគាត់រវាងពួក



រូបទី ២ : **ដែនដី អំបូរ មន - ខ្មែរ**

មេឡាណេស៊ីយាង និងពួកឥណ្ឌូណេស៊ីយាង ដែលរស់នៅពាសពេញលើសុវណ្ណភូមិ ។ ទីតាំងរបស់ជនជាតិអំបូរ មន - ខ្មែរ ស្ថិតពីឆ្នេរសមុទ្រចិន រហូតដល់ព្រំប្រទល់ឥណ្ឌា ។

សូមបញ្ជាក់ថា ពួកឥណ្ឌូណេស៊ីយាង តពូជពីពួកម៉ាឡេស៊ីយាង ដែលមានសម្បុរខ្មៅស្រអែម ។ បុព្វហេតុដែលបណ្ដាលអោយគេហ៊ានសន្និដ្ឋានដូច្នោះ គឺមកពីការរកឃើញនូវ « លលាដ៍ក្បាល » ដែលមានលក្ខណៈជាមេឡាណេស៊ីយាងនៅឥណ្ឌូចិន ។ លលាដ៍ក្បាលនៃពួកមេឡាណេស៊ីយាង មានអាយុច្រើនជាងលលាដ៍ក្បាល នៃពួកឥណ្ឌូណេស៊ីយាង ។ តាមការពិត ពួកឥណ្ឌូណេស៊ីយាងគឺពួក មន - ខ្មែរ តែម្ដង ពីព្រោះមន- ខ្មែរ ស្ថិតក្នុងក្រុមមនុស្ស ឥណ្ឌូណេស៊ីយាង គ្រាន់តែមានភាសាខុសគ្នាតែប៉ុណ្ណោះ ។ ចំពោះលោក អូលីវីយេ ខ្មែរមិនមែន ចិន យួន រឺ ឥណ្ឌាទេ ។ ខ្មែរជាខ្មែរ ។ ហើយចំពោះអ្នកប្រាជ្ញរូបនេះក្នុងពាក្យ « **ពូជសាសន៍ឥណ្ឌូណេស៊ីយាង** » យើងត្រូវបញ្ចូលជនជាតិ ឥណ្ឌូណេស៊ីយាង ដែលសព្វថ្ងៃនៅប្រទេសឥណ្ឌូណេស៊ី ខ្មែរ « មន » ពួកខ្មែរលើទាំងអស់ ដូចជា ភ្នង ស្ទូច ខា រ៉ដែ ជ្រាយ គួយ ព័រ ព្រម ទាំងពួកមនុស្សរស់តាមព្រៃភ្នំនៅ ហ្វីលីពីន ដូចពួកសាកាយជាដើម និង ពួកដាយាកនៅប្រទេសឥណ្ឌូណេស៊ីផង ។ល ។

ដោយសារការសិក្សាផ្នែកភាសាសាស្ត្រ និង ផ្នែកប្រពៃណីផ្សេងៗ រវាងខ្មែរដែលបានទទួលនូវវប្បធម៌ក្បួន និងសម្ព័ន្ធខ្មែរលើ ដែលរស់នៅតាមដងព្រៃភ្នំ អ្នកប្រាជ្ញបារាំងសេសស៊ីដេស បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ខ្មែរសព្វថ្ងៃ គឺជាពួងទទួលវប្បធម៌ក្បួន ។ ចំពោះលោក ពួងមានន័យថា ខ្មែរបុរាណរឺ ខ្មែរលើដែលរស់នៅតាមដុប(១) តាមព្រៃ ។

ការស្រាវជ្រាវរបស់លោក អូលីវីយេ ក៏បានបំភ្លឺយើងដែរចំពោះបញ្ហាដែលទាក់ទង នឹងឫសគល់នៃជនជាតិខ្មែរ ។ ដោយសំអាងទៅលើវត្ថុមាននៃប្រភេទឈាមម្យ៉ាង ដែលគេតាំងឈ្មោះថា **អេម៉ូហ្គូបៀនអេ** អ្នកវិទ្យាសាស្ត្រនេះបានអះអាង « ដូចលោកស៊ីដេស » ដែរថា ខ្មែរ ខ្មែរលើ នៅស្រុកយួន សៀម លាវ ភូមា ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ចាម និង មន ជាជនជាតិរួមពូជសាសន៍តែមួយ ។



រូបទី ៣ : **ស្រីក្រមុំខ្មែរលើ (យួនខាងត្បូង)**
**រូបភាពឆ្នាំ ១៩៣០-១៩៣៥**




រូបទី ៤ : **ដែនដីអំបូរ មន-ខ្មែរ នៅកម្ពុជា**

(នៅមានតទៅលេខក្រោយ)
ដកស្រង់ចេញពីសៀវភៅប្រវត្តិនៃកម្ពុជា
របស់ឯកឧត្តម **មីសែល ត្រាណេ**

(១). តម្កោត ( ប្រែតាមទំលាប់ដោយស្រុក )



ខ្ញុំសូមចុះផ្សាយទាំងស្រុងនូវលិខិតលោក យិន គឹមទូ គ្រូមធ្យមសិក្សាកំរិត ១ នៃអនុវិទ្យាល័យបារាយណ៍ ឃុំបារាយណ៍ ខេត្តកំពង់ធំ ដើម្បីជូនសមាជិក - សមាជិកា ស.ប.ស.ខ ទាំងអស់ជ្រាបពីទឹកចិត្តរបស់ស្នេហ៍ចំពោះទស្សនាវដ្តីគ្រូបង្រៀន ។ គាត់បានរៀបរាប់យ៉ាងក្បោះក្បាយមានទំរង់ និង អត្ថរស គួរជាទីពេញចិត្ត ។ ខ្ញុំសូមស្នើលោកគ្រូ - អ្នកគ្រូទាំងអស់រៀនពិចារណា រៀនវិនិច្ឆ័យលើសំនេរនេះ ។ តើអស់លោកមានយោបល់ដូចស្នេហ៍ទេ ? ប៉ុន្មានភាគរយស្រប ? ប៉ុន្មានភាគរយមិនស្រប ? សូមមេត្តាសរសេរមកគណៈកម្មាធិការនាយក ស.ប.ស.ខ ។ ខ្ញុំនឹងចាំទទួលដោយរីករាយ ។

**យ៉ង់ ធី**

បារាយណ៍, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៨

ខ្ញុំបាទឈ្មោះ យិន គឹមទូ គ្រូមធ្យមសិក្សាកំរិត ១នៃអនុវិទ្យាល័យបារាយណ៍ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**សូមគោរពចូលមកគណៈកម្មាធិការនាយក ស.ប.ស.ខ.**

សូមទានជ្រាប ។

ខ្ញុំបាទសូមសំដែងនូវមនោសញ្ចេតនា រីភើបរីករាយក្រៃលែង ចំពោះគណៈកម្មាធិការនាយក ស.ប.ស.ខ ដែលបានតស៊ូពុះពារយ៉ាងប្តូរផ្តាច់ ដើម្បីប្រសូត្រចេញនូវទស្សនាវដ្តីគ្រូបង្រៀន ដែលមានឧត្តមគតិដ៏ជ្រាលជ្រៅ ក្នុងគោលបំនងលើកស្ទួយកិត្តិយសលោកគ្រូ - អ្នកគ្រូ អោយទទួលបានបទពិសោធន៍ និងចំនេះដឹងថ្មី ល្អៗ វិធីសាស្ត្របង្រៀនចិត្ត - គរុកោសល្យ ក្នុងការលើកកំពស់វិជ្ជាជីវៈគ្រូបង្រៀន និងគុណភាពអប់រំអោយបានឧត្តុងឧត្តម ។

ទស្សនាវដ្តីគ្រូបង្រៀន ប្រៀបដូចជាយានដ៏មានរស្មីត្រចះត្រចង់ ដែលបានជួយបំភ្លឺផ្លូវដល់ខ្ញុំបាទជាគ្រូបង្រៀនម្នាក់ ដើម្បីជួយលើកតំកាស់កំរិតវប្បធម៌ - គុណធម៌ - សីលធម៌ មនសិការនៃវិជ្ជាជីវៈជាគ្រូបង្រៀន អោយកាន់តែល្អប្រសើរឡើង ។ តាមរយៈអត្ថបទចុះផ្សាយក្នុងទស្សនាវដ្តីគ្រូបង្រៀន បានផ្តល់នូវចំនេះដឹងថ្មីៗ បទពិសោធន៍ល្អៗ ទុកជាមេរៀនដ៏ប្រពៃចំពោះលោកគ្រូ - អ្នកគ្រូគ្រប់មជ្ឈដ្ឋានកំរិតសិក្សា ។

ទស្សនាវដ្តីគ្រូបង្រៀន ប្រៀបដូចជាស្ពានសំរាប់រឹតចំនងសាមគ្គីភាព ក្នុងជួរគ្រូបង្រៀនគ្រប់មជ្ឈដ្ឋានកំរិតសិក្សាអោយកាន់តែយោគយល់គ្នា ចេះអធ្យាស្រ័យគ្នាយ៉ាងល្អប្រសើរ ។

ទស្សនាវដ្តីគ្រូបង្រៀន គឺជាប្រទីបដ៏ភ្លឺថ្លា រឺ ប្រៀបដូចជាត្រីវិស័យដ៏ល្អឯក ដែលចង្អុលបង្ហាញផ្លូវដល់ខ្ញុំបាទដែលជាគ្រូបង្រៀនម្នាក់ ក៏ដូចជាលោកគ្រូ - អ្នកគ្រូទាំងអស់ អោយដើរឆ្ពោះទៅរកផ្លូវត្រូវ ប្រកបដោយស៊ីលធម៌ - គុណធម៌ និង សច្ចធម៌ ។

ដូច្នេះដើម្បីជាសក្ខីភាពឆ្លើយតបទៅនឹងវត្ថុបំនងឧត្តុងឧត្តម និង ឧត្តមគតិដ៏ជ្រាលជ្រៅរបស់គណៈកម្មាធិការនាយក ស.ប.ស.ខ ខាងលើ ក្នុងនាមខ្ញុំបាទជាគ្រូបង្រៀនម្នាក់ដែលតែងតែចង់ចេះ ចង់ដឹង ចង់បាននូវបទពិសោធន៍ល្អៗ ខ្ញុំបាទសូមសំនូមពរលោកនាយក ស.ប.ស.ខ មេត្តាផ្តល់នូវអត្ថបទជាវិធីសាស្ត្របង្រៀនផ្នែកភាសាខ្មែរ អោយបានច្រើនអត្ថបទ ដើម្បីជាជំនួយពុទ្ធិដ៏ប្រសើរ ។ ជាមួយគ្នានេះដែរ ខ្ញុំបាទសូមប្រសិទ្ធិពរបវរមហាប្រសើរ ចំពោះគណៈកម្មាធិការនាយក ស.ប.ស.ខ សូមអោយទទួលបានជោគជ័យគ្រប់ភារកិច្ចដ៏ថ្លៃថ្លាបំផុត ។

សូមអស់លោកទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ឧត្តុងឧត្តមបំផុតអំពីខ្ញុំ ។

**យិន គឹមទូ**

# ប្រធានអត្ថាធិប្បាយ

**( Sujet de dissertation )**

កាលពីថ្ងៃទី ៧ - ១០ - ១៩៩៧ ខ្ញុំបានដាក់ប្រធានអត្ថាធិប្បាយតរុកោសល្យមួយ ជូនជាសំនើត្រិះរិះពិចារណា ដើម្បីបង្កើនចំនេះដឹង ។ ប៉ុន្តែ មកទល់ថ្ងៃនេះ ខ្ញុំបានទទួលកិច្ចការមួយចំនួន តែពុំមានកិច្ចការណាមួយឆ្លើយបានត្រឹមត្រូវឡើយ ។ ខ្ញុំសូមរំលឹកឡើងវិញថា ប្រធាននោះមានខ្លឹមសារដូចតទៅ ៖

## ជាភាសាបារាំង

Il est vain d'exiger des hommes l'esprit d'équipe et le sens des responsabilités, si l'école n'est pas porteuse de ces valeurs.

Expliquez et discutez cette affirmation. Dites comment vous procédez dans votre classe pour éveiller et développer chez vos élèves ces vertus essentielles.

## ប្រែជាភាសាខ្មែរ

ជាការឥតប្រយោជន៍ ដែលទាមទារអោយមនុស្សពេញវ័យមានគតិយុត្តគូ ( សាមគ្គីភាពរវាងអ្នកនៅក្នុងក្រុមជាមួយ ) និងមានស្មារតីទទួលខុសត្រូវ ប្រសិនបើសាលារៀនមិនមានលទ្ធភាពបណ្តុះគុណសម្បត្តិនេះបានទេ ។

សូមពន្យល់ និង ពិភាក្សាអំនះអំនាងនេះ ។ សូមអធិប្បាយថា តើនៅក្នុងថ្នាក់រៀនរបស់លោក លោកធ្វើបែបណា ដើម្បីបំផុស និង បណ្តុះគុណធម៌ ( គុណសម្បត្តិ ) ជាសារវន្តនេះដល់សិស្សលោក ។

ដើម្បីជាជំនួយ ក្នុងការធ្វើអត្ថាធិប្បាយ ខ្ញុំសូមលោកគ្រូ អ្នកគ្រូ ហាត់គិត ហាត់ពិចារណាជាមួយខ្ញុំ ។ ក្នុងប្រធាននេះ គេចង់អោយយើងធ្វើអត្ថាធិប្បាយលើចំនុចអ្វីខ្លះ ដែលសំខាន់ៗ ? គិតជញ្ជឹងសិនមុនអានបន្តទៅទៀត ។

១. គតិយុត្តគូ : ( សាមគ្គីភាពរវាងអ្នកនៅក្នុងក្រុមជាមួយ ) L'ésprit d'équipe

២. ស្មារតីទទួលខុសត្រូវ : Le sens des responsabilités

សូមពន្យល់ពាក្យទាំងពីរនេះ ដែលចាត់ទុកជាគុណធម៌ រឺ តំលៃ ។

ដូចម្តេចដែលហៅថា គតិយុត្តគូ ? គឺជាស្មារតីសាមគ្គីភាពនៃសមាជិកក្រុម ដែលធ្វើការរួមគ្នានៅលើការងារមួយ ។ ឧ: ក្រុមបាល់ទាត់ ត្រូវតែមានស្មារតីសាមគ្គីភាព ស្រះស្រួលមតិគ្នា ដើម្បីទាត់អោយបានឈ្នះក្រុមម្ខាងទៀត ។ ជាការងាយយល់ណាស់ ស្មារតីសាមគ្គីភាពរវាងសមាជិករបស់ក្រុមអាចមើលឃើញទៅលើសមាជិកម្នាក់ៗ ដែលបណ្តើរបាល់ ។ ភារកិច្ចរួម ត្រូវតែប្រឹងរួមគ្នា ។ ស្មារតីសាមគ្គីភាព ត្រូវការស្មារតីទទួលខុសត្រូវ ។ សមាជិកម្នាក់ត្រូវបំពេញភារកិច្ចអោយអស់ពីកំលាំងកាយ និង ចិត្ត ។ ប្រសិនបើមិនមានស្មារតីទទួលខុសត្រូវទេ នោះក៏មិនមានស្មារតីសាមគ្គីភាពរបស់ក្រុមនីមួយៗដែរ ។ ឧ: អ្នកទាត់បាល់ម្នាក់ ពូកែជាងគេ ត្រូវក្រុមម្ខាងទៀតទិញទឹកចិត្តបាន ។ នៅថ្ងៃប្រកួតផ្តាច់ព្រ័ត្រ គេទាត់មិនសូវយកចិត្តទុកដាក់ ។ អ្នកនោះឯង គឺបាត់ស្មារតីសាមគ្គីភាព បាត់ស្មារតីទទួលខុសត្រូវរបស់ក្រុម ។

ស្មារតីទទួលត្រូវ ជាគុណធម៌ រឺ គុណសម្បត្តិរបស់មនុស្ស ។ ធ្វើអ្វីមួយមិនមានទំនួលខុសត្រូវ គឺបំពេញការងារមិនបានល្អ គឺធ្វើអោយរួចតែពីដៃ ខ្ជិលខ្ជា ។ ពាក្យទំនួលខុសត្រូវ ច្រើននិយាយតែទៅលើការខ្វះខាត ការខុសឆ្គង

អ្វីមួយ ការមិនសំរេចភារកិច្ចដោយខ្វះមនសិការ ។ ឧ: ក្រុមហ៊ុនម៉ៅការមួយ ទទួលសាងសង់អាគារសិក្សាមួយខ្នង ។ ដោយខ្ជិលខ្ជា មិនត្រួតពិនិត្យអោយបានដិតដល់ សំនង់នេះ ធ្វើរួចមិនទាន់បានប៉ុន្មានខែផង ត្រូវស្រុត រឺ ប្រេះជញ្ជាំង រឺ ដំបូលលិចទឹកភ្លៀង ។ នេះ គឺមកពីការខ្វះស្មារតីទទួលខុសត្រូវ ។ គ្រូបង្រៀនក៏ដូចនោះដែរ តែកាលណាខ្វះមនសិការ វិជ្ជាជីវៈ កិច្ចការមិនបានបំពេញម៉ត់ចត់ បោះបង់ចោលសិស្ស ។ល ។

ពាក្យទំនួលខុសត្រូវ គឺជាការទទួលខុសផង ត្រូវផង ។ យើងធ្លាប់ប្រើពាក្យនេះតែទៅលើទង្វើខុស ឆ្គាំឆ្គង មិនសំរេចបានលទ្ធផលជាទីពេញចិត្ត ។ ផ្ទុយទៅវិញ ប្រសិនបើការងារមួយធ្វើបានសំរេចលទ្ធផលល្អ សាមីជនទទួលបានទូវការសរសើរ ។ នេះមកពីការបំពេញការងារដោយមានទំនួលខុសត្រូវ ។ គេសប្បាយនឹងស្នាដៃរបស់គេ ។

ឥឡូវនេះ ពាក្យទាំងពីរត្រូវបានពន្យល់ហើយ ។ តើប្រធានតំរូវអោយយើងធ្វើអ្វីទៀត ។ សូមគិតសិន ។ ពាក្យថា ពិភាក្សា ( ជជែកវែកញែក ) អំនះអំនាងនេះ បានសេចក្តីថា ដូចម្តេច ? តើក្នុងប្រធាន គេពោល អះអាងថាដូចម្តេច ? ខ្ញុំសូមលើកមកបង្ហាញម្តងទៀត ។ គេពោលថា « ជាការឥតប្រយោជន៍ ដែលទាមទារអោយមនុស្សពេញវ័យ មានគតិយុត្តគូ ( សាមគ្គីភាពរវាងអ្នកនៅក្នុងក្រុមជាមួយ ) និង មានស្មារតីទទួលខុសត្រូវ ប្រសិនបើសាលារៀនមិនមានលទ្ធភាពបណ្តុះគុណសម្បត្តិនេះបានទេ » ។

យើងអាចនិយាយមួយបែបទៀតថា កុមារា កុមារី ដែលកំពុងរៀននៅសាលាដែលមានកម្មវិធីដូចសព្វថ្ងៃនេះ ដល់អាយុពេញវ័យ អាចមានគុណសម្បត្តិពីរយ៉ាងនេះបានរឺទេ ប្រសិនបើសាលារៀនមិនបានបង្ហាត់បង្រៀនអោយមានស្មារតីសាមគ្គីភាព និងស្មារតីទទួលខុសត្រូវ កាលនៅក្នុងយុវវ័យ ។ យើងងាកមកមើលការរៀនសូត្រសិស្សយើងសព្វថ្ងៃ ។ តាមបែបបុរាណ (école traditionnelle) រឺតាមបែបសម័យខ្លះដែរ (école moderne) ។ សូមលោកគ្រូ អ្នកគ្រូ ពិចារណា ។ ក្នុងការបង្រៀនសិស្ស តើយើងចង់អោយសិស្សដើរទៅដល់គោលកំនត់ជាដូចម្តេច ។ បានឈានដើរលើផ្លូវនោះហើយរឺនៅ រឺនៅទ្រេតទ្រោត មិនដឹងទៅឆ្វេង រឺទៅស្តាំ ។ មើលទិសដៅមិនឃើញ ? នេះជាបញ្ហាដែលត្រូវគិត ។ យើងចង់អោយកូនខ្មែរទៅជាមនុស្សបែបណានៅបច្ចុប្បន្នកាលនេះ និង ទៅអនាគត ។

ខ្ញុំសូមស្នេះប៉ុននេះចុះ ។ ខ្ញុំដាក់សំនួរខាងលើ ទុកអោយអស់លោកគិត ។ ឥឡូវនេះ យើងត្រូវងាកមកមើលប្រធានវិញ ។ នៅក្នុងប្រធាន គេចង់អោយគ្រូបង្ហាត់បង្រៀនសិស្សអោយមាន ។ ទី ១ : ធម៌សាមគ្គី ( solidarité ) ទី ២ : ស្មារតីទទួលខុសត្រូវ ។

ចំពោះគុណធម៌ទាំងពីរនេះ កម្មវិធីសិក្សាយើងនាបច្ចុប្បន្ននេះ បានបញ្ចូលទ្រឹស្តី « សិស្សជាមជ្ឈមណ្ឌល » ការងារ « តាមក្រុម រឺ តាមពួក » គេសួរសិក្ខាបនធារីថា តើត្រូវរៀបចំបង្រៀនបែបណា ដើម្បីបំផុស និង ពង្រឹងគុណសម្បត្តិជាសារវ័ន្តទាំងពីរនេះ ។ ដើម្បីពង្រីកចំនេះដឹងទៅលើបញ្ហានេះ ខ្ញុំសូមលោកគ្រូ អ្នកគ្រូ អានអត្ថបទចុះទស្សនាវដ្តីគ្រូបង្រៀនលេខ ៤ ទំព័រ ២៨ និង ២៩ និង អានទស្សនាវដ្តីលេខ ៧ ទំព័រ ៣៧ និង អត្ថបទ « វិធីបង្រៀនសិស្សមជ្ឈមណ្ឌល » ចុះក្នុងទស្សនាវដ្តីលេខ ៨ ដែលលោកអ្នកកំពុងកាន់នៅដៃ ។

តាមពត៌មានទទួលបាន ខ្ញុំដឹងថា នៅតាមសាលារៀនយើងមួយចំនួនធំ បានរៀបចំការរៀនសូត្រចែកជាពួក ជាក្រុមតាមវិធីសាស្ត្រថ្មី ដែលអង្គការមិនមែនរដ្ឋាភិបាល ( **ONG** ) បានបណ្តុះបណ្តាល ។ ជាទំលាប់យូរមកហើយសាលារៀនបានចាត់សិស្សអោយដាំបន្លែ ដាំផ្កា បំផុសចលនាប្រលងប្រទាំងតាមថ្នាក់ និង បានចាត់សិស្សអោយបំពេញមុខងារផ្សេងៗ នៅពេលបុណ្យផ្កាកសាងសាលារៀន ។

ជាទីបញ្ចប់ ខ្ញុំសូមគំនិតថ្មីក្នុងការអប់រំ រីកដុះដាលនៅក្នុងជួរគ្រូបង្រៀនយើង ដើម្បីកសាងមនុស្សនា ស.ត.ទី ២១ ខាងមុខនេះ ។

លោក យ៉ង់ ធី

# សំនួរ

ទី ១ : លោកគ្រូ អ្នកគ្រូ ធ្លាប់បានអានសៀវភៅសីលធម៌ និងបានប្រទះឃើញពាក្យពីរម៉ាត់ ដែលខ្ញុំ

*សូមអោយបកស្រាយ* : សីលធម៌ និង គុណធម៌

- ដូចម្តេចហៅថា សីលធម៌ ?
- ដូចម្តេចហៅថា គុណធម៌ ?

សូមអធិប្បាយ ។

ទី ២ : *សូមពន្យល់ពាក្យ* :

- អត្តសញ្ញាណវប្បធម៌ ? Identité culturelle
- បេតិកភ័ណ្ឌវប្បធម៌ ? Patrimoine culturel

ទី ៣ : *ពាក្យ* : បង្រៀន និង រៀន

តើលោកគ្រូ អ្នកគ្រូ យល់ថាដូចម្តេច ?
សូមអធិប្បាយ ។

លោក **យ៉ង់ ធី**

---

**ចំលើយចំពោះលិខិតលោក ឌឹម លីម**

គ្រូបង្រៀននៅសាលាបឋមសិក្សាឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

ខ្ញុំបានទទួលលិខិតលោកហើយ ដែលឆ្លើយបានត្រឹមត្រូវល្អ នូវសំនួរអំពីបញ្ញាសជាតក (vie antérieure du Buddha. ?) ចុះក្នុងទស្សនាវដ្តីលេខ ៦ ។ ខ្ញុំសូមលោកអធ្យាស្រ័យ ដោយមិនបានចុះសំនេររបស់លោក ដោយលោកគ្រូយើងបានឆ្លើយមកមុនជាច្រើន តែខ្ញុំយកតែចំលើយអ្នកគ្រូ **ស្វាយ ធឿម** ចុះក្នុងទស្សនាវដ្តីលេខ ៧ ព្រោះទស្សនាវដ្តីគ្រូបង្រៀនត្រូវបានកំរិតទំព័រក្នុងការចេញមួយលើកៗ ។

លោក **យ៉ង់ ធី**

---

**សេចក្តីជូនដំណឹង**

ដោយទស្សនាវដ្តីយើងមានទំព័រកំរិត ខ្ញុំមិនអាចចុះចំលើយនៃសំនួរទី ១ និងទី ២ ដែលចុះក្នុងទស្សនាវដ្តីលេខ ៧ ឡើយ ។ សូមរង់ចាំអានទស្សនាវដ្តីលេខក្រោយ ។

សូមអរគុណ និង សូមអធ្យាស្រ័យ

លោក **យ៉ង់ ធី**



**មេសុក្រ** **បទភាគគតិ**

# ខំទាន់ខ្លួនក្មេង

១. កើតមកជាមនុស្ស វិជ្ជាទាបខ្លស់ កូនត្រូវសិក្សា
អក្សរទព្វន្ត ច្បាប់ក្បួនតម្រា ចេះច្រើនភាសា
ទុះបាបានគាប់ ។

២. ខំទាន់ខ្លួនក្មេង កុំគិតតែលេង ដល់ចាស់អភ័ព្វ
បើខ្សត់វិជ្ជា កូននឹងខ្សត់ទ្រព្យ ល្ងង់ញាតិពុំគាប់
មិនរាប់ជាគ្នា ។

២. បើមានចំនេះ ឫកពារិសេស តង់មានទ្រព្យា
កេរ្តិ៍ឈ្មោះបូឆ្ងាយ ណាកូនពុំងា លោកិយសុខជា
ដល់សួគ៌ាហោង ។

---

និពន្ធដោយលោក **ឯក សុក្រ**
អតីតគ្រូបង្រៀនអប់រំកាយ និង កីឡា ជំនាន់ទី ៥
ស.វ.អា. ថ្ងៃទី ១ ខែ វិច្ឆិកា ១៩៩៧

# កុំទុកពេលទំនេរ

« តាមលំនាំបទឱដ្ឋាយលើមេឃ » ( ចង្វាក់រាំវង់ )

I. កូនអើយចងចាំ គ្រូកូនបានផ្តាំប្រាប់កូនៗ ជីវិតរស់បានថ្លៃថ្លាបវរ
ភក្តីស្មោះសថៃព្រលឹងជាតិ (ពីរដង) ។

II. វិជ្ជាជាយាន កូនខំរៀនអានតាមវគ្គតាមឃ្លា បើរៀនសរសេរត្រូវចំនាំវា
បើរៀនគណនាពុះពារិះគិត (ពីរដង) ។

III. កូនអើយត្រូវចាំ គ្រូកូនខំផ្តាំកុំអោយកូនភ្លេច ប្រើពេលវេលាព្យាយាមជានិច្ច
កុំទុកកុំភ្លេចព្រោះជាមាសប្រាក់ (ពីរដង) ។

IV. ប្រទេសចំរើន សេដ្ឋកិច្ចរីកច្រើនដោយសារបុគ្គលា ចេះប្រើពេលវាចេះជួយការពារ
ប្រើប្រាស់គ្រប់គ្នាគព្វជគពង្ស (ពីរដង) ។

តែងបទចំរៀងដោយលោក **អុម ចាន់ចន្ទ្រា**
ជាអធិការបឋមសិក្សា និងជាអនុប្រធានមន្ទីរ អ.យ.ក. ខេត្តមណ្ឌលគិរី

# ទឹកចិត្តម្ដាយ

ពេលម្ដាយក្រមុំស្រស់ប្រិមប្រិយ ក្រអូបឥតបីគ្រប់វេលា
សំលៀកបំពាក់សមសោភា ស្រស់ស្រីពុំងារសក់រំសាយ ។

ស្រលាញ់ខ្លួនណាស់តែងផ្ចិតផ្ចង់ ទោណាម្ដងៗ មើលរាងកាយ
រៀបចំខ្លួនប្រាណមិនរាយមាយ គួរគយគន់ឆ្ងាយកល្យាណី ។

ពេលមានកូនម្ដាយមិនសូវគិត ពីខ្លួនឯងពិតស្រវាំបី
បុត្រភ្ងាសំលាញ់លើសលប់អ្វី សន្ដោសប្រណីរាល់យប់ថ្ងៃ ។

រាត្រីម្ដាយសំរាន្ដមិនផ្អែត រវល់បើកភ្នែកមើលបុត្រថ្ងៃ
ក្រែងមានស្រមោចឬសត្វអ្វី ខាំទិចពិសីពៅមាសមុំ ។

បុត្រជុះបុត្រនោមម្ដាយមិនថា អោយតែពុំងារបានសុខុម
សុខភាពបវរល្អឧត្ដម ទើបអស់បារម្ភពីបុត្រស្ងួន ។

ម្ដាយឈឺម្ដាយថ្កាត់មិនហាស្ដី លំបាកម្ដេចក្ដីម្ដាយខំធ្ងួន
ទោះបីហត់នឿយមិនគេចពួន ម្ដាយនៅមាំមួនមិនត្អូញឡើយ ។

កូនមានតំហុសម្ដាយជេរស្ដី ប្រដៅស្រដីគ្មានកន្ដើយ
អាណិតអាសូរបុត្រគ្មានត្រើយ ជេរស្ដីរួចហើយហៅរកវិញ ។

ចិត្តម្ដាយចង់អោយកូនបានខ្ពស់ ថ្កុំថ្កើងសក្ដិយសទ្រព្យពោរពេញ
ដោយភាពសុខជុមគ្មានទោម្នេញ ពុំគិតចំនេញពីកូនហោង ។

លុះកូនធំឡើងចេះដឹងក្ដី សក្ដិសមឥតបីល្អហ្មត់ហ្មង
ម្ដាយសែនត្រេកអរពេកកន្លង ទួនល្អងដើរតាមដំបូន្មាន ។

ជាតិថ្កុំជាតិថ្កើងដោយសារស្ងួន កំលាំងមាំមួនប្រឹងប្រែងរៀន
ចំនេះគ្រប់មុខធ្វើជាយាន នាំជាតិឆ្ពោះឈានអភិវឌ្ឍន៍ ។

ដោយលោកស្រី **ហង្ស ភរី**

# ដំណឹងមរណភាព

គណៈកម្មាធិការនាយកនៃស.ប.ស.ខ សូមជូនពត៌មានថា ៖ ក្នុងរយៈពេលប្រាំមួយខែ បន្តពីខែ តុលា ឆ្នាំ១៩៩៧ គឺខែ វិច្ឆិកា ធ្នូ ១៩៩៧ និង មករា កុម្ភៈ មិនា មេសា ១៩៩៨ សមាជិក សមាជិកាយើង បានទទួលអនិច្ចកម្មមានកំនើនទាំងអស់ចំនួន **:១១៧នាក់** ។ រីឯគូស្រករ ( ប្តី រឺ ប្រពន្ធ ) ចំនួន : **៦៤ នាក់** ដូចតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសព សមាជិក | ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសព សមាជិក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំយុវជននិងកីឡា | | ១២ | ខេត្ត ស្វាយរៀង | ០៣ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០៨ នាក់ | ១៣ | ខេត្ត ព្រៃវែង | ១០ នាក់ | |
| ០២ | ខេត្ត តាកែវ | ០៨ នាក់ | ១៤ | ខេត្ត បាត់ដំបង | ០៣ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ១១ នាក់ | ១៥ | ខេត្ត កំពង់ឆ្នាំង | ០៤ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០៤ នាក់ | ១៦ | ខេត្ត កំពង់ស្ពឺ | ១១នាក់ | |
| ០៥ | ខេត្ត កណ្តាល | ០៨នាក់ | ១៧ | រាជធានីភ្នំពេញ | ១០ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ២១នាក់ | ១៨ | ខេត្ត ពោធិសាត់ | ០១ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៥ នាក់ | ១៩ | ខេត្ត ស្ទឹងត្រែង | ០០ នាក់ | |
| ០៨ | ខេត្ត កំពត | ០៨នាក់ | ២០ | ខេត្ត កោះកុង | ០០ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០១នាក់ | ២១ | ខេត្ត រតនគិរី | ០១ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០១ នាក់ | ២២ | ខេត្ត មណ្ឌលគិរី | ០០ នាក់ | |
| ១១ | ក្រុង កែប | ០០នាក់ | ២៣ | ខេត្ត ព្រះវិហារ | ០២នាក់ | |
| | | សរុប : | | | **១១៧ នាក់** | |

| ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសពគ្រួសារ ប្តី រឺ ប្រពន្ធ | ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសពគ្រួសារ ប្តី រឺ ប្រពន្ធ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំ យុវជន និងកីឡា | | ១២ | ខេត្ត ស្វាយរៀង | ០៤ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០២ នាក់ | ១៣ | ខេត្ត ព្រៃវែង | ០៥ នាក់ | |
| ០២ | ខេត្ត តាកែវ | ០៦នាក់ | ១៤ | ខេត្ត បាត់ដំបង | ០២ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ០៤នាក់ | ១៥ | ខេត្ត ព្រះវិហារ | ០០ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០៥ នាក់ | ១៦ | ខេត្ត កំពង់ឆ្នាំង | ០១នាក់ | |
| ០៥ | ខេត្ត កណ្តាល | ០២ នាក់ | ១៧ | ខេត្ត កំពង់ស្ពឺ | ១៣ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ០៥ នាក់ | ១៨ | រាជធានីភ្នំពេញ | ១១ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៤ នាក់ | ១៩ | ខេត្ត ពោធិសាត់ | ០២ នាក់ | |
| ០៨ | ខេត្ត កំពត | ០២ នាក់ | ២០ | ខេត្ត ស្ទឹងត្រែង | ០២ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០៣ នាក់ | ២១ | ខេត្ត កោះកុង | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០១នាក់ | ២២ | ខេត្ត រតនគិរី | ០០ នាក់ | |
| ១១ | ខេត្ត មណ្ឌលគិរី | ០០នាក់ | ២៣ | ក្រុងកែប | ០០ នាក់ | |
| | | សរុប : | | | **៦៤ នាក់** | |

អប់រំ គឺ ជាភារកិច្ច របស់ យើងទាំងអស់គ្នា

រោងពុម្ព ក្រសួងអប់រំ